# ២០សំណួរ

# ដែលសួរច្រើនបំផុតដោយ

## អ្នកមិនមែនមូស្លីម



បកស្រាយដោយ

បណ្ឌិត ហ្សាកៀរ អាប់ឌុលការីម

វាជាកាតព្វកិច្ចលើអ្នកមុស្លឹមគ្រប់រូប ត្រូវផ្តល់សារឥស្លាមទៅកាន់អ្នកមិនទាន់ស្គាល់សារនេះ ចាំបាច់លើអ្នកមុស្លឹមគ្រប់រូបត្រូវផ្សព្វផ្សាយសាសនាឥស្លាម ការផ្សព្វផ្សាយនេះមានន័យថា ការអំពាវនាវអ្នកមិនមែនមុស្លឹមឲ្យយល់ដឹងពីសាសនាឥស្លាម ការអំពាវនាវអ្នកមិនមែនឥស្លាមឲ្យយល់ដឹងពីសាសនាឥស្លាម ជាកាតព្វកិច្ចរបស់អ្នកមុស្លឹមគ្រប់រូប មានមាគ៌ានិងវិធីសាស្រ្តជាច្រើនដែលអ្នកមុស្លឹមប្រើក្នុងការផ្សព្វផ្សាយឥស្លាម។ នៅពេលមានការពាក់ព័ន្ធនឹងការផ្សព្វផ្សាយគឺ ជាទូទៅវិធីសាស្រ្តដែលគេច្រើនប្រើ នៅពេលអ្នកមុស្លឹមបានជួបនឹងអ្នកមិនមែនមុស្លឹមគេនិយាយមួយរយចំណុចល្អៗអំពីឥស្លាម។ ទោះបីជាអ្នកមិនមែនមុស្លឹមឯកភាពលើមួយរយចំណុចល្អៗ ដែលអ្នកមុស្លឹមបានប្រាប់អំពីឥស្លាមនោះក៏ដោយ ក៏គេនៅតែមានចំណុចអវិជ្ជមានខ្លះក្នុងចិត្តរបស់គេអំពីឥស្លាម ជូនកាលគាត់និយាយថា បាទខ្ញុំឯកភាពលើរាល់ចំណុចល្អៗរបស់ឥស្លាម ក៏ប៉ុន្តែអ្នកជាមុស្លឹមដូចគ្នានឹងមូស្លីមដែលជាភេរវករ អ្នកដូចជាមុស្លឹមដែលនិយមជ្រុល ពួកអ្នកជាអ្នកដែលផ្សព្វផ្សាយសាសនារបស់ពួកអ្នកដោយផ្លែដាវ ពួកអ្នកជាអ្នកដែលយកស្រ្តីភេទជាទាសករ អូហ!ពួកអ្នកជាអ្នកដែលយកប្រពន្ធច្រើននាក់ នេះជាចំណុចអវិជ្ជមានបន្តិចបន្តួចដែលមាននៅក្នុងគំនិតរបស់គេ ដែលជាមូលហេតុឃាត់គេមិនឱ្យចូលឥស្លាម។ ទាំងនេះជាមូលហេតុ រាល់ពេលដែលខ្ញុំបានជួបអ្នកមិនមែនមុស្លឹម ខ្ញុំតែងសួរគាត់មុនថា តើអ្នកមានអារម្មណ៍ដឹង

ថាឥស្លាមខុសត្រង់ណា? ដោយមិនគិតពីការយល់ដឹងរបស់អ្នក តើវាខុសឬក៏ត្រូវ? តើអ្នកមានអារម្មណ៍ដឹងថាឥស្លាមខុសត្រង់ណា? ហើយខ្ញុំនិងទុកឱកាសឱ្យគេគិតតាមសម្រួល ប្រសិនបើគេចង់រិះគន់ឥស្លាមក៏រិះគន់ចុះ ឬចង់វាយប្រហារក៏វាយប្រហារចុះ ខ្ញុំនិងទុកឱកាសឱ្យគេគិតតាមសម្រួល ហើយខ្ញុំនិងសួរគាត់ម្តងទៀត តើអ្នកមានអារម្មណ៍ដឹងថាឥស្លាមខុសត្រង់ណា? បន្ទាប់ពីគាត់គិតតាមសម្រួលរួច គេនឹងចោទសួរបីរឺបួនសំនួរអំពីសាសនាឥស្លាម អំឡុងពេលប៉ុន្មានទសវត្សកន្លងមកដែលខ្ញុំបានអំពាវនាវអ្នកមិនមែនមុស្លីម ខ្ញុំបានសង្កេតឃើញថា ជាទូទៅមាន ២០សំនួរ ដែលអ្នកមិនមែនមុស្លីមតែងតែសួរជារៀងរាល់លើក។ នៅពេលដែលគេសួរបីរឺបួនសំនួរ គឺសំនួរទាំងនោះច្បាស់ជាមាននៅក្នុងចំណោមសំនួរទាំង២០នោះ។ ប្រសិនបើរអ្នកមុស្លីមគ្រប់រូបដឹងចម្លើយសំនួរទាំង២០ដែលអ្នកមិនមែនមុស្លីមចោទសួរនោះ ដោយប្រើវិធីសាស្ត្រដែលមានហេតុផល ប្រើបញ្ញាញាណ ចំណេះដឹង និងដកស្រង់ចេញពីគម្ពីគួរអាន និងហាទីស ព្រមទាំងដកស្រង់ចេញពីគម្ពីរពិសិដ្ឋដទៃទៀតរបស់ពួកអ្នកមិនមែនមុស្លីម។ ទោះជាអ្នកមិនអាចធ្វើឲ្យគេចូលឥស្លាមយ៉ាងហោចណាស់អ្នកអាចលុបបំបាត់ ការយល់ច្រឡំរបស់គេមកលើឥស្លាមដែរ។ យ៉ាងហោចណាស់គេអាចលុបបំបាត់ចំណុចអវិជ្ជមាដែលមានផ្នត់អ្នកមិនមែនមូស្លីមដែលប្រឆាំងនឹងឥស្លាមដៃ។ ហេតុនេះចាំបាច់បំផុតលើរអ្នកមុស្លីមគ្រប់រូបត្រូវដឹងអំពីសំនួរទាំង២០នេះ។

# សំនួរទី១

# អំពី ជីហាទ

ការយល់ច្រឡំដំបូងគេបង្អស់មកលើឥស្លាម ហើយវាជាលេខរៀងទីមួយក្នុងបញ្ជី គឺ ជីហាទ សព្វថ្ងៃ ជាពាក្យមួយដែលគេយល់ខុសអំពីឥស្លាម។ សូម្បីតែអ្នកមុស្លីមក៏យល់ខុសចំពោះពាក្យជីហាតនេះដែរ កុំថាឡើយអ្នកមិនមែនមុស្លីម។ អ្នកមិនមែនឥស្លាមនិងអ្នកមុស្លីមភាគច្រើនគិតថា ជីហាទគឺ រាល់សង្គ្រៀមណាដែលបង្កឡើងដោយអ្នកមុស្លីមណាម្នាក់ ក្នុងមូលហេតុអ្វីក៏ដោយដូចជាសង្គ្រាមដើម្បីអំណាច ឬដើម្បីទ្រព្យសម្បត្តិ ដើម្បីទឹកដី ឬដើម្បីជាតិសាស្រ្ត ឬភាសា។ ដូច្នេះសង្គ្រាអ្វីក៏ដោយ ឱ្យមបង្កឡើងដោយមុស្លីម ក្នុងមូលហេតុអ្វីក៏ដោយ គឺពួកគាត់ហៅថាជីហាទ។ ជីហាទមិនមែនមានន័យថា រាល់សង្គ្រាមដែលបង្កឡើងដោយមុស្លីមក្នុងមូលហេតុអ្វីក៏ដោយនោះទេ ដូចជា សង្គ្រាមដើម្បីទ្រព្យសម្បត្តិ ដើម្បីទឹកដី ដើម្បីអំណាច ឬភាសារ។ ជីហាទ ជាពាក្យអារ៉ាប់មកពីពាក្យ( ហ្ជា ហា ឌា )មានន័យថាព្យាយាម ឬតស៊ូប្រឆាំងនឹងអំពើអាក្រក់ដើម្បីភាពយុត្តិធម៌។ ជីហាទក្នុងសាសនាឥស្លាមមានន័យថា ការព្យាយាម តស៊ូប្រឆាំងនឹងទំនោរអាក្រក់ក្នុងចិត្ត។ ជីហាទក៏អាចប្រែបានថា ការតស៊ូព្យាយាមដើម្បីកែលម្អសង្គម។ ឬមានន័យថា ការប្រយុទ្ធប្រឆាំងនឹងការគាបសង្កត់ជិះជាន់។ ឬមានន័យថា ការតស៊ូដើម្បីការពារ

ខ្លួននៅក្នុងសមរភូមិ ដូច្នេះជាគោលការណ៍ ជីហាទមានន័យថា ការព្យាយាមនិងការតស៊ូប្រឆាំង។ ឧទាហរណ៍ដូចជា និស្សិតម្នាក់តស៊ូព្យាយាមដើម្បីយកជ័យជម្នះក្នុងការប្រលង។ យើងនិយាយក្នុងភាសារអារ៉ាប់ថា និស្សិតនោះបានជីហាទ មានមនុស្សភាគច្រើនគិតថា ជីហាទគឺសម្រាប់តែអ្នកមុស្លីមប៉ុណ្ណោះ។ មានឃ្លាជាច្រើននៅក្នុងគម្ពីរគួរអានជំពូកលុកម៉ានឃ្លាទី១៣-១៤មានន័យថា ហើយយើងបានផ្តាំមនុស្សលោកឲ្យធ្វើល្អចំពោះឪពុកម្តាយរបស់គេ ម្តាយរបស់គេបានពរពោះរូបគេដោយការលំបាកបន្ថែមពីលើការលំបាក់។ ឃ្លាបន្ទាប់ទៀតមានន័យថា ហើយប្រសិនបើគាត់ទាំងពីរជីហាត( ព្យាយាមជម្រុញ )ឲ្យអ្នកធ្វើអំពើពហុទេពនិយមជាមួយយើងនូវអ្វីដែលអ្នកមិនបានដឹងនោះ ចូរអ្នកកុំស្តាប់បង្គាប់ពួកគាត់ទាំងពីរឲ្យសោះ។ នៅទីនេះគម្ពីរគួរអានបានប្រាប់ថាឪពុកម្តាយដែលមិនមែនមុស្លីមបានជីហាទដើម្បីអោយកូនរបស់ពួកគាត់ធ្វើអំពើពហុទេពចំពោះព្រះអល់ឡោះ។ មានន័យថាគោរពព្រះផ្សេងពីព្រះអល់ឡោះ សារដដែលនៅជំពូកអាំងកាពូត ឃ្លាទី៨ ទ្រង់បានមានបន្ទូលថា ហើយយើងបានផ្តាំមនុស្សលោកឲ្យធ្វើល្អចំពោះឪពុកម្តាយរបស់គេ ហើយប្រសិនបើគាត់ទាំងពីរជីហាត់( ព្យាយាមជម្រុញ )ឲ្យអ្នកធ្វើអំពើពិហុទេពនិយមជាមួយនឹងយើងនូវអ្វីដែលអ្នកមិនបានដឹងនោះចូរអ្នកកុំស្តាប់តាមបង្គាប់ពួកគាត់ទាំងពីរឲ្យសោះ។ នៅទីនេះគម្ពីរគួរអានបានប្រាប់ថា ឪពុកម្តាយដែលមិនមែនជាមុស្លីមបានជីហាទ ហើយនៅ

មានឧទាហរណ៍ជាច្រើនទៀតក្នុងគម្ពីរគួរអាននិយាយអំពីជីហាទរបស់អ្នកមិនមែនមុស្លីម។ ហើយក្នុងភាសារអារ៉ាប់គេឲ្យឈ្មោះជីហាទប្រភេទនេះថា ជីហាទក្នុងផ្លូវសាយតន(បិសាច)។ ហើយអ្វីដែលអ្នកឥស្លាមត្រូវធ្វើគឺជីហាទក្នុងផ្លូវអល់ឡោះ។ ហើយនៅពេលដែលគេពោលពាក្យជីហាទតែឯកឯងនោះ គឺគេយល់ក្នុងឥស្លាមថាជីហាទក្នុងផ្លូវអល់ឡោះ។ មានអ្នកមិនមែនមុស្លីមភាគច្រើនព្រមទាំងអ្នកមុស្លីមមួយចំនួនទៀតបានអះអាងថាខ្លួនជាអ្នកប្រាជ្ញឥស្លាមបានបកប្រែពាក្យជីហាទថា(សង្គ្រាមសាសនា)ហើយនៅពេលយើងបកប្រែពាក្យthe holy war ទៅជាភាសារអារ៉ាប់មានន័យថា សង្គ្រាមសាសនា។ ប្រសិនបើអ្នកអានក្នុងគម្ពីគួរអាននិងហាទីសគឺពិតជាមិនឃើញមានពាក្យថាសង្គ្រាមសាសនានោះទេ។ ដូចខ្ញុំបាននិយាយអ៊ីចឹង ជីហាទមានន័យថា ការតស៊ូរ និងព្យាយាម។ ហើយជាប្រភេទនៃជីហាទដែរគឺការធ្វើសង្គ្រាមក្នុងផ្លូវអល់ឡោះ ប៉ុន្តែជីហាទពាក្យដើមរបស់វាមិនមែនមានន័យថា ធ្វើសង្គ្រាមនោះទេ។ ហើយនៅមានជីហាទច្រើនប្រភេទទៀត ដូចជាការតស៊ូរប្រឆាំងនិងទំនោរចិត្តអាក្រក់។ ហើយប្រភេទជីហាតផ្សេងទៀតគឺន័យ សង្គ្រាមដើម្បីការពារខ្លួនក្នុងផ្លូវអល់ឡោះ។ បើយើងក្រឡេកមើលប្រវត្តិរបស់ណាពីមូហាំម៉ាត់វិញ រយៈពេល១៣ឆ្នាំដែលគាត់រស់នៅទីក្រុងមាក្កះនៅពេលនោះមានអាយ៉ាត់ជាច្រើនបានបញ្ចុះមកលើគាត់ក្នុងនោះក៏មានពាក្យជីហាទជាច្រើន ប៉ុន្តែអ្នកឥស្លាមមិនបានធ្វើសង្គ្រាមឡើយនៅពេលនោះ

លើកលែងតែបន្ទាប់ពីពួកគាត់បានភៀសខ្លួនទៅម៉ាឌីន:។ នៅពេលនោះទើបចាប់ផ្ដើមមានសង្គ្រាម។ ក៏ប៉ុន្តែខណ:ដែលគាត់នៅមាក្ក:មានពាក្យជីហាទបានបញ្ចុះមកជាច្រើន។ ខ្ញុំអាចលើកឧទាហរណ៍ជាច្រើនដូចជានៅក្នុងគម្ពីរគួរអានសូរ៉ោះអាំងកាពូត៦៩មានន័យថា រីឯបណ្ដាអ្នកដែលបានតស៊ូក្នុងផ្លូវរបស់យើងវិញ យើងពិតជានឹងចង្អុលបង្ហាញផ្លូវរបស់យើងដល់ពួកគេជាមិនខាន។នៅពេលគេបញ្ចុះឃ្លានេះមកគឺពុំទាន់មានសង្គ្រាមនៅឡើយទេ។ ក្នុងគម្ពីគួរអានបានប្រាប់ក្នុងជំពូកហ្វួរកនឃ្លាទី៥២ ថា: ដូច្នេះចូរអ្នកកុំគោរពតាមពួកប្រឆាំង តែអ្នកត្រូវតស៊ូឲ្យបានខ្លាំងក្លាជាមួយពួកគេ ដើម្បីផ្សព្វផ្សាយវា(គម្ពីរគួរអាន) នេះមានន័យថា អ្នកតស៊ូដោយគម្ពីរគួរអាន ហើយតស៊ូដោយគម្ពីរគួរអានមានន័យថា ព្យាយាមផ្ដល់សាររបស់ព្រះឲ្យទៅមនុស្សលោក។ តើអ្នកគិតថាអ្នកធ្វើសង្គ្រាមដោយម្ពីគួរអានឬ? នៅទីនេះយើងយល់ថា ការយល់ខុសអំពីជីហាតគឺមូលហេតុមកពីប្រពន្ធផ្សព្វផ្សាយ ហើយពាក្យជីហាតមិនដែលមានបញ្ហាឡើយនៅសម័យមុន។ បន្ទាប់ពីព្រឹត្តិការណ៍១១កញ្ញារួចពាក្យនេះបានក្លាយជាប់លេខរៀងទីមួយក្នុងបញ្ជី ដែលមិនធ្លាប់មានពីមុនមក នេះក៏ដោយសារប្រពន្ធផ្សព្វផ្សាយបានបង្ហាញរូបភាពខុសអំពីឥស្លាម រហូតធ្វើឲ្យមនុស្សលោកមានការយល់ច្រឡំមកលើឥស្លាម។ ដើម្បីបញ្ជាក់កាន់តែច្បាស់ សូមស្ដាប់បទបង្ហាញរបស់ខ្ញុំអំពី(ភេរវកម្មនិងជីហាទក្នុងទស្សន:ឥស្លាម)។

# សំនួរទី២

## មុស្លីមជាពួកមូលវិវដ្ដនិយមនិងនិយមជ្រុល?

មុស្លីមជាពួកមូលវិវដ្ដនិយមនិងនិយមជ្រុល។ សម្រាប់រូបខ្ញុំ សំនួរទីពីរនេះជាសំនួរដែលល្បីសុសសាយច្រើនជាងគេ ក្នុងផ្នត់គំនិតអ្នកមិនមែនមុស្លីមវាគឺ (មុស្លីមនិយមជ្រុល)។ ហើយយើងជាមុស្លីមភាគច្រើនមានអារម្មណ៍ថា ជារឿងអាម៉ាស់ ហើយយើងមិនដឹងឆ្លើយតបនឹងគេយ៉ាងម៉េចចំពោះ (និយមជ្រុលនេះ)។ បុគ្គលមូលវិវដ្ឋនិយមមានន័យថា បុគ្គលដែលប្រកាន់តាមមូលដ្ឋានឬគោលការណ៍ណាមួយជាក់លាក់។ ឧទាហណ៍ថាៈ ប្រសិនបើបុគ្គលណាម្នាក់ចង់ចេះជំនាញផ្នែកខាងគណិតវិទ្យា ចាំបាច់ណាស់លើរូបគេត្រូវចេះត្រាប់តាម និងអនុវត្តរូបមន្ដគោលរបស់គណិតវិទ្យា។ ប្រសិនបើគេពុំមែនជាវ៉ាដីកាលលើជំនាញគណិតវិទ្យាទេ គេមិនអាចក្លាយជាអ្នកមានចំណេះដឹងទូលំទូលាយផ្នែកនេះឡើយ។ ដើម្បីក្លាយជាអ្នកប្រាជ្ញចំណាននោះ ចាំបាច់ត្រូវចេះ ត្រាប់តាម និងអនុវត្តតាមរូបមន្ដគោលនៃមុខវិជ្ជានោះ។ តែបើគេពុំមែនជាវ៉ាឌីកាលលើវិស័យមុខវិជ្ជានោះទេ គេមិនក្លាយជាអ្នកប្រាជ្ញចំណាននោះទេ។ យើងមិនអាចវាយតំលៃជាទូទៅថា រាល់អ្នកវ៉ាឌីកាលនិយមសុទ្ធតែល្អឬអាក្រក់នោះទេ។ តែយើងត្រូវពឹងផ្អែកលើវិស័យដែលគេក្លាយជាវ៉ាឌីកាល់និយមនោះ នៅពេលនោះគឺយើងអាចវាយតម្លៃថាគាត់ល្អឬអាក្រក់។ ប្រសិនបើ

ក្នុងសង្គមយើងមានចោរម្នាក់គាត់មានជំនាញ ដោយសារជំនាញគាត់ពូកែខាងលួច ដូច្នេះ គាត់ជាប្រភពនៃការបង្កផលលំបាកដល់សង្គម។ ក៏ប៉ុន្តែ ម្យ៉ាងវិញទៀត បើយើមានពេទ្យជំនាញម្នាក់ក្នុងការងាររបស់គាត់ដែលគាត់អាចសង្គ្រោះជីវិតរាប់ពាន់នាក់នោះវាជាការល្អសម្រាប់សង្គមវិញ។ ដូច្នេះ ដោយយោងទៅលើវិស័យដែលបុគ្គលម្នាក់ក្លាយជារ៉ាឌីកាល់និយម ទើបយើងអាចវាយតម្លៃបានត្រឹមត្រូវ។ ដរាបរឿងនេះទាក់ទងនិងខ្ញុំ ដូច្នេះខ្ញុំជាមុស្លីមរ៉ាឌីកាលនិយម ខ្ញុំពិតជាមានបមោទនភាព ពីព្រោះខ្ញុំស្គាល់ ខ្ញុំគ្រាប់តាម ហើយខ្ញុំនិងព្យាយាមអនុវត្តគ្រប់គោលការណ៍ឥស្លាមទាំងអស់។ ហើយខ្ញុំដឹងយ៉ាងច្បាស់ថា គ្មានគោលការណ៍ណាមួយរបស់សាសនាឥស្លាមគោលការដែលប្រឆាំងនឹងមនុស្សជាតិទ្បើយ។ ប្រហែលជាមានគោលការណ៍ខ្លះក្នុងសាសនាឥស្លាម ដែលអ្នកមិនមែនមុស្លីមគិតស្មានថាវាប្រឆាំងនឹងមនុស្សជាតិ។ ក៏ប៉ុន្តែនៅពេលដែលអ្នកឆ្លើយតបប្រាប់ពួកគេវិញនូវមូលហេតុដែលសមហេតុផលនៃគោលការណ៍ឥស្លាមទាំងនេះ។ គឺគ្មានបុគ្គលណាម្នាក់លើលោកនេះអាចដកស្រង់គោលការណ៍មួយក្នុងសាសនាឥស្លាមដែលប្រឆាំងនឹងមនុស្សជាតិ។ ប្រសិនបើយើងត្រទ្បប់ទៅមើលប្រវត្តិសាស្ត្រ យើងនឹងដឹងថា វាត្រូវម៉ាច់នឹងវចនានុក្រមវីពិសទ័របានបញ្ជាក់ថាៈ ពាក្យថា(មូលវិវដ្តនិយម) គេប្រើដំបូងបង្អស់ដើម្បីពិព័ណ៌នាក្រុមមួយនៃជនជាតិអាមេរិកកាន់គ្រិស្តសាសនា នាយុគសម័យដំបូងគេនៃសតវត្សរ៍ទី២១។ ពួកគ្រិស្ត

សាសនិកជនជាតិអាមេរិកទាំងនោះបានតវ៉ាប្រឆាំងនឹងវិហារគ្រិស្ត ហើយពួកគេបាននិយាយថាៈ វិហារគ្រិស្តពីដើមមានជំនឿថា គម្ពីរបាយបលទាំងមូលគឺមកពីព្រះជាម្ចាស់។ ពួកគ្រិស្តសាសនិកប្រូតេស្តង់បានតវ៉ាប្រឆាំងនឹងវិហារគ្រិស្ត ហើយបាននិយាយថាៈ ពុំមែនត្រឹមតែគម្ពីរបាយបលប៉ុណ្ណោះទេ ដែលមកពីព្រះជាម្ចាស់ តាមពិតរាល់ពាក្យពេចន៍ និងរាល់ឃ្លាឃ្លោងក្នុងគម្ពីនេះក៏មកពីព្រះដែរ។ ប្រសិនបើក្នុងចំណោមពួកគេមានម្នាក់ទទួលស្គាល់ថា រាល់អក្សរ ពាក្យពេចន៍ និងឃ្លាឃ្លោងក្នុងគម្ពីរបាយបលមកពីព្រះដ៏មានអានុភាពនោះ ដូច្នេះចលនានេះគឺជាចលនាមួយដ៏ល្អ។ ម្យ៉ាងវិញទៀត ប្រសិនបើមានបុគ្គលណាម្នាក់ទទួលស្គាល់ថា រាល់អក្សរ ពាក្យពេចន៍ និងឃ្លាឃ្លោងក្នុងគម្ពីរបាយបលមិនមែនមកពីព្រះនោះ គឺគេចាត់ទុកថា ជាចលនាដែលមិនល្អ។ នៅពេលយើងអានវចនានុក្រម Oxford វាបានបកស្រាយថាៈ (មូលវិវដ្ដនិយម ឬ ហ៊្វាឌីកាល់និយម គឺបុគ្គលដែលប្ដេជ្ញាចិត្តការកាន់តាមបទបញ្ញត្តិចាស់ និងគម្ពីរពិសិដ្ឋដែលពិសេសទោះក្នុងសាសនាណាក៏ដោយ)។ ក៏ប៉ុន្តែបើយើងមើលច្បាប់ថ្មីបន្ទាប់ពីបានកែសំរួលរួចក្នុងវចនានុក្រម Oxford យើងនឹងឃើញមានការខុសគ្នាបន្តិច ដោយបានបក្រសាយថាៈ(ហ៊្វាឌីកាល់និយម គឺបុគ្គលដែលបានប្ដេជ្ញាចិត្តយ៉ាងកាន់ខ្ជាប់នឹងបទបញ្ញត្តចាស់និងគម្ពីរពិសិដ្ឋដែលពិសេសទោះក្នុងសាសនាណាមួយ ជាពិសេស សាសនាឥស្លាម)។ គេបានបញ្ចូលពាក្យ ជាពិសេសឥស្លាមទៅ

ក្នុងវចនានុក្រម Oxford ច្បាប់ដែលគេកែសំរួលរួច។ នៅពេលអ្នកបានឮពាក្យថា រ៉ាឌីកាល់និយម ភ្លាមៗ អ្នកពិតជាគិតថា មុស្លីម។ មូស្លីមជាពួករ៉ាឌីកាល់និយមនិងនិងនិយមជ្រុល។ ផ្ទុយទៅវិញ យើងជាមុស្លីម យើងនិយាយថា ទេ!ពួកយើងមិនមែន រ៉ាឌីកាល់និយម ហើយក៏មិននិយមជ្រុលដែរ។ ខ្ញុំថា ខ្ញុំជ្រុលនិយម។ ខ្ញុំតឹងរឹងចំពោះសច្ចភាព តឹងរឹងចំពោះភាពយុត្តិធម៌ តឹងរឹងចំពោះការអាណិតអាសូរ តឹងរឹងចំពោះក្តីមេត្តា និងតឹងរឹងចំពោះក្តីស្រលាញ់។ តើនរណាម្នាក់អាចប្រាប់ខ្ញុំបានទេថា ហេតុអ្វីបានជាខ្ញុំតឹងរឹងចំពោះសច្ចភាព តឹងរឹងចំពោះភាពយុត្តិធម៌ តឹងរឹងចំពោះការអាណិតអាសូរ តឹងរឹងចំពោះក្តីមេត្តា និងតឹងរឹងចំពោះក្តីស្រលាញ់? តើខ្ញុំខុសអ្វី ដែលខ្ញុំតឹងរឹងចំពោះរឿងនេះ? គម្ពីរគួរអានបានប្រាប់ថា អ្នកត្រូវតែតឹងរឹងចំពោះសច្ចភាព អ្នកមិនអាចមានសច្ចភាពតែមួយផ្នែកនោះទេ ពេលមានផលប្រយោជន៍ ទើបមានសច្ចៈ បើសគ្មានផលប្រយោជន៍គ្មានសច្ចៈ គម្ពីរគួរអានបានប្រាប់ថា អ្នកត្រូវតែតឹងរឹងចំពោះពាក្យសច្ចៈនិងយុត្តិធម៌។ ដូច្នេះប្រសិនបើអ្នកកាន់តាមឥស្លាមអ្នកត្រូវតែតឹងរឹងចំពោះការអាណិតស្រលាញ់ សច្ចភាព និងយុត្តិធម៌។ អ្នកត្រូវតឹងរឹងចំពោះផ្លូវឆ្ពោះទៅរកភាពត្រឹមត្រូវ។ មិនមែនតឹងរឹងចំពោះផ្លូវខុសនោះទេ។ ប៉ុន្តែអ្នកមុស្លីមត្រូវតែតឹងរឹងក្នុងការប្រតិបត្តិតាមគម្ពីគួរអាន។ អល់ឡោះទ្រង់មានបន្ទូលក្នុងគម្ពីគួរអានជំពូកទី២/២០៨មានន័យថាៈ ចូរពួកអ្នកចូលសាសនាឥស្លាមដោយទាំងស្រុង៕ មានន័យថា ចូរពួកអ្នកអនុ

វត្តឥស្លាមទាំងស្រុង មិនមែនអនុវត្តមួយផ្នែកនោះទេ។ ដូច្នេះ ហេតុអ្វីអ្នកមូស្លីមចេះតែពាក្យដោះសារអ៊ីចឹង។ បណ្ដាញសារព័ត៌មានបានធ្វើការវាយប្រហារមកលើឥស្លាម តែគួរឱ្យសោកស្ដាយយើងជាមុស្លីម។ ដ្បិតតែយើងកាន់សាសនាដ៏ល្អប្រសើបំផុត ក៏ប៉ុន្តែហេតុអ្វីខ្លាច ហើយយើងដោះសារ ឥឡូវដល់ម៉ោងដែលយើងត្រូវលាតត្រដាងការពិតហើយ។

# សំនួរទី៣

# តើពួកអ្នកមូស្លីមជាភេរវករឬ?

បន្ទាប់ពីហេតុការណ៍ថ្ងៃទី១១ខែកញ្ញា ក៏មានហេតុការណ៍ផ្សេងទៀតគឺការបំផ្ទុះគ្រាប់បែកនៅទីក្រុងឡុងដ៍ថ្ងៃទី០៧ ខែកក្កដា។ ហើយមានពាក្យមួយដែលគេនិយាយថា ពួកអ្នកមុស្លីមមិនមែនជាភេរវករទេ ប៉ុន្តែរាល់ភេរវករទាំងអស់សុទ្ធតែជាអ្នកមុស្លីម។ ពាក្យនេះឮសុសសាយក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលធ្វើឱ្យខ្ញុំផ្តល់ប្រធានបទថ្មីមួយមានចំណងជើងថា តើភេរវកម្មជាអំពើផ្តាច់មុខរបស់អ្នកមុស្លីមឬ ? គ្មានពេលវេលាទូលាយាគ្រប់គ្រាន់ដើម្បីនិយាយពិស្តារ (តើភេរវកម្មជាអំពើផ្តាច់មុខរបស់អ្នកមុស្លីមឬ? ) ក៏ប៉ុន្តែពួកអ្នកអាចតាមដានទស្សនាបានតាមរយៈប៉ុស្ត៍សាឡាម ឬតាមគេហទំព័រ ពួកយើងដឹងថាប្រព័នផ្សព្វផ្សាយបានចាក់ផ្សាយជាច្រើនដង ហៅឈ្មោះពីរផ្សេងគ្នាសម្រាប់បុគ្គលតែម្នាក់ និងសកម្មភាពតែមួយរបស់គេ។ ឧទាហរណ៍ កាលពីជាង៦០ឆ្នាំងមុន មានជនឥណ្ឌាជាច្រើនបានប្រយុទ្ធធ្វើសង្គ្រាមដើម្បីសិទ្ធិសេរីភាពប្រទេសរបស់ពួកគេ គេបានឱ្យឈ្មោះពួកនេះថាភេរវករ ដោយរដ្ឋាភិបាលអង់គ្លេស។ ក៏ប៉ុន្តែពួកយើងហៅពួកគេថាជាប្រជាជនឥណ្ឌាសាមញ្ញ ពួកយើងបហៅពួកគេថា អ្នកកាពារសិទ្ធិសេរីភាព និងអ្នកជាតិនិយម។ ជាបុគ្គលតែមួយ ជាសកម្មភាពតែមួយ ក៏ប៉ុន្តែដោយការហៅឈ្មោះពីរផ្សេងគ្នា

ប្រសិនបើអ្នកគាំទ្ររដ្ឋាភិបាលអង់គ្លេសថា ពួកគេមានសិទ្ធគ្រប់គ្រង ឥណ្ឌា អ៊ីចឹង អ្នកចាំបាច់ហៅពួកអ្នកទាំងនោះថា ជាភេរវះករ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកគាំទ្រប្រជាជនឥណ្ឌាសាមញ្ញ ហើយពួកអង់គ្លេសមកដើម្បី រកផលប្រយោជន៍ផ្ទាល់ខ្លួន ហើយពួកគេគ្មានសិទ្ធិគ្រប់គ្រងប្រទេស ឥណ្ឌាទេនោះ អ៊ីចឹងអ្នកចាំបាច់ហៅបុគ្គលទាំងនោះថា ជាអ្នកជាតិនិយម ឬពួកអ្នកប្រយុទ្ធដើម្បីសិទ្ធិសេរីភាព។ ចូរសង្កេត បុគ្គលតែម្នាក់ សកម្មភាពតែមួយ ក៏ប៉ុន្តែមានងារផ្សេងគ្នា។ ហើយជាច្រើនដង ដែលខ្ញុំ ជួបសម្ភាសជាមួយសារព័ត៌មាន ហើយក្នុងពេលកំពុងសម្ភាសជាមួយ កាសែតឥណ្ឌា ខ្ញុំបានសួរពួកគេនូវសំនួរមួយ តើពួកអ្នកចាត់ទុក្ខលោក ហាំហ្គាតសាំងជាភេរវករឬ? គេបាននិយាយថា ទេ ! ហេតុអ្វី? សារ ព័ត៌មានលោកខាងលិចក៏ដូចគ្នាដែរ នៅពេលគេនិយាយពីគាត់ថាជាភេ វរករ ហេតុអ្វី? សារព័ត៌មានលោកខាងលិចក៏ដូចគ្នាដែរ នៅពេលគេ និយាយពីគាត់ថាជាភេរវករ។ ហេតុអ្វីបានជាលោកបដិសេធថាគាត់មិន មែនជាភេរវករ? ពីព្រោះលោកបានដឹងពីប្រវត្តសាស្ត្រពិតដែពាក់ព័ន្ធនឹ ការទទួលបានសិទ្ធិសេរីភាពរបស់ប្រទេសឥណ្ឌា។ សូម្បីតែខ្ញុំក៏មិនបាន ចាត់ទុក្ខលោកហាំហ្គាតសាំងជាភេរវករដែរ។ ក៏ប៉ុន្តែសារព័ត៌មានលោក ខាងលិចដដែលនឹង សព្វថ្ងៃនេះ នៅពេលគេដាក់ងារពួកអ្នកមុស្លីមថាជា ភេរវករ ហេតុអ្វីបានជាអ្នកឯកភាពចំពោះរឿងនេះ។ តើអ្នកបានសិក្សា ស្រាវជ្រាវដែឬទេ!!!( ពួកគេចាប់ផ្តើមអស់សំណើច ) គម្ពីរគួរអាន

និយាយក្នុងជំពូកទី៤៩ អាល់ហ៊ូជូរ៉ត ឃ្លាទី៦ : ((នៃពួកអ្នកដែលមានជំនឿទាំងឡាយ! ប្រសិនបើមានមនុស្សខិលខូចណាម្នាក់នាំដំណឹងអ្វីមួយមកប្រាប់ពួកអ្នក ចូរពួកអ្នកពិនិត្យឱ្យបានច្បាស់លាស់ ))។ ចំនុចដែលត្រូវចាប់អារម្មណ៍ គឺនៅពេលដែលរដ្ឋាភិបាលអង់គ្លេស បានដាក់ងារលោកបះហ្គុតសាំងជាភេរវករគឺ អ្នកមិនឯកភាពនោះទេ ឥឡូវនេះហេតុអ្វីបានជាអ្នកឯកភាពជាមួយពួកគេចំពោះគំនិតនេះ? ហេតុអ្វីមានចិត្តវៀចវេរចំពោះគំនិតនេះ? ហើយនៅមានឧទាហរណ៍គំរូជាច្រើនទៀតក្នុងរឿងនេះ នៅពេលយើងអានប្រវត្តិបដិវត្តន៍របស់អាមេរិកនៅឆ្នាំ១៧៧៥ អំឡុងពេលបដិវត្តន៍របស់អាមេរិក លោកGeorge Washington ត្រូវបានគេហៅគាត់ថាជាភេរវករលំដាប់លេខ១ ដោយរដ្ឋាភិបាលអង់គ្លេសក្នុងអំឡុងកំឡុងពេលនៃការត្រួតត្រារបស់ខ្លួនលើអាមេរិក។ រដ្ឋាភិបានអង់គ្លេសបានហៅលោកGeorge Washington ថាជាភេរវករលំដាប់លេខ១ បន្ទាប់មក នៅពេលអាមេរិកទទួលបានឯករាជ្យ ក៏បានលើកGeorge Washingtonជាប្រធានាធិបតីរបស់ខ្លួន។ ចូរគិតស្រមៃមើល ភេរវករលំដាប់លេខ១បានក្លាយជាប្រធានាធិបតីសហរដ្ឋអាមេរិក។ ហើយគាត់បានក្លាយជាវរបិតាដួងព្រលឹងសម្រាប់មេដឹកនាំអាមេរិកទាំងឡាយដែលមកបន្ទាប់ពីគាត់ ហើយសូម្បីតែ George Bush ហើយអ្នកនៅមានឧទាហរណ៍ជាច្រើនទៀត យើងមានឧទាហរណ៍ដូចជាលោក Nelson Mandela Nelson Mandela កាលពីប៉ុន្មានទសវត្សមុន

នៅពេលភាគខាងត្បូងអាហ្វ្រិកស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលស្បែកស គេបានចាប់ឃុំឃាំងលោក Nelson Mandela ហើយដាក់គុកគាត់នៅលើកោះរ៉ូបឹនអស់រយៈពេល២៥ឆ្នាំ។ ហើយរដ្ឋាភិបាលស្បែកសបានហៅគាត់ថាជាភេរវករលំដាប់លេខមួយ បន្ទាប់ពីខាងត្បូងអាហ្វ្រិកទទួលបានឯករាជ្យ លោកNelson Mandela បានទទួលពានរង្វាន់នូបេលសន្តិភាព។ ចូរគិតស្រមៃមើល ភេរវករលំដាប់លេខមួយបែរជាទទួលបានពានរង្វាន់នូបេលសន្តិភាពទៅវិញ មិនមែនពីមុនគាត់ជាមនុស្សអាក្រក់ទេ ហើយបន្ទាប់មកបានក្លាយជាមនុស្សល្អនោះទេ ក៏ប៉ុន្តែវាជាសកម្មភាព តែមួយដែលគេដាក់ឈ្មោះថាជាភេរវករដោយសារសកម្មភាពនោះ។ បន្ទាប់ពី៣០ឆ្នាំក្រោយ គាត់ទទួលបានពានរង្វាន់នូបេលសន្តិភាព ដោយសារតែសកម្មភាពតែមួយ ដែលគាត់បានធ្វើវាពីមុន។ ដូច្នេះយើងអាចសន្និដ្ឋានបានថា នៅពេលណាអ្នកមានអំណាចដាក់លក្ខណៈអ្វីមួយឱ្យបុគ្គលម្នាក់ គឺអ្នកលក្ខណៈនោះឱតជាប់នឹងបុគ្គលនោះ។ នេះគឺចាសារព័ត៌មាន វាមានអំណាចខ្លាំងមែនទែន តាមគំនិតខ្ញុំ ជាអាវុធដ៏សំខាន់បំផុតនៅក្នុងពិភពលោកសព្វថ្ងៃនេះ។ ដោយសារវាអាចប្តូរខ្មៅទៅជាស ថ្ងៃទៅជាយប់ វីរជនទៅជាឧក្រិដ្ឋជន ហើយឧក្រិដ្ឋជនទៅជាវីរជន។ គួរឱ្យសោកស្តាយ ពួកយើងជាអ្នកមុស្លីមនៅអន់ថយខ្លាំងមែនទែក្នុងវិស័យសារព័ត៌មាននេះ។ បច្ចេកវិទ្យារបស់ពួកយើង ដូចជាយើងបានដឹងហើយថាបច្ចេកវិទ្យា ជារឿងស្របច្បាប់ បើសិនជាគេប្រើវាដើម្បីស្តាប់

អាល់គួរអាន និងប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ គឺចាំបាច់ត្រូវតែប្រើវា។ ចាំបាច់យើងត្រូវបង្វែរវាទៅលើវិស័យដែលហាឡាល មើលទូរទស្សន៍មិនហារ៉ាមទេ ខ្ញុំជឿថា ៩៩%អ្វីដែលគេចាក់ផ្សាយតាមទូរទស្សន៍ជាប្រកាហារ៉ាម ក៏ប៉ុន្តែយើងត្រូវប្តូរពីហារ៉ាមទៅជាហាឡាលវិញ អ៊ីចឹងឯង យើងចាំបាច់ត្រូវពាំនាំសាររបសអល់ឡោះ វិធីសាស្រ្តដែលល្អបំផុត សព្វថ្ងៃនេះ ដើម្បីផ្សព្វផ្សាយសាររបស់អល់ឡោះគឺតាមរយៈប្រព័ន្ធផ្កាយរណប ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាដើម។ យ៉ាងហោចណាស់ពួកយើងអាចនិយាយទៅកាន់អល់ឡោះនៅថ្ងៃបរលោកថា ពួកយើងបានធ្វើតាមលទ្ធភាពរបស់ពួកយើង។ ដើម្បីធ្វើឱ្យសារឥស្លាមទៅដល់គ្រប់ផ្ទះទាំងអស់។ ឬយ៉ាងហោចណាស់ ដល់ផ្ទះមួយភាគធំដែលអាចទៅរួច។ សូមសរសើរដឹងគុណចំពោះអល់ឡោះ មានរយៈពេល៣០ឆ្នាំកន្លះហើយ តាំងពីចាប់ផ្តើមចាក់ផ្សាយប៉ុស្ត៍សាឡាម ឥឡូវនេះ ទស្សនិកជនប៉ុស្ត៍សាឡាមមានចំនួនច្រើនជាងមួយរយលាននាក់។ ប្រហែលមានគេសួរថា ហេតុអ្វីមានកាមេរ៉ាច្រើនម្លេះ មនុស្សនាំគ្នានិយាយថា ហេតុអ្វីមាន១២កាមេរ៉ា សម្រាប់មនុស្សម្នាក់ និងបទបង្ហាញមួយមាន១២កាមេរ៉ា បុរសម្នាក់មាន១២កាមេរ៉ា ប៉ុស្ត៍ទូរទស្សន៍បាននិយាយថា ពួកយើងប្រើកាមេរ៉ា២ឬ៣តែប៉ុណ្ណោះ មាន១២កាមេរ៉ា ពីព្រោះពួកយើងចង់បង្ហាញឥស្លាមតាមវិធីសាស្រ្តមួយល្អបំផុត ប៉ុន្តែនៅពេលអ្នកផ្សព្វផ្សាយសាសនាធ្វើបទបង្ហាញ ហេតុអ្វីមានកាមេរ៉ាតែ២

ប៉ុណ្ណោះ? សម័យឥឡូវជាសម័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើប នៅពេលអ្នកចង់បញ្ចុះបញ្ចូលយុវជន ប្រព័ន្ធផ្សព្វផ្សាយបាននាំពួកគេទៅរកផ្លូវខុស ពួកយើងចាំបាច់ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដដែលដើម្បីធ្វើឱ្យយុវជនពួកយើងដើរផ្លូវត្រឹមត្រូវ ពីផ្លូវខុសទៅរកផ្លូវត្រឹមត្រូវ ជឿខ្ញុំចុះ ពួកយើងដឹង ខ្ញុំឯកភាពជាមួយពួកអ្នកថា ប្រព័ន្ធផ្សព្វផ្សាយភាគច្រើនចាក់ផ្សាយប្រកាដែលហារ៉ាម។ ក៏ប៉ុន្តែ ដរាបណាពួកយើងមិនប្រឆាំងនិងច្បាប់ស្ហារីអាត់ដែលមានចែងក្នុងគម្ពីគួរអាន និងប្រសាសន៍មូហាំម៉ាត់ដែលត្រឹមត្រូវទេនោះ ពួកយើងអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនេះជាផលប្រយោជន៍ដើម្បីផ្សព្វផ្សាយឥស្លាម។

# សំនួរទី៨

# ឥស្លាមរីកសុសសាយដោយផ្លែដាវ?

ការយល់ខុសក្នុងគំនិតអ្នកមិនមែនមូស្លីម គឺ(ឥស្លាមរីកសុសសាយដោយផ្លែដាវ) តើពាក្យ”ឥស្លាម” មានន័យដូចម្តេច? ឥស្លាម មកពីពាក្យ សាលាម ដែលមាន័យជាភាសាខ្មែរថា (សន្តិភាព ) ។ ហើយពាក្យនេះកម្លាយចេញពីពាក្យ សាឡាម មានន័យថា ( ដាក់បំណងប្រាថ្នារបស់អ្នកនៅក្រោមរណបឬបង្គាប់អល់ឡោះ ) ដោយសង្ខេបឥស្លាម មានន័យថា សន្តិភាពដែលកើតឡើងដោយបំណងប្រាថ្នារបស់អ្នកស្តាប់បង្គាប់តាមអល់ឡោះជាម្ចាស់ ។ ដូច្នេះ ពាក្យថា ឥស្លាមរីកសុសសាយដោយផ្លែដាវ មានន័យថា “សន្តិភាពរីកសុសសាយដោយផ្លែដាវ” ដែលមានភាពផ្ទុយគ្នាស្រឡះ។ តើវាអាចទៅរួចទេ ដែលសន្តិភាពរីកសុសសាយដោយផ្លែដាវនោះ? ពួកយើងដឹងថាមិនមែនបុគ្គលគ្រប់រូបលើសកលលោកសុទ្ធតែពេញចិត្តចង់ឱ្យសន្តិភាពឈ្នះនោះទេ។ ឥស្លាមជាសាសនាសន្តិភាព គោលបំណងគ្រឹះរបស់ខ្លួនគឺផ្សព្វផ្សាយសន្តិភាព។ ក៏ប៉ុន្តែមិនមែនបុគ្គលគ្រប់រូបនៅលើពិភពលោកនេះសុទ្ធតែចង់សន្តិភាពគ្រប់ដណ្តប់ទូទៅនោះទេ។ ដូច្នេះទើបប្រទេសនីមួយៗមានកម្លាំងនគរបាល ឬប៉ូលីស។ កម្លាំងទាំងនេះជួនកាលភាគច្រើនគេប្រើដើម្បីរក្សាសន្តិភាពក្នុងប្រទេសនោះ។ ពួកគេមិនប្រើកម្លាំងទាំងនោះដើម្បីរាំង

ស្ទះសន្តិភាពនោះទេ ក៏ប៉ុន្តែបើសិនជាពួកជនទុច្ចរិតចង់បង្កឧបសគ្គដល់សន្តិភាព។ កងកម្លាំងប៉ូលីសគ្រប់ប្រទេសទាំងអស់ប្រើកម្លាំងដើម្បីរក្សាសន្តិភាពនៅក្នុងប្រទេសទាំងនោះ។ ដូចគ្នាដែរក្នុងសាសនាឥស្លាម។ ឥស្លាមប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការកាប់សម្លាប់ ប្រឆាំងនឹងការប្រើកម្លាំងអំណាច លើកលេងតែជាដំណោះស្រាយចុងក្រោយដើម្បីរក្សាសន្តិភាព។ ដូច្នោះដែរឥស្លាមអនុញ្ញាត្តិឱ្យប្រើកម្លាំងដើម្បីការពារយុត្តិធម៌ និងរក្សាសន្តិភាពនៅលើទឹកដីនោះ។ ការឆ្លើយតបដ៏ល្អប្រសើរបំផុតសម្រាប់ការចោទប្រកាន់ថា ឥស្លាមរីកសុសសាយដោយផ្លែដាវ គឺសម្អាងលើសំដីរបស់ប្រវត្តិវិទូដ៏ល្បីល្បាញ លោក តាលីសី អូលីរី ក្នុងសៀវភៅរបស់លោក (ឥស្លាមស្ថិតនៅលើផ្លូវបំបែក) ទំព័រទី៨ ។ ប្រវត្តិសាស្រ្តវាបានបកស្រាយពីព្រេងនិទានដែលថា ឥស្លាមរីកសុសសាយក្នុងពិភកលោកហើយបង្ខិតបង្ខំមនុស្សឱ្យចូលឥស្លាមដោយកម្លាំងអាវុធ និងសង្គ្រាម។ នេះគឺជារឿងប្រឌិត ដែលមានកំហុសធ្ងន់ធ្ងរបំផុតដែលប្រវត្តិសស្រ្តប្រព្រឹត្តិដដែលៗ។ ខ្ញុំនឹងនិយាយម្តងទៀតនូវសំដីរបស់ប្រវត្តិវិទូដ៏ល្បីល្បាញ លោក លីសីអូលីរី ក្នុងសៀវភៅរបស់លោក (ឥស្លាមស្ថិតនៅលើផ្លូវបំបែក) ទំព័រទី៨ ។ ប្រវត្តិសាស្រ្តវាបានបកស្រាយពីព្រេងនិទានដែលថា ឥស្លាមរីកសុសសាយក្នុងពិភកលោកហើយបង្ខិតបង្ខំមនុស្សឱ្យចូលឥស្លាមដោយកម្លាំងអាវុធ និងសង្គ្រាម។ នេះគឺជារឿងប្រឌិត ដែលមានកំហុសធ្ងន់ធ្ងរបំផុតដែលប្រវត្តិសស្រ្តប្រព្រឹត្តិដដែលៗ។ តើផ្លែដាវ

ស្អី? ពួកយើងមូស្លីមទាំងអស់បានគ្រប់គ្រងប្រទេស អេស្ប៉ាញ អស់រយៈកាល៨០០ឆ្នាំ ក៏ប៉ុន្តែពួកយើងមិនបានបំពេញភារកិច្ចនេះ។ យើងមិនបានផ្សព្វផ្សាយសាសនាឥស្លាមដល់អ្នកមិនមែនមូស្លិម។ បន្ទាប់មកបេសកម្មឈើឆ្កាងនៃសាសនា គ្រិស្ទានបានមកដល់ គ្មានមូស្លីមណាម្នាក់អាចអាចធ្វើសូម្បីតែការប្រកាសប្រាប់មនុស្សថាដល់ម៉ោងថ្វាយបង្គំ ក៏មិនបានផល។ ប្រសិនបើអ្នកអានប្រវត្តិសាស្រ្ត ។ សាសនាដែលរីកសុសសាយដោយប្រើកម្លាំងនោះគឺសាសនាគ្រិស្ទាន។ ប្រសិនបើអ្នកអានប្រវត្តិសាស្រ្ត រាប់រយពាន់នាក់ត្រូវបានសម្លាប់ដោយអ្នកកាន់សាសនាគ្រិស្ទាន។ សព្វថ្ងៃនេះមនុស្សដដែល ដែលកាន់សាសនាគ្រិស្ទាននិយាយថា ឥស្លាមរីកសុសសាយដោយសាផ្លែដាវ។ ពិតណាស់ពួកអ្នកមូស្លីមបានគ្រប់គ្រងទឹកដីអារ៉ាប់១៤០០ឆ្នាំកន្លងមក។ ជាទូទៅរយៈពេលប៉ុន្មានឆ្នាំប៉ុណ្ណោះនៃគ្រប់គ្រងរបស់អង់គ្លេស និងបារាំង។ ពីដើមពួអ្នកមូស្លីមគ្រប់គ្រងទឹកដីអារ៉ាប់រយៈកាល១៤០០ឆ្នាំ។ ទោះជាអ៊ីចឹងក៏ដោយសព្វថ្ងៃនេះមានជនជាតិអារ៉ាប់អេស៊ិបកាន់គ្រិស្ទានចំនួន១៤លាននាក់ ។ អារ៉ាប់អេស៊ិបកាន់គ្រិស្ទានមានន័យថា កាន់ពីតាំងរាប់សិបជំនាន់។ ពូកអេស៊ិបកាន់គ្រស្ទាន១៤លាននាក់នេះគឺជាសាក្សីរស់ដ៏ប្រសើរបំផុតបញ្ជាក់ថា ឥស្លាមមិនរីកសុសសាយដោយសារផ្លែដាវនោះទេ ។ ពិតណាស់ពូកយើងជាមូស្លីមបានគ្រប់គ្រងប្រទេសឥណ្ឌាជាងមួយពាន់ឆ្នាំ ។ ប្រសិនបើពូកយើងចង់ ពូកយើងនឹងប្រើដាវដើម្បីផ្លាស់ប្តូរជនជាតិ

ឥណ្ឌាឱ្យចូលឥស្លាម ក៏ប៉ុន្តែពួកយើងមិនធ្វើដូច្នោះទេ។ សព្វថ្ងៃមានប្រជាជនឥណ្ឌាជាង៨០% មិនមែនជាមូស្លីម ហើយពួកគេជាសាក្សីរស់ដ៏ប្រសើរបំផុត បញ្ជាក់ថា ឥស្លាមមិនរីកសុសសាយដោយសារផ្លែដាវនោះទេ។ សព្វថ្ងៃនេះប្រទេសដែលមានអ្នកមូស្លិមច្រើនជាងគេគឺប្រទេសឥណ្ឌូនេស៊ី តើមានទាហានឥស្លាមណាមួយបានទៅកាន់ទីនោះ? តើទាហានឥស្លាមណាមួយដែលបានទៅកាន់ប្រទេសម៉ាឡេស៊ី ? ដែលមានពលរដ្ឋជាអ្នកមូស្លីមជាង៥០% ។ តើទាហានឥស្លាមណាមួយដែលបានទៅកាន់ឆ្នេរអាហ្វ្រិកខាងជើង? ហើយអាវុធណាមួយ? ប្រវត្តិវិទូជនអឺរ៉ុបដ៏ល្បីល្បាញម្នាក់ លោក តូម៉ាសការឡេលបានឆ្លើយតបមកពួកយើងថា គាត់បានចាត់ទុកព្យាការីមូហាំម៉ាត់ជាវីរជន “ Heroes Hero-worship” ក្នុងសៀវភៅរបស់លោក លោកបាននិយាយថា គាត់បាននិយាយក្នុងសៀវភៅនេះថា តើដាវណាមួយ?ដំបូងអ្នកត្រូវរកឱ្យឃើញដាវរបស់អ្នកសិន ។ តើដាវមួយណា? ដំបូងគាត់ត្រូវរកឱ្យឃើញដាវសិន។ គឺរាល់គំនិតថ្មីដែលមានក្នុងខួរក្បាលខ្លួនឯង។ ក្នុងខួក្បាលបុរសណាម្នាក់ គិតតែម្នាក់ឯង បុរសម្នាក់ប្រឈមមុខនឹងពិភពលោកទាំងមូល។ វាមិនទទួលបានផលច្រើនទេ ប្រសិនបើគាត់កាន់ដាវ និងតម្រូវឱ្យប្រើវានោះ ចាំបាច់អ្នកត្រូវរកដាវរបស់អ្នកឱ្យឃើញសិន គង់មានន័យថាដាវប្រាជ្ញា ។ តើដាវមួយណាដែលធ្វើឱ្យមនុស្សរាប់រយពាន់នាក់ចូលឥស្លាម ? ពិតណាស់គាត់និយាយអំពីដាវប្រាជ្ញា។ ពិតណាស់បទបង្ហាញ

របស់ខ្ញុំចាប់ផ្ដើមពីគម្ពីរគួរអាន ចាប់ពីជំពូក អាន់ណាហល៍ភាគទី១៦ វាក្យខណ្ឌលេខ ១២៥ អល់ឡោះបានមានបន្ទូល : ចូរអ្នក( ព្យាការីមូហាំម៉ាត់ )អំពាវនាវ( មនុស្សលោក )ទៅកាន់មាគ៌ាព្រះម្ចាស់របស់អ្នក ដោយគតិបណ្ឌិត និងពាក្យទូន្មានដែលល្អពីរោះ ហើយជជែកជាមួយពួកគេនឹងអ្វីដែលប្រសើរបំផុត។ ចូរអ្នក( ព្យាការីមូហាំម៉ាត់ )អំពាវនាវ មនុស្សលោក ទៅកាន់សាសនាឥស្លាម ហើយចូរជជែកជាមួយពួកគេ ដោយគតិបណ្ឌិត និងកុសលធម៌។ ពិតណាស់វាជាដាវតក្កភាពប្រើប្រាជ្ញាគតិបណ្ឌិតដែលចាប់យកចិត្តមនុស្ស។ ពុំមែនជាដាវដែក ទោះបីវានៅនឹងដៃពួកយើងក៏ដោយ ក៏ពួកយើងមិនអាចប្រើវាបានដែរ ព្រោះគួរអានបាននិយាយក្នុងជំពូកអាល់ពរការ៉ស់ភាគ២ វាក្យខណ្ឌលេខ ២៥៦ គ្មានការបង្ខិតបង្ខំឡើយក្នុងសាសនាឥស្លាម។ មានន័យថា គ្មានការបង្ខិតបង្ខំឱ្យកាន់តាមសាសនាឥស្លាមឡើយ។ ប្រាកដណាស់ផ្លូវពិតបានញែកដាច់ពីផ្លូវវង្វេង ។ លោកតូម៉ាសការឡេល និយាយពីដាវប្រាជ្ញា ។ ដាវតក្កវិជ្ជា(សមហេតុផល) ៕ មានការសិក្សាស្រាវជ្រាវមួយដែលបានធ្វើឡើង ហើយចុះផ្សាយនៅឆ្នាំ១៩៨៤ក្នុងសៀវភៅដែលមានឈ្មោះថា Reader’s Digest “ Almanac “ year book “ ហើយក៏បានចុះផ្សាយដែរក្នុងទស្សនាវដ្ដី សច្ចភាពសុទ្ធសាធ “ The Plan truth “ ពិតណាស់ការសិក្សាស្ដីពីការីកសុសសាយសាសនាធំៗនៅលើពិភពលោកក្នុងអំឡុងពេល៥០ឆ្នាំ ។ ពីឆ្នាំ១៩៣៤ ដល់ ១៩៨៤។ លទ្ធផលបានបញ្ជាក់

ឱ្យឃើញថា សាសនាដែលរីកសុសសាយជាប់លំដាប់លេខ១ គឺសាសនាឥស្លាម ។ ដែលមានមធ្យមភាគ២៣៥% ។ ចំណែកឯសាសនាគ្រិស្ទានវិញមានត្រឹមតែ៤៧%ប៉ុណ្ណោះ។ ខ្ញុំមានសំនួរសាមញ្ញមួយ តើមានសង្គ្រាមអ្វីកើតឡើងក្នុងអំឡុងពេលចន្លោះពីឆ្នាំ១៩៣៤ ដល់ឆ្នាំ១៩៨៤ ដែលគេបង្ខិបង្ខំមនុស្សរាប់ពាន់នាក់ឱ្យចូលសានាឥស្លាម? តើសង្គ្រាមអ្វី? សព្វថ្ងៃនេះសាសនាដែលរីកសុសសាយលឿងជាងគេនៅសហរដ្ឋអាមេរិក គឺសានាឥស្លាម ។ ហើយដូចគ្នា សាសនាដែលរីកសុសសាយលឿងជាងគេនៅអឺរ៉ុប គឺសានាឥស្លាម ។ ហើយខ្ញុំធ្វើជាឆ្ងល់ហើយសួរថា តើនរណាជាអ្នកបង្ខិតបង្ខំជនជាតិអាមេរិកនិងអឺរ៉ុបទាំងអស់នោះឱ្យចូលសានាឥស្លាម ? តើដាវមួយណា ? សព្វថ្ងៃនេះប្រព័ន្ធផ្សព្វផ្សាយកំពុងវាយប្រហារមកលើសានាឥស្លាម ដែលចោទថាឥស្លាមរំលោភសិទ្ធិស្ត្រី ។ តើអ្នកដឹងទេថា២/៣នៃអ្នកដែលចូលឥស្លាមនៅអាមេរិកនិងអឺរ៉ុបគឺជាស្ត្រី ។ ប្រសិនបើសាសនាឥស្លាមរំលោភសិទ្ធិស្ត្រីនោះហេតុអ្វីស្ត្រីជនជាតិអាមេរិកនិងអឺរ៉ុបព្រមចូលឥស្លាម ? តើនរណាបង្ខំពួកគាត់ ? ម្សិលមិញពួកយើងបានឃើញស្ត្រីម្នាក់ចូលសាសនាឥស្លាម អរគុណព្រះជាម្ចាស់! តើនរណាបង្ខំនាង ? តើពួកយើងប្រើដាវមែនទេ? ពិតណាស់ពួកយើងប្រើដាវប្រាជ្ញា ឬគតិបណ្ឌិត ដាវតក្កវិជ្ជា ហើយពួកយើងនឹងបញ្ចប់នូវការឆ្លើយនឹងសំនួរនេះ ។ បើសិនជា ឥស្លាមរីកសុសសាយដោយដាវ សូមស្រង់សម្តីរបស់លោកអាតាំពីរីសីនគាត់បាននិយាយថា

ក្រុមមនុស្សដែលបារម្ភខ្លាចអារ៉ាប់មានមានអាវុធនុយក្លេអ៊ែរ ។ ពួកគេបរាជ័យមិនដឹងថា អាវុធនុយក្លេអ៊ែរឥស្លាមនោះ គឺសាសនាឥស្លាមហ្នឹងឯង។ ប្រាកដណាស់គេដាក់វាចុះមកទាំងថ្ងៃកើតព្យាការីមូហាំម៉ាត់មកម្លេះ ។

## សំនួរទី៥

## ហេតុអ្វីបានជាឥស្លាមអនុញ្ញាតឲ្យបុរសមូស្លីម យកប្រពន្ធលើសពីមួយនាក់?

ជាសំនួរដែលល្បីសុសសាយជាងគេ ហើយដែលអ្នកមិនមែនមូស្លីមតែងតែសួរនូវសំនួរនេះគឺ : ហេតុអ្វីបានជាឥស្លាមអនុញ្ញាតឲ្យបុរសមុស្លីមយកប្រពន្ធលើសពីមួយនាក់? តើឥស្លាមនិយាយថាម៉េច? អល់ឡោះបានមានបន្ទូលក្នុងគួរអានជំពូកនីសាកវ៉ាក្យខណ្ឌលេខ៣ថា( ចូរពួកអ្នករៀបអាពាហ៍ពិពាហ៍ ជាមួយនារីណាដែលពួកអ្នកពេញចិត្តសម្រាប់ពួកអ្នក ពីរនាក់ បីនាក់ បួននាក់ តែប្រសិនបើពួកអ្នកមិនអាចផ្តល់ភាពយុត្តិធម៌( ដល់ពួកនាង )ទេនោះ ចូរពួកអ្នករៀបការតែម្នាក់បានហើយ...។ នេះមានន័យថា សម្រាប់បុគ្គលណាអាចផ្តល់ភាពយុត្តិធម៌តែប៉ុណ្ណោះ គេអាចរៀបការបានពីរនាក់ ឬបីនាក់ ឬបួនាក់ តែប្រសិនបើគ្មានភាពយុត្តិធម៌ទេគឺយកប្រពន្ធតែម្នាក់គត់។ ហើយគួរអានបានប្រាប់ទៀតក្នុងជំពូកនីសាកវ៉ាក្យខណ្ឌលេខ១២៩( (ហើយពួកអ្នក -ស្វាមី- មិនអាចផ្តល់ភាពយុត្តិធម៌ដាច់ខាតរវាងប្រពន្ធទាំងឡាយ ទោះជាពួកអ្នកប្រុងប្រយ័ត្នយ៉ាងណាក៏ដោយ។ ដូច្នេះចូរពួកអ្នកកុំលម្អៀងម្ខាងៗហួសពេក

...។ មានមនុស្សភាគច្រើនគិតថាបុរសត្រូវតែយកប្រពន្ធបួននាក់ក្នុងសាសនាឥស្លាម។ ក៏ប៉ុន្តែវាមិនមែនជាកាតព្វកិច្ចទេក្នុងឥស្លាម វាគ្រាន់តែជាជម្រើសដែលគេអនុញ្ញាតប៉ុណ្ណោះ។ តែបើអ្នកយកប្រពន្ធច្រើនហើយអ្នកមិនបានផ្តល់ភាពយុត្តិធម៌ជាមួយនឹងប្រពន្ធទាំងនោះ ទេ អ្នកពិតជាមានបញ្ហា(ទទួលបាបកម្ម)។ ដូច្នេះប្រសិនបើអ្នកមានលទ្ធភាពរៀបការលើសពីពីរនាក់ អ្នកត្រូវតែផ្តល់ភាពយុត្តិធម៌រវាងពួកគេ។ តោះយើងវិភាគមើល តើអ្វីទៅជាមូលហេតុដែលឥស្លាមបានអនុញ្ញាតឲ្យបុរសយកប្រពន្ធច្រើន? ជាធម្មតាភាគរយបុរសនឹងស្ត្រីនៅពេលកើតមកមានភាពប្រហាក់ប្រហែលគ្នា។ ក៏ប៉ុន្តែសម្រាប់វ័យកុមារ អ្នកអាចសួរគ្រូពេទ្យណាម្នាក់ក៏បានដែរ។ ពេទ្យនឹងប្រាប់អ្នកថា ក្មេងស្រីខ្លាំងជាងក្មេងប្រុស។ ក្មេងស្រីមានប្រព័ន្ធការពារច្រើនជាងក្មេងប្រុស។ ហើយក្មេងស្រីអាចធន់ទ្រាំនឹងជំងឺនិងមេរោគច្រើនជាងក្មេងប្រុស។ ហេតុដូច្នេះនៅវ័យកុមារ ក្មេងប្រុសប្រឈមមុខនឹងការស្លាប់ច្រើនណាស់បើប្រៀបធៀបនឹងក្មេងស្រី។ មានន័យថា នៅវ័យកុមារក្មេងស្រីច្រើនជាងបើប្រៀបនឹងក្មេងប្រុស។ ហើយយើងត្រូវគិតថា មានសង្គ្រាម និងគ្រោះថ្នាក់ចរាចរណ៍ឬគ្រឿងញៀននិងជម្ងឺ៕ ក្នុងករណីទាំងនេះគឺមនុស្សប្រុសមានអត្រាស្លាប់ច្រើនបំផុតបើប្រៀបធៀបនឹងមនុស្សស្រី។ ហើយសព្វថ្ងៃនេះស្ថិតិជំនឿនបានឲ្យដឹងថា អត្រាអាយុមនុស្សស្រីមានចំនួនច្រើនជាងអាយុមនុស្សប្រុស។ ហើយសព្វថ្ងៃនេះនៅទូទាំងពិភពលោក យើង

ឃើញថាចំនួនមនុស្សស្រីច្រើនលើសពីមនុស្សប្រុស។ ហើយយើងសង្កេតឃើញថា ប្រទេសតតិយលោកមួយចំនួនដូចជាប្រទេសឥណ្ឌាដែលជាកន្លែងកំណើតរបស់ខ្ញុំ យើងឃើញថា មនុស្សប្រុសមានចំនួនច្រើនជាងមនុស្សស្រី មូលហេតុដោយមានការរំលូតទារកក្នុងផ្ទៃនិងសម្លាប់ក្មេងស្រី។ មានកម្មវិធីមួយដែលមានឈ្មោះថា (ទុកឲ្យនាងស្លាប់)ក្នុងទូរទស្សន៍បីបីស៊ីតាមរយៈលោកអ៊ីមីលីពូកាណាន។ ហើយគេបានលើកឡើងក្នុងកម្មវិធីនោះថា គេរំលូតកូនជាងបីពាន់នាក់ជារៀងរាល់ថ្ងៃបន្ទាប់ពីគេបានដឹងថាទារកទាំងនោះជាក្មេងស្រី។ គ្រាន់តែក្នុងប្រទេសឥណ្ឌាមួយ បានសម្លាប់ទារកជាងបីពាន់នាក់ បន្ទាប់ពីបានដឹងច្បាស់ថាជាកូនស្រី។ ប្រសិនបើអ្នកយកចំនួននេះទៅគុណនឹងចំនួន៣៦៥ថ្ងៃ អ្នកនឹងឃើញចំនួនជាងមួយលានទារកដែលជាភេទស្រី ត្រូវម្ដាយរបស់គេរំលូតចោលជារៀងរាល់ឆ្នាំ។ បន្ទាប់ពីបានដឹងថាពួកគេជាភេទស្រី។ យោងតាមរបាយការណ៍របស់មន្ទីរពេទ្យរដ្ឋតាមិលណាឌូបានបញ្ជាក់ថា ក្នុងចំណោមក្មេងស្រីដែលបានកើតមកចំនួនដប់នាក់ត្រូវបានសម្លាប់ចោលអស់បួននាក់។ ប្រសិនបើមានការបញ្ឈប់ទង្វើដ៏អាក្រក់នេះគឺការសម្លាប់ទារិកានិងក្មេងស្រីនៅប្រទេសឥណ្ឌា។ សូម្បីក្នុងប្រទេសឥណ្ឌារយៈពេលប៉ុន្មានទសវត្សប៉ុណ្ណោះអត្រាក្មេងស្រីមានចំនួនច្រើនជាងក្មេងប្រុស។ សព្វថ្ងៃនេះនៅលើពិភពលោក អត្រាស្ត្រីច្រើនជាងបុរស។ នៅទីក្រុងញូវយ៉កអត្រាស្ត្រីច្រើនជាងបុរសមួយលាននាក់។ នៅ

សហរដ្ឋអាមេរិកអត្រាស្ត្រីច្រើនជាងបុរសមានចំនួន៧.៨លាននាក់។ នៅចក្រភពអង់គ្លេសអត្រាស្ត្រីលើសពីបុរសចំនួនបួនលាននាក់។ នៅប្រទេសសអាល្លឺម៉ង់អត្រាស្ត្រីលើសពីបុរសចំនួន៥លាននាក់។ នៅប្រទេសរុស្ស៊ីអត្រាស្ត្រីលើសពីអត្រាបុរសចំនួន៩លាននាក់។ មានអល់ឡោះតែមួយគត់ដែលដឹងថា ចំនួនស្ត្រីរាប់លាននាក់លើសពីបរុសនៅលើពិភពលោកទាំងមូល។ ប្រសិនបើយើងឯកភាពជាមួយនឹងយោបល់របស់អ្នកមិនមែនមូស្លីមដែលថា បុរសគ្រប់រូបចាំបាច់ត្រូវយកប្រពន្ធតែម្នាក់ប៉ុណ្ណោះ។ ហើយឧបមាថា ប្អូនស្រីរបស់ខ្ញុំឬប្អូនស្រីរបស់អ្នកបានទៅរស់នៅសហរដ្ឋអាមេរិក។ ហើយឧបមាថាពេលនោះស្ត្រីគ្រប់ៗគ្នាបានប្តីរៀងៗខ្លួន។ នៅពេលនោះសល់ស្ត្រីប្រមាណ៧.៨លាននាក់ដែលគ្មានប្តី។ ហើយឧបមាថាប្អូនស្រីរបស់ខ្ញុំឬប្អូនស្រីរបស់អ្នកដែលរស់នៅសហរដ្ឋអាមេរិក ហើយជាស្ត្រីដែលឋិតក្នុងចំណោមស្ត្រី៧.៨លាននាក់នោះ ដោយសារសំណាងមិនល្អ។ ស្ត្រីដែលគ្មានប្តី តើអ្វីជាជម្រើសសម្រាប់ពួកគាត់? ជម្រើសគឺមានតែរៀបការជាមួយនឹងបុរសដែលមានប្រពន្ធរួចឬនាងក្លាយជាកម្មសិទ្ធិរួម)។ កម្មសិទ្ធិរួម!!!! មនុស្សជាច្រើននឹងនិយាយថា បណ្ឌិតសាកៀរណែនិយាយពាក្យនេះឡើង។ ពាក្យនេះគឺចាពាក្យដែលខ្ញុំប្រើច្រើនជាងគេសម្រាប់ន័យនេះ ព្រោះវាគ្មានពាក្យណាប្រសើជាងនេះ។ ដូច្នេះ នាងគ្មានជម្រើសផ្សេងក្រៅពីរៀបការជាមួយនឹងបុរសដែលមានប្រពន្ធរួច ឬក្លាយជា(កម្មសិទ្ធិរួម)។ ហើយនៅសហរដ្ឋ

អាមេរិកមានការរីកសុសសាយកម្រិតខ្ពស់បំផុតនូវការយកស្ត្រីដទៃជាគូស្នេហ៍។ ស្ថិតិជំរឿនរបស់អាមេរិកបានបញ្ជាក់ថា ជាមធ្យមបុរសត្រូវតែមានការទំនាក់ទំនងជាមួយនឹងស្ត្រីចំនួនប្រាំបីនាក់មុននឹងសម្រេចចិត្តចាប់ដៃជាគូជីវិតជាមួយនឹងនារីម្នាក់។ ស្ត្រីប្រាំបីនាក់! ហើយអ្នកខ្លះប្រាំនាក់ ហើយអ្នកខ្លះទៀតអាចដល់ទៅដប់នាក់ ម្ភៃនាក់!។ មុនរៀបការមានការទំនាក់ទនងជាមួយគូដៃប្រាំបីនាក់ តែបន្ទាប់ពីរៀបការហើយមិនទាន់មានស្ថិតិណាបញ្ជាក់ពីចំនួនពិតឡើយ។ ក៏ប៉ុន្តែមុនរៀបការជាមធ្យមបុរសមានការទំនាក់ទំនងដៃគូចំនួនប្រាំបីនាក់។ ការមានគូស្នេហ៍ជារឿងធម្មតាគ្មានបញ្ហាឡើយនៅសហរដ្ឋអាមេរិក។ មានគូស្នេហ៍ដប់ឬម្ភៃនាក់វាគ្មានបញ្ហាទេ ក៏ប៉ុន្តែអ្វីដែលគេមិនពេញចិត្តនោះគឺយកប្រពន្ធពីរ។ ហើយពួកអ្នកទាំងអស់គ្នាដឹងហើយថា នៅពេលដែលស្ត្រីម្នាក់បានក្លាយជាប្រពន្ធទីពីរនោះនាងពិតជាមានកិត្តិយស ហើយនាងនឹងទទួលបាននូវសិទ្ធិរបស់នាង។ តែបើនាងគ្រាន់តែជាគូស្នេហ៍គឺនាងគ្មានទទួលបានសិទ្ធិអ្វីឡើយ។ គ្មានការការពារ ជីវិតនាងពោរពេញដោយក្តីអាម៉ាស់និងអាប់ឱនកិត្តិយស។ ហេតុនេះហើយបានជាឥស្លាមអនុញ្ញាតឲ្យបុរសមួយចំនួនរៀបការប្រពន្ធលើសពីមួយនាក់ ពីព្រោះដើម្បីការពារនាង។ ហើយខ្ញុំយល់ស្របជាមួយអ្នកដែលនិយាយថា គ្មាននារីណាព្រមឲ្យនារីផ្សេងមករួមចំណែកក្នុងជីវិតប្តីប្រពន្ធរបស់ខ្លួនឡើយ។ បាទ!ខ្ញុំយល់ស្របដែលថាគ្មាននារីណាព្រមឲ្យប្តីរបស់នាងមានអ្នកផ្សេងឡើយ។ ក៏

ប៉ុន្តែច្បាប់ឥស្លាមបានចែងថា (ទទួលការខាតបង់បន្តិចបន្តួចដើម្បីការពារកុំឲ្យមានបញ្ហាធំ)។ នេះមានន័យថា ស្ត្រីមុស្លិមដែលដឹងពីស្ថានភាពពិតនៃពិភពលោកមិនគួរហាមប្តីរបស់នាងមិនឲ្យមានប្រពន្ធផ្សេងឡើយ។ ព្រោះដើម្បីការពារស្ត្រីទាំងនោះកុំឲ្យនាងក្លាយជាកម្មសិទ្ធិរួម។ ចូរសួរនារីថ្លៃថ្នូរណាម្នាក់ក៏បាន ប្រសិនបើនាងមានជម្រើសពីរ ធ្វើជាប្រពន្ធទី២ ឬធ្វើជាកម្មសិទ្ធិរួម។ ពិតណាស់នាងនឹងជ្រើសរើសយកជម្រើសទីមួយជាមិនខាន។

# សំនួរទី៦

# ប្រសិនបើឥស្លាមអនុញ្ញាតឲ្យបុរសមានប្រពន្ធច្រើន៕ ចុះហេតុអ្វីបានជាមិនអនុញ្ញាតឲ្យស្ត្រីមានប្តីច្រើនដែរ?

បើនិយាយអំពីរៀបការស្ត្រីវិញ.. ក្នុងគម្ពីគួរអានបានបកស្រាយពីប្រភេទនារីដែលបុរសអាចរៀបការជាមួយនិងនាងបាននៅក្នុងជំពូកនីសាកឃ្លាទី២២-២៤។ ហើយនៅក្នុងជំពូននីសាកឃ្លាទី២៤បានបញ្ជាក់ថា បុរសមិនអាចយកនារីដែលមានប្តីរួចធ្វើជាភរិយាបានឡើយ នេះក្នុងសាសនាឥស្លាម។ ស្ត្រីមិនអាចយកប្តីលើសពីមួយនាក់បានឡើយ។ មុននឹងខ្ញុំប្រាប់ពួកអ្នកពីមូលហេតុពិត៕ សូមគិតជាមុនសិន.. មាននារីមួយក្រុមដែលមិនទាន់មានប្តី ហើយប្រសិនបើស្ត្រីអាចយកប្តីលើសពីមួយនាក់នោះ ការកង្វះខាតវាកាន់តែកើនឡើង ដែលជាមូលហេតុនាំឲ្យមានបញ្ហាកាន់តែធំ។ តោះយើងនាំគ្នាវិភាគមើល តើអ្វីជាមូលហេតុដែលឥស្លាមបានហាមមិនឲ្យស្ត្រីមានប្តីច្រើនលើសពីមួយនាក់។ ខណៈដែលបុរសមានប្រពន្ធច្រើនលើសពីមួយនាក់៕ ហើយនៅពេលដែលមានកូនមកគឺវាងាយស្រួលបំផុតក្នុងការសម្គាល់ឪពុកម្តាយរបស់គេ។ តែបើនាងយកប្តីច្រើនលើសពីមួយនាក់វិញ ហើយនៅពេលមានកូន យើងអាចសម្គាល់

ម្ដាយរបស់ក្មេង តែយើងមិនអាចសម្គាល់ថាតើនរណាជាឪពុករបស់ក្មេងនោះ។ ហើយនៅពេលដែលអ្នកចង់ចុះឈ្មោះកូនអ្នកឲ្យចូលសាលា ហើយគេសួរអ្នកពីឈ្មោះឪពុក គឺអ្នកត្រូវផ្ដល់ឈ្មោះពីរ។ ហើយចិត្តវិទូសព្វថ្ងៃឲ្យយើងដឹងថា។ ពិតណាស់ ការកំណត់អត្តសញ្ញាណឪពុកម្ដាយមានសារៈសំខាន់បំផុតសម្រាប់ជីវិតដ៏មានសុខភាពរបស់ក្មេង..ជាពិសេសអត្តសញ្ញាណឪពុក។ ប្រសិនបើមិនគេអាចកំណត់អតសញ្ញាណរបស់ឪពុកម្ដាយបានទេនោះ ក្មេងនឹងកើតជំងឺផ្លូវចិត្តធ្ងន់ធ្ងរ។ បច្ចុប្បន្នដោយសារវិទ្យាសាស្ត្រជឿនលឿន ខ្ញុំក៏បានដឹងពីបញ្ហានេះ។ ជាការពិតណាស់មានការធ្វើតេស្ត ឌីអិនអេ និងការពិនិត្យមើលហ្សែន អ្នកអាចកំណត់បានថាតើនរណាជាឪពុក ហើយនរណាជាម្ដាយបាន។ ទោះបីជាមានការធ្វើពិសោធទាំងនេះក៏ដោយក៏មិនទាន់ល្អិតល្អន់នៅឡើយទេ។ តែអ្វីទាំងអស់នេះគឺទើបរកឃើញនាពេលថ្មីៗនេះ ពីមុនមិនទាន់មានឡើយ។ នេះពុំមែនជាមូលហេតុតែមួយដែលឥស្លាមហាមមិនឲ្យស្ត្រីយកប្ដីច្រើនលើសពីមួយនាក់នោះទេ។ នៅមានមូលហេតុជាច្រើនទៀត៕ ឧទាហរណ៍ដូចជាវិទ្យាសាស្ត្របានប្រាប់យើងថាៈ បុរសមានចរិតចង់មានដៃគូច្រើននាក់ជាងស្ត្រីភេទ ។ វិទ្យាសាស្ត្របានបញ្ជាក់ប្រាប់យើងថាៈ ដោយសារមូលហេតុការផ្លាស់ប្ដូរអាកប្បកិរិយា និងផ្លូវចិត្តដែលកើតឡើងលើរូបនាងនៅពេលុះពុងមករដូវ។ ជាហេតុដែលធ្វើឲ្យនាងមិនអាចបំពេញតួនាទីជាប្រពន្ធលើសពីមួយនាក់បានឡើយក្នុងពេលតែមួយនោះ។ រីឯបុរសវិញគេអាចបំពេញតួនាទីជាប្ដីលើសពីមួយនាក់ក្នុងរយៈពេលតែមួយនោះ។ ប្រសិនបើស្ត្រីមានដៃគូរួមភេទលើសពីមួយនាក់

ទោះបីជាពួកគេទាំងនោះមានចិត្តស្មោះស្ម័គ្រនឹងគ្នាក៏ដោយ។ គឺនៅតែមានគ្រោះថ្នាក់ធំបំផុតក្នុងការប្រឈរមុខនឹងជំងឺឆ្លងដែលជាហេតុធ្វើឲ្យបុរសឆ្លងជំងឺនេះ។ តែបើសិនជាបុរស តាមវិទ្យាសាស្រ្តបានបញ្ជាក់ប្រាប់ថាៈ ប្រសិនបើបុរសមានប្រពន្ធលើសពីមួយនាក់ឬមានដៃគូររួមភេទលើសពីមួយនាក់ ហើយពួកនាងមានការស្មោះស្ម័គ្រនោះ។ គឺជំងឺកាមរោគ រឺជំងឺឆ្លងពិបាកនឹងឆ្លងរវាងពួកគេ។ ដូច្នេះទាំងវេជ្ជសាស្រ្តនិងវិទ្យាសាស្រ្តបញ្ជាក់ថា គគ្មានបញ្ហាឡើយសម្រាប់បុរសដែលមានប្រពន្ធច្រើនលើសពីមួយនាក់នោះ។ តែវាមានបញ្ហាប្រសិនបើស្រ្តីមានប្តីលើសពីមួយនាក់នោះ។

# សំនួរទី៧

# ហេតុអ្វីបានជាឥស្លាមគាបសង្កត់ស្ត្រីដោយបង្ខំឲ្យនាងគ្របក្បាល

វាជាការយល់ខុសទីប្រាំពីរមកលើឥស្លាម។ នៅក្នុងគំនិតរបស់អ្នកមិនមែនឥស្លាមគឺៈ ហេតុអ្វីបានជាឥស្លាមគាបសង្កត់ស្ត្រីដោយបង្ខំឲ្យនាងគ្របក្បាល? ហេតុអ្វីបានជាឥស្លាមបង្ខំឲ្យស្ត្រីគ្របបិទបាំងខ្លួនប្រាណ? មុននឹងខ្ញុំជជែកគ្នាពីមូលហេតុគ្របខ្លួនប្រាណ(ហីជាប) តោះយើងមកវិភាគមើលថា តើស្ត្រីមានស្ថានភាពយ៉ាងដូចម្តេចក្នុងអារិយធម៌សម័យបុរាណ? នៅពេលយើងអានប្រវត្តិសាស្ត្រអរិយធម៌បាប៊ីឡូន យើងឃើញថា ស្ត្រីត្រូវគេប្រមាថមើលងាយក្នុងការទំនាក់ទំនង។ ហើយប្រសិនបើបុរសណាម្នាក់សម្លាប់គេនោះ គឺពួកគេដាក់ទណ្ឌកម្មលើបុរសនោះដោយសម្លាប់ប្រពន្ធរបស់គេ នេះគឺជាច្បាប់របស់ពួកគេ។ ហើយបើសិនជាអ្នកអានអរិយធម៌ក្រិចបុរាណហើយគេទទួលស្គាល់ថា ជាអរិយធម៌ដ៏ល្បីល្បាញបំផុត។ នៅសម័យនោះពួកគេមានអប្បិយជំនឿលើស្ត្រីម្នាក់នាងមានឈ្មោះថា បានដូរ៉ា នាងជាមូលហេតុនាំជោគអាក្រក់មកដល់សង្គម។ ក្នុងអារ្យធម៌ក្រិចបុរាណដ៏មហិមានេះពួកគេបានចាត់ទុកស្ត្រីជាឧបករណ៍បម្រើតណ្ហា និងពេស្យាចារ ហើយវារីកសុសសាយមែន

ទែន។ ហើយបើសិនជាយើងអានប្រវត្តិសាស្រ្ត រ៉ូម៉ាំង សូម្បីតែក្នុងអារ្យធម៌រ៉ូម៉ាំង តម្លៃស្រ្តីត្រូវធ្លាក់ចុះកាន់តែខ្លាំង ហើយអំពើពេស្យាចារនិងការអាក្រាតកាយសុសសាយខ្លាំងមែនទែន។ ហើយបើសិនជាយើងអានអារ្យធម៌អេហ្ស៊ីប គេបានចាត់ទុកស្រ្តីជាសភាវៈអាក្រក់ ហើយគេហៅនាងថាជាឧបករណ៍បិសាចសាតាំង។ ហើយនៅពេលយើងអានប្រវត្តិអារ្យធម៌អារ៉ាប់មុនឥស្លាម គឺពួកគេបានកប់កូនស្រីរបស់ពួកគេទាំងរស់បន្ទាប់ពីបានកើតមកនោះ។ អរគុណចំពោះអល់ឡោះ! សូមអរគុណចំពោះអល់ឡោះជាម្ចាស់បន្ទាប់ពីឥស្លាមមកដល់ ការប្រព្រឹត្តអំពើអាក្រក់ទាំងនោះត្រូវបានបញ្ឈប់ តែនៅមានវត្តមានជុំវិញពិភពលោកនៅឡើយ។ អរគុណចំពោះអល់ឡោះ ឥស្លាមជាសាសនាដែឲ្យតម្លៃស្រ្តី។ ហើយព្យាការីមូហាំម៉ាត់ជាមូលហេតុសំខាន់ក្នុងការផ្តល់សិទ្ធិដល់ស្រ្តី។ ហើយបន្ទាប់ពីឥស្លាមបានផ្តល់សិទ្ធិដល់ស្រ្តី ក៏បានបង្ហាញប្រាប់យើងអំពីវិធីសាស្រ្តសម្រាប់ស្រ្តីដើម្បីរក្សាសិទ្ធិនេះជារៀងរហូត។ គ្រប់កាយជាតួនាទីរបស់ស្រ្តីដើម្បីរក្សាសិទ្ធិរបស់នាងជារៀងរហូត ហើយកុំឲ្យវិលទៅរកសម័យបុរាណទៀត។ តាមទម្លាប់របស់មនុស្សភាគច្រើននិយាយពីការបិទបាំងខ្លួនប្រាណរបស់ស្រ្តី ក៏ប៉ុន្តែអល់ឡោះបាននិយាយពីការបិទបាំងខ្លួនប្រាណរបស់បុរសមុន ហើយបន្ទាប់មកទើមទ្រង់និយាយពីការបិទបាំងរបស់ស្រ្តី។ នៅក្នុជំពូកអាននួរ២៤ឃ្លាទី៣០អល់ឡោះទ្រង់មានបន្ទូលថាៈ ចូរ(អ្នកព្យាការីមូហាំម៉ាត់)ពោលទៅកាន់បុរសទាំងឡាយ

ដែលមានជំនឿឲ្យពួកគេដាក់ក្រសែភ្នែកចុះពីការសម្លឹងមើល( ស្ត្រីនិងអ្វីដែលច្បាប់ឥស្លាមបានហាមឃាត់ )ហើយឲ្យពួកគេថែរក្សាប្រដាប់ភេទរបស់ពួកគេ( កុំធ្វើអំពើផិត )។ នៅពេលបុរសបានមើលទៅស្ត្រីម្នាក់ ហើយនៅពេលគេគិតអ្វីមួយដែលមិនសមរម្យគឺគេត្រូវតែដាក់ក្រសែភ្នែករបស់គេចុះ។ នេះគឺជាអ្វីដែលគម្ពីរគួរអានបានប្រាប់។ មានថ្ងៃមួយមានបុរសម្នាក់បានសម្លឹងមើលទៅ នារីម្នាក់អស់រយៈពេលជាយូរ ហើយខ្ញុំក៏បាននិយាយទៅកាន់គេថា នែ!ប្អូនអ្នកដូច្នេះឥស្លាមមិនអនុញ្ញាតទ្បើយ។ ហើយគាត់បានតបវិញថា ព្យាការីមូហាំម៉ាត់បានប្រាប់ថា ការក្រឡេកមើលនារីលើកទីមួយគឺគេអនុគ្រោះ ហើយលើកទីពីរត្រូវគេហាមឃាត់ ហើយការមើលរបស់ខ្ញុំលើកទីមួយមិនទាន់បានពាក់កណ្តាលផងហ្នឹង។ ព្យាការីគាត់ចង់ប្រាប់ថា ការមើលលើកទីមួយគេអនុគ្រោះ ហើយលើកទីពីរត្រូវគេហាមនោះ គឺមានន័យថា ប្រសិនបើអ្នកមើលដោយអចេតនា ចូរកុំមើលទៅនាងម្តងទៀត។ នេះមិនមែនមានន័យថា គេអនុញ្ញាតឲ្យអ្នក មើលរយៈពេលដប់នាទីជាប់គ្នាគ្មានឈប់ រួចហើយអ្នកនិយាយថា ខ្ញុំមិនទាន់មើលលើកទីមួយគ្រប់ផង។ អាយ៉ាតទីពីរនៃជំពូកអាននួរឃ្លាទី៣១។ បាននិយាយអំពីការបិទបាំងខ្លួនប្រាណរបស់ស្ត្រី។ ចូរអ្នក( ណាពីមូហាំម៉ាត់ )ពោលទៅកាន់ស្ត្រីទាំងឡាយដែលមានជំនឿឲ្យពួកនាងដាក់ក្រសែភ្នែករបស់ពួកនាងចុះពីការសម្លឹងមើល( បុរសនិងអ្វីដែលច្បាប់ឥស្លាមហាមឃាត់ )ហើយឲ្យពួកនាង ថែរក្សាប្រដាប់ភេទ

របស់ពួកនាង...។ មានប្រាំមួយចំណុចសំខាន់ដែលគម្ពីគួរអាននិងហាទីសបានបកស្រាយប្រាប់ពីការបិទបាំងខ្លួនប្រាណ។ ដំបូងបង្អស់គឺសារុងឬសំពត់វែង។ សម្រាប់បុរសត្រូវគ្របពីផ្ចិតរហូតដល់ជង្គង់ រីឯស្ត្រីវិញគឺគ្របខ្លួនប្រាណទាំងអស់។ ហើយមានមួយផ្នែកដែលគេអនុញ្ញាតឲ្យបើកនោះគឺមុខនិងបាតដៃទាំងពីរ។ ហើយប្រាំចំណុចផ្សេងទៀតនោះទាំងប្រុសទាំងស្រីគឺដូចគ្នា។ ទីពីរៈ សម្លៀកបំពាក់ដែលស្ត្រីស្លៀកគឺត្រូវឲ្យធំទូលាយ កុំឲ្យចង្អៀតនិងរឹបនោះឡើយ។ ទីបីៈ កុំឲ្យក្រណាត់នោះស្តើង (ឃើញសាច់)ដែលធ្វើឲ្យអ្នកដទៃមើលឃើញសាច់ខាងអាវ។ ទីបួនៈ ត្រូវចៀសវាងពីសម្លៀងបំពាក់ដែលគួរជាទីទាក់ទាញ។ ទីប្រាំៈ ស្ត្រីមិនត្រូវប្រើសម្លៀកបំពាក់បុរសហើយបុរសមិនត្រូវប្រើសម្លៀកបំពាក់ស្ត្រី។ ទីប្រាំមួយៈ មិនត្រូវប្រើសម្លៀកបំពាក់ប្រដូចខ្លួននឹងអ្នកមិនមែនមុស្លីម។ នេះគឺជាចំណុចសំខាន់ទាំងប្រាំមួយទាក់ទងនឹងសម្លៀកបំពាក់សម្រាប់គ្របខ្លួនប្រាណនោះ។ តែនេះមិនមែនជាការគ្របខ្លួនដែលពេញលក្ខណៈនោះទេ។ ដែលហៅថាការគ្របខ្លួនពេញលក្ខណៈគឺ រួមបញ្ចូលទាំងទង្វើរបស់យើង អត្តចរិករបស់យើង និងសេចក្តីប្រាថ្នារបស់យើង។ ក្រៅពីការបិទបាំងខ្លួនប្រាណគឺមានការបិទបាំងភ្នែកចិត្តគំនិតនិងទស្សនៈ។ ហើយវារួមបញ្ចូលទាំងការយ វាចា ចិត្ត នេះគឺជាការបិទបាំងដែលពេញលក្ខណៈ។ អល់ឡោះមានបន្ទូលក្នុងគម្ពីគួរអានជំពូកអះហ្សាប៣៣ឃ្លាទី៥៩ថាៈ នែណាពី! ចូរអ្នកប្រាប់ទៅកាន់ភរិយាៗរបស់អ្នកនិងកូនស្រី

ទាំងឡាយរបស់អ្នកនិងប្រពន្ធៗរបស់ពួកអ្នកមានជំនឿឲ្យបិទបាំងរាងកាយរបស់ពួកនាងដោយអាវវែងរបស់ពួកនាង។ធ្វើដូច្នោះងាយស្រួលបំផុតកុំឱ្យគេស្គាល់ ហើយពួកនាងក៏មិនត្រូវបានគេមើលងាយដែរ។ គម្ពីគួរអានបានប្រាប់ថា ការដែលឲ្យស្ត្រីគ្របខ្លួនគឺដើម្បីឲ្យនាងមានកិត្តិយសហើយដើម្បីការពារនាងមិនឲ្យមានការបៀតបៀនលើរូបនាង។ ខ្ញុំមានសំនួរមួយ ឧបមាថា មាននារីពីរនាក់ជាបងប្អូននិងគ្នា ហើយគេទាំងពីរមានរូបស្រស់ស្អាតស្មើគ្នា។ គេទាំងពីរដើរតាមដងផ្លូវក្នុងនីសនៃប្រទេសឌូបៃ។ ហើយម្នាក់នៃនារីទាំងពីរនាក់បានពាក់សម្លៀកបំពាក់ឥស្លាមដែលគ្របខ្លួនទាំងមូល លើកលែងតែមុខនិងបាតដៃប៉ុណ្ណោះ។ ហើយនារីម្នាក់ទៀតបានស្លៀកពាក់ខើចខ្លី។ ហើយនៅតាមដងផ្លូវនោះមានបុរសចិត្តអាក្រក់ម្នាក់ចង់បៀតបៀនស្ត្រី ហើយចង់បង្កបញ្ហាទៅលើនាងទាំងពីរ។ ខ្ញុំចង់សួរអ្នកថា តើនារីមួយណាដែលគេចង់ទៅបៀតបៀននោះ? តើគេនឹងទៅបៀតបៀននារីដែលស្លៀកពាក់សម្លៀកឥស្លាមឬយ៉ាងណា? ឬក៏គេទៅបៀតបៀននារីដែលស្លៀកខើចខ្លីនោះ? តើនារីមួយណាដែលគេនឹងទៅបៀតបៀន? នារីមួយណា?ជាធម្មតាគេនឹងជ្រើសរើសនារីដែលស្លៀកខើចខ្លីនោះហើយ។ ហើយបើអ្នកហៅចម្លើយនឹងមកដល់អ្នក។ ហេតុនេះគួរអានបានប្រាប់ការពិតថា ការដែលគេបង្គាប់ឲ្យស្ត្រីគ្របខ្លួន គឺដើម្បីការពារនាងកុំឲ្យមានការបៀតបៀនទៅលើរូបនាង។ លើសពីនេះ បើសិនមានករណីចាប់រំលោភទៅលើនារីណា

ម្នាក់ ច្បាប់ឥស្លាមដាក់ទណ្ឌកម្មឱ្យប្រហាជីវិតជនល្មើសនោះ។ ហើយមានអ្នកមិនមែនឥស្លាមភាគច្រើននឹងនិយាយថា ទោសប្រហារជីវិត!!! នៅសតវត្សនទី២១ ឥស្លាមពិតជាសាសនាព្រៃផ្សៃណាស់ច្បាប់ពិតជាគ្មានធម៌មេត្តាមែន។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំសួរសំនួរតទៅនេះ ហើយខ្ញុំបានសួរអ្នកមិនមែនមុស្លីមរាប់ពាន់នាក់រួចមកហើយ។ ឧបមាថា បើសិនជាអល់ឡោះទ្រង់បានហាមដូច្នោះ។ ហើយមានមនុស្សម្នាក់ចាប់រំលោភម្ដាយរបស់អ្នកឬប្អូនស្រីរបស់អ្នក ហើយអ្នកជាអ្នកធ្វើការក្នុងតុលាការ ហើយគេបាននាំជនល្មើសមកដាក់នៅចំពោះមុខអ្នក តើទណ្ឌកម្មអ្វីដែលអ្នកនឹងដាក់លើជនល្មើសនោះ។ ជឿខ្ញុំទៅ ពួកគេច្បាស់ជានិយាយមួយរយភាគរយថា ពួកយើងនឹងដាក់ទោសប្រហាជីវិតគេ។ ហើយមានអ្នកខ្លះនិយាយថាធ្វើទារុណកម្មគេរហូតទាល់ស្លាប់។ ប្រសិនបើគេចាប់រំលោភម្ដាយអ្នកឬប្អូនស្រីរបស់អ្នក អ្នកនឹងដាក់ទោសប្រហាជីវិត។ តែបើគេចាប់រំលោភម្ដាយឬប្អូនស្រីអ្នកដទៃ ពួកគេថា ទោសប្រហាជីវិតជាច្បាប់សាហាវណាស់។ ហើយលោកខាងលិចបានអះអាងថា ពួកគេជាអ្នកលើកស្ទួយកិត្តិយសស្ត្រី តែការពិតពួកគេជាអ្នកដែលធ្វើឲ្យស្ត្រីអាប់ឱនកិត្តិយស។ ពួកគេយកនាងជាគូកំណាន់ ឬសង្សារ ហើយនាងគ្រាប់តែជាឧបករណ៍សប្បាយរបស់អ្នកល្មោភតណ្ហា និងជាទំនិញសម្រាប់ការជួយដូរផ្លូវភេទ។ ផ្ទៃស្ដើងនៅពីក្រោយអេក្រង់លាបពណ៌ដោយសិល្បៈ និងការយល់ព្រម ក្រោមឈ្មោះវប្បធម៌ និងសិល្បៈពួកលោកខាងលិច

បានលក់កូនស្រីរបស់ពួកគេ និងម្តាយរបស់ពួកគេ។ ហើយដូចអ្នកបានឃើញស្រាប់ ជារឿងសាមញ្ញទៅហើយ រាល់ការផ្សាយពាណិជ្ជកម្មគឺចាំបាច់ត្រូវតែមានស្ត្រី។ ហើយអ្នកពិតជាបានឃើញការផ្សាយពាណិជ្ជកម្មម៉ូតូ។ តើមាននារីប៉ុន្មាននាក់ដែលបើកបរម៉ូតូនោះ? ទោះជាយ៉ាងនោះក៏ដោយ ស្ត្រីត្រូវមានវត្តមានក្នុងការពាណិជ្ជកម្មម៉ូតូ។ ត្រូវមានក្នុងការផ្សាយពាណិជ្ជកម្មរថយន្ត ហើយស្ត្រីភាគតិចបំផុតដែលចេះបើកបរ។ តែទោះជាយ៉ាងនោះក៏ដោយ គេឃើញស្ត្រីមានក្នុងការផ្សាយពាណិជ្ជកម្ម។ ហើយគេបានប្រាប់ខ្ញុំរួចហើយអំពី ការផ្សាយពាណិជ្ជកម្មមួយដ៏ល្បីបំផុតអំពីរថយន្តបីអេមដាប្បិលយូ។ តើអ្នកស្គាល់ឡានបីអេមដិប្បិលយូទេ។ វាជាក្រុមហ៊ុនរថយន្ត ហើយយុវវ័យពេញចិត្តវាណាស់ ព្រោះ គ្រឿងរបស់មានគុណភាពល្អ ហើយលឿន។ មានគេប្រាប់ខ្ញុំថា នៅក្នុងការផ្សាយពាណិជ្ជកម្ម បីអេមដិប្បិលយូម្តងនោះ មាននារីម្នាក់ឈរនៅខាងមុខឡាន។ ហើយនាងស្លៀកពាក់ខោអាវហែលទឹក ហើយគេសរសេរដាក់ពីមុខនាងថា (ចូរអ្នកសាកបើកវាឥឡូវនេះ) តើមួយណា?ឡានឬនាង? ក្រោមឈ្មោះសិទ្ធិសិរីភាពរបស់ស្ត្រីពួកគេលក់ប្រពន្ធកូននិងម្តាយរបស់ពួកគេ។តែយើងជាមុស្លីមយើងស្រលាញ់ប្រពន្ធកូននិងម្តាយរបស់ពួកយើងណាស់។ ប្រសិនបើការបិទបាំងខ្លួនប្រាណជាការគាបសង្កត់លើស្ត្រី តែវាការពារនាងនោះ គឺយើងស្រលាញ់ពេញចិត្តនឹងការគាបសង្កត់នេះ។ គឺយើងស្រលាញ់ពេញចិត្តនឹងការគាបសង្កត់និងការ

ការពារនេះ។ ប្រសិនបើនេះជាសិទ្ធិសេរីភាពរបស់អ្នក ក្រោមឈ្មោះសិទ្ធិសេរីភាពស្ត្រីវាគឺជាការលក់ខ្លួន ហើយពួកយើងរីករាយជាមួយនឹងសាសនារបស់ពួកយើងណាស់។ ឥស្លាមបានបង្គាប់ឱ្យស្ត្រីគ្របខ្លួនដើម្បីការពារនាងនិងលើកស្ទួយកិត្តិយសរបស់នាង។ ហើយសព្វថ្ងៃយើងបានឃើញមានបញ្ហាកើតឡើងក្នុងសង្គមអារ៉ាប់ ដូចបញ្ហាដែលបានកើតឡើងចំពោះអរិយធម៌ ក្រិចបុរាណ និងរូម៉ាំង ក្រោមឈ្មោះសិទ្ធិស្ត្រីសិល្បៈ អរិយធម៌ និងការបង្ហាញម៉ូត។ សម្លៀបកបំពាក់ ហើយអ្វីដែលអ្នកបានឃើញសព្វបែបយ៉ាង តើពួកគេកំពុងធ្វើអ្វី? គឺពួកគេបានវិលទៅរកសម័យមុនវិញហើយ។

# សំនួរទី៨

# ហេតុអ្វីបានជាឥស្លាមអនុញ្ញាតិឲ្យអ្នកមុស្លីមហូបសាច់?

ដូចដែលអ្នកបានដឹង ការសម្លាប់សត្វគឺពិតជាគ្មានធម៌មេតាឡើយ ដូច្នេះហេតុអ្វីបានជាឥស្លាមអនុញ្ញាតិ ឲ្យអ្នកមុស្លីមហូបសាច់អញ្ចឹង? ជាបឋមខ្ញុំចង់រំឭកថា អ្នកមុស្លីមអាចក្លាយទៅជាអ្នកមុស្លីមដ៏ល្អទោះបីគាត់មិនហូបសាច់ក៏ដោយ។ គឺគ្មានឡើយក្នុងគម្ពីគួរអានឬហាទីសដែលបញ្ជាក់ថា អ្នកមុស្លីមចាំបាច់ត្រូវតែហូបសាច់នោះ។ ក៏ប៉ុន្តែក្នុងគម្ពីគួរអានអល់ឡោះទ្រង់បានអនុញ្ញាតិឲ្យមនុស្សលោកហូប ចុះហេតុអ្វីបានជាយើងមិនហូប?! ក្នុងគម្ពីគួរអាននៅក្នុងជំពូកទី៥ឃ្លាទី១ទ្រង់បានមានបន្ទូលថាៈ ((ឱបណ្តាអ្នកដែលមានជំនឿ ចូរពួកអ្នកអនុវត្តតាមពាក្យសន្យាចុះ។ គេបានអនុញ្ញាតិឲ្យពួកអ្នកបរិភោគគ្រប់សត្វពាហនៈលើកលេងតែអ្វីដែលគេនឹងសូត្រប្រាប់ពួកអ្នក..))។ ចូរពួកអ្នកបរិភោគចុះគ្រប់សត្វពាហនៈលើកលេងតែអ្វីដែលគេហាមឃាត់ប៉ុណ្ណោះ។ ក្នុងគម្ពីគួរអានជំពូកទី១៦ឃ្លាទី៥បានបញ្ជាក់ថា ((ហើយសត្វពាហនៈជាច្រើនដែលទ្រង់បានបង្កើតវាសម្រាប់ពួកអ្នក ដែលសត្វទាំងនោះ(មានរោមធ្វើជាសំលៀកបំពាក)ផ្តល់ភាពកក់ក្តៅ ហើយផ្តល់ផល់ប្រយោជន៍

ជាច្រើន ហើយវាមួយចំនួនពួកអ្នកក៏អាចទទួលទានបានផងដែរ។ ក្នុងគម្ពីគួរអានក្នុងជំពូកទី២៣ឃ្លាទី២១បានប្រាប់ថាៈ ហើយពិតប្រាកដណាស់ចំពោះសត្វពាហនៈ គឺជាមេរៀនមួយ សម្រាប់ពួកអ្នក(ទុកពិចារណា)។ យើងផ្តល់ឲ្យពួកអ្នកទទួលទាននូវអ្វីដែលមាននៅក្នុងពោះរបស់ពួកវា(ទឹកដោះ)។ហើយចំពោះសត្វនោះវាមានផលប្រយោជន៍ជាច្រើនសម្រាប់ពួកអ្នក ហើយវាមួយចំនួនពួកអ្នកក៏អាចទទួលទានបានផងដែរ។ គម្ពីគួរអានបានអនុញ្ញាតិឲ្យបរិភោគសាច់ ចុះហេតុអ្វីបានជាយើងមិនបរិភោគ!!! តោះយើងវិភាគមើលពីមូលហេតុដែលឥស្លាមអនុញ្ញាតឲ្យបរិភោគសាច់នោះ។ ការស្រាវជ្រាវសព្វថ្ងៃបានឲ្យដឹងថាៈ អាហារមិនមែនរុក្ខជាតិ(សាច់) ជាម្ហូបអាហារដែលមានជាតិគ្រប់គ្រាន់និងសម្បូរទៅដោយ ប្រូតេអ៊ីន ហើយរាងកាយត្រូវការ អាស៊ីត អាមីណូ ហើយមានអាស៊ីតអាមីណូ ប្រាំបីយ៉ាងដែលខ្លួនមនុស្សមិនអាចផលិតបាន។ ហើយខ្លួនមនុស្សត្រូវការអាហាររូបត្ថម្ភពីខាងក្រៅដែលគេស្គាល់ថាអាស៊ីតអាមីណូ។ ជាតិអាស៊ីតអាមីណូទាំងប្រាំបីនេះគឺមាននៅតែក្នុងសាច់ប៉ុណ្ណោះ។ ដូច្នេះសាច់មានប្រូតេអ៊ីនគ្រប់គ្រាន់ ចំណែកអាហាររុក្ខជាតិវិញគឺគ្មានជាតិអាមីណូនេះឡើយ។ លើសពីនេះទៅទៀត។ សាច់ គឺសម្បូរ niacin និង វិតាមីនបី , ជាអាហារ ដែលមានសុខភាពល្អ។ មានអ្នកមិនមែនមុស្លីមជាច្រើន ជាពិសេសពួកហិណ្ឌូបានថាហេតុអ្វីពួកមុស្លីមបរិភោគសាច់? ជាពិសេសពួកឥណ្ឌា គឺពួកគេនៅគ្រប់ទីកន្លែ

ង។ ប្រជាជនឥណ្ឌាមាន២០%នៃប្រជាជនពិភពលោក។ អ្នកទៅគ្រប់ទីកន្លែង អាមេរិក កាណាដា ឌូបៃ អ្នកនឹងបានជួបជនជាតិឥណ្ឌា។ ហេតុនេះហើយបានជាសំនួរនេះសុះសាយជុំវិញពិភពលោក។ ខ្ញុំតបទៅពួកគេថា: ប្រសិនបើអ្នកសង្កេតមើលធ្មេញសត្វពាហនៈដែលស៊ីរុក្ខជាតិ គោ ចៀម ពពែ ដែលស៊ីតែស្មៅនោះ។ អ្នកពិតជាបានឃើញប្រភេទធ្មេញនោះជាប្រភេទធ្មេញដែលស្មើរគ្នា ហើយគេឲ្យឈ្មោះថា ប្រភេទធ្មេញដែលបរិភោគរុក្ខជាតិប៉ុណ្ណោះ។ ហើយប្រសិនបើអ្នកសង្កេតមើលធ្មេញសត្វដែលស៊ីសាច់ជាអាហារ តោ ខ្លា ខ្លាដំបង គេឃើងឃើញថា ប្រភេទធ្មេញដែលមានចង្កោម។ គឺសត្វទាំងនោះមានធ្មេញចង្កោម។ នៅពេលដែលអ្នកមើលកញ្ចក់ហើយអ្នកសង្កេតមើលធ្មេញរបស់មនុស្ស អ្នកនឹងឃើញមានធ្មេញស្មើរផងចង្កោមផង។ ប្រសិនបើអល់ឡោះចង់ឲ្យយើងបរិភោគតែរុក្ខជាតិប៉ុណ្ណោះចុះហេតុអ្វីបានជាទ្រង់ផ្តល់ធ្មេញចង្កោមដល់យើង ធ្មេញដែលបរិភោគសាច់?តើគឺដើម្បីអ្វី? គឺដើម្បីបរិភោគសាច់ហ្នឹងហើយ។ លើសពីនេះទៅទៀត បើយើងសង្កេតមើលប្រព័ន្ធរំលាយអាហាររបស់សត្វដែលស៊ីរុក្ខជាតិ គោ ពពែ ចៀម គឺអាចរំលាយតែអាហាររុក្ខជាតិប៉ុណ្ណោះ។ ហើយបើវាស៊ីសាច់គឺប្រព័ន្ធរំលាយអាហារមិនអាចរំលាយបានឡើយ។ ហើយបើអ្នកពិសោធមើលប្រព័ន្ធរំលាយអាហារសត្វដែលស៊ីសាច់នោះ ដូចជា ខ្លា ខ្លារខិន តោ គឺវាមិនអាចរំលាយអាហាររុក្ខជាតិបានឡើយ។ តែបើប្រព័ន្ធរំលាយអាហាររបស់

មនុស្សវិញគឺវាអាចរំលាយអាហារបានទាំងសាច់និងរុក្ខជាតិ។ ប្រសិនបើទ្រង់ចង់ឲ្យយើងបរិភោកតែរុក្ខជាតិប៉ុណ្ណោះ ចុះហេតុអ្វីបានជាទ្រង់ផ្តល់ដល់យើងនូវប្រព័ន្ធរំលាយអាហារ ដែលអាចរំលាយជាតិសាច់បាននោះ។ ហេតុនេះការបរិភោគសាច់វាជារឿងធម្មតាទេ។យើងមានពោះវៀតស្មើងនិងក្រាស់ ដើម្បីបរិភោគរុក្ខជាតិនិងសាច់។ យើងមិនមែនជាអ្នកបរិភោគតែរុក្ខជាតិហើយមិនបរិភោគសាច់នោះទេ។ យើងបរិភោគទាំងពីរ។ ហើយមានពួកហិណ្ឌូជាច្រើនបានយល់ច្រឡំថា សាសនាហិណ្ឌូបានហាមមិនឲ្យបរិភោគសាច់ឡើយ។ បើអ្នកអានគម្ពីហិណ្ឌូ គឺអ្នកនឹងបានជួបក្នុងគម្ពីនោះជាច្រើនកន្លែងដែលបានប្រាប់ថា ចូរពួកអ្នកបរភោគសាច់ចុះ។ បើអ្នកអានគម្ពី(ម៉ានូសម៉េរតី)ភាគទីប្រាំឃ្លាទី៣០បានប្រាប់ថា: ការពិតណាស់អ្នកដែលបរិភោគប្រសិនបើគេបរិភោគសាច់ណាដែលគេអនុញ្ញាតិឲ្យបរិភោគនោះគឺវាជាការល្អបំផុត។ ទោះបីមួយថ្ងៃចន្លោះមួយថ្ងៃក៏ដោយ ព្រោះព្រះជាម្ចាស់បានបង្កើតមកគឺមានអ្នកបរិភោគនិងអ្នកដែលត្រូវគេបរិភោគ។ នៅពេលដែលអ្នកអានគម្ពីម៉ានូសម៉េរតីភាគទី៥ឃ្លាទី៣១ បានប្រាប់ថា: ការបរិភោគសាច់ក្នុងលក្ខណៈបូជាគឺគ្មានបាបឡើយ។ ព្រោះវាជាច្បាប់របស់ព្រះ។ ហើយនៅក្នុងគម្ពីម៉ានូសម៉េរតីភាគទី៥ឃ្លាទី៣៩-៤០បានលើកឡើងថា: ពិតប្រាកដណាស់ព្រះជាម្ចាស់បានបង្កើតសត្វពាហនៈមកនោះគឺដើម្បីបូជា ហេតុនេះសម្លាប់សត្វដើម្បីបូជាគឺមិនហៅសម្លាប់ឡើយ។ លើសពីនេះទៅទៀតបើ

អ្នកអានគម្ពី មហាបាហារ៉តអានុសសាណាបារីហ្វ ភាគទី៨៨៕ ដែលទាក់ទងនឹងលោក បានដាហ្វាស ជាប្អូនទីប្រាំនិងលោកយូទីសតីរ៉ាជាបងប្រុសធំ។ បានសួរ បាហីសាម៉ា។ ខណៈដែលគាត់កំពុងគោរពវិញ្ញាណរបស់លោក(បូចាយ៉ាក់ណា)អ្នកសម័យមុន។ បានសួរ បាហីសាម៉ាថាតើចំណីអាហារបែបណាដែលយើងត្រូវយកមកបូជាដើម្បីឲ្យអ្នកសម័យមុននោះស្ងប់ចិត្ត។ បាហីសាម៉ា បានឆ្លើយថាៈ ប្រសិនបើអ្នកសែនអាហារុក្ខជាតិ គឺព្រលឹងអ្នកសម័យមុននិងយល់ព្រមបានមួយខែ។ បើអ្នកសែនត្រីពួកគេនឹងយល់ព្រមរយៈពេលពីរខែ។ បើអ្នកសែនសាច់ពួកគេនឹងយល់ព្រមបានរយៈពេលបីខែ។ បើអ្នកសែនទន្សាយពួកគេនឹងយល់ព្រមរយៈពេលបួនខែ។ បើអ្នកសែនសត្វចៀមពួកគេនឹងយល់ព្រមរយៈពេលប្រាំខែ។ បើអ្នកសែនជ្រូកពួកគេនឹងយល់ព្រមរយៈពេប្រាំមួយខែ។ បើអ្នកសែនសត្វស្លាបពួកគេនឹងយល់ព្រមរយៈពេលប្រាំពីរខែ។ បើអ្នកសែនពពែពួកគេនឹងយល់ព្រមរយៈពេលប្រាំបីខែ។ ហើយបញ្ជីចេះតែទៅមុខ។ បើអ្នកសែនក្របីពួកគេនឹងយល់ព្រមរយៈពេលដប់មួយខែ។ ហើយបើអ្នកសែនសាច់គោពួកគេនឹងយល់ព្រមរយៈពេលមួយឆ្នាំពេញ។ នេះជាសាច់គោ។ ហើយបើអ្នកសែនសាច់រមាសអ្នកសម័យមុននឹងព្រមធ្វើជាភ្ញៀវរបស់យើងដោយគ្មានការធុញទ្រាន់ឡើយ។ បញ្ជីធំមែនចូរគិតមើល បន្លែ ត្រី សាច់ ទន្សាយ គឺមាននៅក្នុងបញ្ជីទាំងអស់។ ដូច្នេះបើអ្នកអានគម្ពីសាសនាហិណ្ឌូ គឺបានអនុញ្ញាតិអោយបរិភោគសាច់។

ក្រោយមកពួកហិណ្ឌូបានទទួលឥទ្ធិពលពីអ្នកដំទៃ។ ហើយពួកគេព្យាយាមយកទស្សនៈពីអ្នកដំទៃ ដោយកែសាសនារបស់គេឲ្យទៅជាសានាដែលបរិភោគរុក្ខជតិតែប៉ុណ្ណោះ ខណៈដែលសាសនាហិណ្ឌូមិនមែនជាសាសនាដែលបរិភោគតែរុក្ខជាតិប៉ុណ្ណោះទេ។ ជាធម្មតាបើអ្នកសួរពួកគាត់ថាតើហេតុអ្វីបានជាពួកលោកបរិភោគតែរុក្ខជាតិ? ពួកគាត់នឹងតបមកយើងវិញថា ពីព្រោះសម្លាប់សត្វគឺបាប ព្រោះថា ការសម្លាប់សត្វដែលមានជីវិតគឺបាប។ ហើយខ្ញុំក៏បានប្រាប់គាត់វិញថាៈ ខ្ញុំយល់ស្របនិងអ្នក។ ប្រសិនបើបុគ្គលណាម្នាក់អាចរស់បានដោយមិនបានសម្លាប់សត្វមានជីវិតនោះ គឺខ្ញុំស្របនឹងអ្នក។ ការស្រាវជ្រាវសព្វថ្ងៃបានឲ្យយើងដឹងថា សូម្បីតែរុក្ខជាតិក៏មានជីវិតដែរ. មនុស្សជំនាន់មុនមិនទាន់ដឹងថារុក្ខជាតិមានជីវិតឡើយ។ ប៉ុន្តែឥឡូវខុសពីមុន។ ហើយពួកគេតបថា ទេទេ!!ពួកយើងដឹងថារុក្ខជាតិមានជីវិត។ ក៏ប៉ុន្តែរុក្ខជាតិគ្មានអារម្មណ៍ឈឺឡើយ ហេតុនេះការសម្លាប់សត្វមានបាបធំជាងសម្លាប់រុក្ខជាតិ។ តែបច្ចុប្បន្នការស្រាវជ្រាវមានការរីកចំរើន ហើយបានរកឃើញថា រុក្ខជាតិក៏មានអារមណ៍ឈឺដែរ។ ពិតមែនយើងមិនបានឮការយំស្រែករបស់រុក្ខជាតិ តែវាមានអារមណ៍ឈឺដែរ។ វាមិនមានប្រព័ន្ធទំនើបទេតែវាមានអារមណ៍ឈឺ។ មានការពិសោធមួយនៅអាមេរិកបានបញ្ជាក់ថា មានកសិករម្នាក់បានធ្វើការកែឆ្នៃមួយដែលមនុស្សអាចស្តាប់សំលេងយំរបស់រុក្ខជាតិបាន។ ពីព្រោះត្រចៀកមនុស្សអាចស្តាប់ការរំញោចរវាង ម្តី( ឪសបិល

ទៅ២០០០០ឪសបិលក្នុងមួយវិនាទី)៕ អ្វីដែលតិចឬច្រើនជាងនេះត្រចៀកមនុស្សមិនអាចស្តាប់បានឡើយ។ ដូចនេះអញ្ចឹងក្រោមពីម្ភៃឪសបិល ខ្ញុំស្តាប់មិនឮទេ។ តែបើខ្ញុំគ្រវីវាកាន់តែខ្លាំងឡើងគឺខ្ញុំអាចស្តាប់ឮព្រោះវាខ្ពស់ជាង២០ឪសបិល។ សត្វឆ្កែអាចស្តាប់បានដល់ទៅ៨០០០០ឪសបិល។ អ្នកប្រហែលជាធ្លាប់ឮពីកញ្ចែស្តាប់របស់ឆ្កែ។ កញ្ចែនោះបានឲ្យសញ្ញា។ ការរំញោចរវាង២០ទៅ៨០០០០ឪសបិលមនុស្សមិនអាចស្តាប់ឮបានឡើយតែសត្វឆ្កែអាចស្តាប់ឮបន្ទាប់មកវានិងទៅរកម្ចាស់របស់វា។ ហេតុនេះហើយបានជាមនុស្សមិនអាចស្តាប់ឮសំលេងយំរបស់រុក្ខជាតិបានឡើយ។ ការពិសោធដែលបានធ្វើឡើងនៅអាមេរិក ដែលថាបុរសម្នាក់បានឆ្នៃរបស់មួយសម្រាប់ស្តាប់សំលេងយំរបស់រុក្ខជាតិនៅពេលដែលវាត្រូវការទឹក ហើយរបស់នោះអាចបំលែងសំលេងនោះដើម្បីឲ្យយើងស្តាប់ឮ។ ការស្រាវជ្រាវសព្វថ្ងៃបានបញ្ជាក់ថា រុក្ខជាតិក៏មានអារមណ៍ឈឺដែរ។ ហេតុនេះអ្នកមិនមែនមុស្លីមបច្ចុប្បន្នគេជជែកនិងខ្ញុំហើយគេនិយាយថាៈ ត្រឹមត្រូវលោកសាកីរណៃខ្ញុំយល់ស្របនិងលោក រុក្ខជាតិមានជីវិតហើយមានអារមណ៍ឈឺក៏ប៉ុន្តែបើប្រៀបធៀបនឹងសត្វពាហនៈវាឈឺតិចជាង។ សត្វពាហនៈមានអារម្មណ៍ប្រាំ ហើយរុក្ខជាតិមានអារម្មណ៍បី។ ហេតុនេះបានជាខ្ញុំថា ខ្ញុំយល់ស្របនិងអ្នកក្នុងគោលដៅជជែកគ្នានិងពិភាក្សា។ រុក្ខជាតិមានអារម្មណ៍បីហើយសត្វពាហនៈមានអារម្មណ៍បួន។ ខ្ញុំសួរពួកគាត់ថា ឧបមាថា អ្នកមានប្អូនប្រុស

ម្នាក់កើតមកថ្លង់និងគ។ ហើយមានមនុស្សម្នាក់មកសម្លាប់ប្អូនអ្នក តើអ្នកនឹងប្រាប់ចៅក្រមថា ចូរលោកចៅក្រមដាក់ទណ្ឌកម្មលើជនល្មើសបន្តិចបានហើយ ព្រោះអ្នកស្លាប់មានអារម្មណ៍ឈឺតិចជាងអ្នកដទៃ? ជាការពិតណាស់ខ្ញុំនឹងទៅជួបចៅក្រមហើយប្រាប់ឲ្យគាត់ដាក់ទណ្ឌកម្មលើជនល្មើសទ្វេដងពីព្រោះប្អូនខ្ញុំមិនបានធ្វើខុសអ្វីទេ គាត់ស្តាប់មិនបាននិងនិយាយមិនកើត ចូរដាក់ទណ្ឌកម្មលើគាត់ទ្វេដង។ សមរម្យអត់ដែលនិយាយថា មានអារម្មណ៍តិច ដូច្នេះដាក់ទោសតិចដែរ!!! ឥស្លាមមិនគិតអារម្មណ៍តិចឬច្រើនទេ។ ក្នុងគម្ពីគួរអានជំពូកទី២ឃ្លាទី១៦៨បានប្រាប់ថា ចូរពួកអ្នកបរិភោគនូវអ្វីដែលស្អាតស្អំលើផែនដីនេះចុះ។ ចូរពួកអ្នកបរិភោគចុះរបស់ដែលស្អាតស្អំ អ្វីដែលគេអនុញ្ញាតិឲ្យបរិភោគ អ្វីដែលល្អស្អាតស្អំហើយគេអនុញ្ញាតិគឺអាចបរិភោគបាន ទាក់ទងនិងអ្នកមិនមែនមុស្លីមដែលមិនបរិភោគសាច ប្រសិនបើអ្នកស្របនិងគេលើ ជាការល្អចាំបាច់ត្រូវតែបញ្ឈប់ការសម្លាប់សត្វ។ ដូចអ្នកបានដឹងស្រាប់ហើយសត្វចៀមមាចំនួនកើនឡើងលឿនណាស់។ ប្រសិនបើយើងបញ្ឈប់ការបរភោគសាច់ សត្វចៀមនិងមានចំនួនហួសចំណុះនៅលើពិភពលោក។ ដូចបច្ចុប្បននេះចំនួនប្រជាជនក្នុងប្រទេមួយចំនួននៅលើពិភពលោក
មានការកើនឡើងច្រើនណាស់ដូចជា ចិន ឥណ្ឌា។ ក៏ដូច្នោះដែរបញ្ហាសត្វចៀមលើសចំណុះ។ ខ្លួនខ្ញុំផ្ទាល់បើអ្នកមិនមែនមុស្លីមមិនបរិភោគសាច់ គឺសម្រាប់ខ្ញុំគ្មានបញ្ហាឡើយ។ ជឿខ្ញុំចុះសម្រាប់ខ្ញុំគឺគ្មានបញ្ហា

ឡើយព្រោះ អ្នកមិនមែនមុស្លីមនៅប្រទេសឥណ្ឌា បើពួកគាត់ទាំងអស់គ្នាចាប់ផ្ដើបបរិភោគសាច់នោះ ប្រហែលជាសាច់គោ ចៀមឡើងថ្លៃហើយ។ ដូច្នេះសម្រាប់ខ្ញុំគឺគ្មានបញ្ហាឡើយ។ បើពួកគាត់មិនបរិភោគសាច់គឺគ្មានបញ្ហាឡើយសម្រាប់ខ្ញុំ។ តែបើមានបុគ្គលណាម្នាក់ប្រាប់ខ្ញុំថាបរិភោគសាច់មិនបានឡើយព្រោះបាប ភ្លាមៗនោះខ្ញុំនិងបកស្រាយប្រាប់គាត់យ៉ាងក្បោះក្បាយ។

# សំនួរទី៩

# ហេតុអ្វីបានជាមុស្លីមធ្វើការសម្លាប់សត្វ?

អ្នកមូស្លីមបរិភោគសាច់ ចុះហេតុអ្វីបានជាមុស្លីមធ្វើការសម្លាប់សត្វដោយគ្មានធម៌មេតាបន្តិចសោះ? ព្រោះនៅពេលអ្នកសម្លាប់អ្នកបានបង្អង់ក្នុងការសម្លាប់ គឺហាក់បីដូចជាធ្វើបាបលើសត្វពាហនៈណាស់ពួកអ្នកជាមនុស្សគ្មានធម៌មេតាឡើយ នៅប្រទេសឥណ្ឌាមានក្រុមមួយឈ្មោះថា-ស៊ីខ៏-ពួកគេមានការជំទាស់និងអ្នកមុស្លីម ហើយក្រុមនោះ-ស៊ីខ៏-បាននិយាយថាៈ ពួកអ្នកគ្មានការអាណិតនិងធម៌មេតាឡើយ ហេតុអ្វីបានជាពួកអ្នកធ្វើបាបសត្វពាហនៈដូច្នោះ? អ្នកអាចប្រើខ្សែភ្លើងឆក់វិញក៏បានដែរ អ្នកមុស្លីមបានតបវិញថាៈ ពួកអ្នក-ស៊ីខ៏-កំសាកណាស់ពួកអ្នកតទល់និងសត្វពីខាងក្រោយ ចំណែកពួកយើងជាអ្នកដែលក្លាហាន ព្រោះយើងតទល់និងសត្វពីខាងមុខ នេះជាប្រាជ្ញារបស់គាត់ប៉ុណ្ណោះ វាមិនមែនជាមូលហេតុនៃការសំលេះឡើយ នេះជាប្រាជ្ញារបស់គាត់ព្រោះគាត់គ្មានអ្វីដើម្បីឆ្លើយតប គឺគាត់តបថា ពួកយើងជាអ្នកក្លាហាន យើងតទល់ពីខាងមុខ ចំណែកពួកអ្នកវិញកំសាកណាស់តទល់ពីខាងក្រោយ ឥឡូវ មូលហេតុដែលសមរម្យដែលយើងធ្វើការសម្លេះនោះគឺ ហេតុអ្វីបានជាយើងសម្លេះសត្វតាមរបៀបឥស្លាម? របៀបសម្លេះក្នុងឥស្លាម គឺត្រូវប្រើកាំបិតដែលមុតបំផុត និងសម្លេះឲ្យលឿនបំផុត

ដើម្បីបន្ធូរការឈឺចាប់សម្រាប់សត្វ ទីពីរៈ គឺយើងចាប់ផ្តើមផ្តាច់បំពង់ខ្យល់និងសសៃឈាម និងបំពង់ក ដោយមិនផ្តាច់ខួរឆ្អឹងខ្នងឡើយ។ ព្រោះថា កាលណាប៉ះពាល់ដល់ខួរឆ្អឹងខ្នង វាបណ្តាល់ឲ្យប៉ះពាល់ដល់សសៃដែលទាក់ទងនឹងបេះដូង ដែលជាហេតុបណ្តាលឲ្យគាំងបេះដូង ហេតុនេះមិនចាំបាច់ផ្តាច់ខួរឆ្អឹងខ្នងឡើយ យើងផ្តាច់បំពង់ក និងបំពង់ខ្យល់ និងសសៃឈាម ហើយយើងលែងឲ្យបេះដូងធ្វើចលនា ព្រោះនៅពេលដែលបេះដូងធ្វើចលនា គឺឈាមដែលនៅក្នុងខ្លួននឹងហូរចេញ ហើយការស្រាវជ្រាវបានឲ្យដឹងថា ឈាមជាកន្លែងផ្ទុកមេរោគនិងបាក់តេរីនិងជាតិពល់ ហេតុនេះហើយបានជាយើងឲ្យឈាមហូរចេញពីខ្លួនសត្វនោះ...ហេតុអ្វីបានជាយើងធ្វើដូច្នោះ? គឺដើម្បីយើងសម្អាតខ្លួនវាសម្អាតមេរោគ បាក់តេរីនិងជាតិពល់ពីខ្លួនវា វាជាការអនាម័យមួយដ៏ល្អបំផុត លើសពីនេះទៅទៀត ការសម្លេះសត្វតាមរបៀបឥស្លាម វាអាចរក្សាសាច់អោយនៅស្រស់បានយូរបើប្រៀបនិងសត្វដែលសម្លាប់ប្រើខ្សែភ្លើងនោះ ព្រោះចំណុះឈាមដែលនៅសល់គឺបន្តិចបន្តួច ហេតុនេះសាច់អាចនៅស្រស់បានរយៈពេលយូរ លើសពីនេះទៀតមានមនុស្សមួយចំនួនយល់ច្រឡំ ដោយពួកគេគិតថា ការសម្លេះតាមរបៀប ឥស្លាម គឺធ្វើឲ្យសត្វនោះមានការឈឺចាប់ខ្លាំង ការស្រាវជ្រាវសព្វថ្ងៃបានឲ្យដឹងថា នៅពេលដែលយើងសម្លេះ នៅពេលដែលយើងអារបំពង់ក និងបំពង់ខ្យល់ សសៃឈាម ពិតប្រាកដ៏ណាស់សសៃដែលទាក់ទងនិងខួរក្បាលក៏

ត្រូវបានផ្តាច់ដែរ ហើយវាជាចំណុចគ្រប់គ្រងចំពោះការឈឺចាប់។ហេតុនេះវាស្លាប់ដោយគ្មានការឈឺចាប់ឡើយ ផ្ទុយទៅវិញវាស្លាប់យ៉ាងស្រួលបំផុត ផ្ទុយពីការឆក់ខ្សែភ្លើង ព្រោះវាមិនងាយស្លាប់ភ្លាមៗឡើយ ហេតុនេះការសម្លេះតាមរបៀបឥស្លាមវាជាការល្អបំផុត ហើយសត្វនោះវាស្លាមយ៉ាងស្រួលបំផុត ការកំរើករបស់សត្វមិនមែនបញ្ជាក់ថាវាឈឺនោះទេ វាគ្រាន់តែជាចលនាចុះឡើង ដើម្បីបង្ហូរឈាមឲ្យចេញពីខ្លួនប៉ុណ្ណោះ វាធ្វើចលនាកំរើកដើម្បីបង្ហូរឈាម មិនមែនព្រោះការឈឺចាប់ឡើយ ហេតុនេះការសម្លេះតាមរបៀបឥស្លាម វាជាវិធីមួយដ៏ប្រសើរនឹងត្រឹមត្រូវបំផុត ហើយពិតជាមានធម៌មេតាបំផុតក្នុងកាសម្លេះនេះ។

# សំនួរទី១០

# ការបរិភោគសាច់សត្វ នឹងធ្វើឲ្យមានចរិតដូចសត្វ?

អ្នកមិនមែនមុស្លីមជាច្រើននិយាយថាៈ នែ!ពួកអ្នកឥស្លាមឯងបរិភោគសាច់សត្វ ដូច្នេះពួកអ្នកមានចរិតដូចសត្វអ៊ីចឹង។ របៀបព្រៃផ្សៃ និងសាហាវ ពួកអ្នកមុស្លីមបរិភោគសាច់ ហើយមានចរិតកាចសាហាវដូចសត្វអ៊ីចឹង។ ហើយខ្ញុំចាំបាច់ត្រូវតែបញ្ជប់ពួកគេ។ តាមការសិក្សាស្រាវជ្រាវបានឲ្យដឹងថា រាល់អ្វីដែលយើងបរភោគនោះ វានឹងមានឥទ្ធិពលមកលើចរិតរបស់យើង ហើយខ្ញុំពិតជាយល់ស្របនឹងពួកគេថា អ្វីដែលអ្នកបរិភោគវាមានឥទ្ធិពលដល់ចរិតរបស់អ្នក។ ហេតុនេះយើងជាអ្នកមុស្លីមគេហាមមិនឲ្យបរិភោគសត្វដែលកាចសាហាវ។ ដូចជាខ្លាដំបង ខ្លាខិនតោ និងសត្វដែលកាចសាហាវនោះ។ គេអនុញ្ញាតឲ្យយើងបរិភោគសត្វដែលស្លូតៗតែប៉ុណ្ណោះ ដូចជា គោ ចៀម ពពែ ព្រោះយើងស្រលាញ់សន្តិភាព។ ទាំងនោះជាសត្វពាហនៈដែលស្លូតបូត។ ក្នុងគម្ពីគួរអានជំពូកទី៧ឃ្លាទី១៥៧បានប្រាប់ថាៈ គេអនុញ្ញាតឲ្យយើងបរិភោគសត្វដែលស្លូតបូតប៉ុណ្ណោះ សត្វពហានៈ។ គាត់(ណាពីមូហាំម៉ាត់)ប្រើពួកគេឲ្យធ្វើល្អ និងហាមឃាត់ពួកគេពីប្រការអាក្រក់ ហើយអនុញ្ញាតសម្រាប់ពួកគេនូវអ្វីដែលល្អ និងហាមឃាត់ពួកគេពីអ្វីដែលអាក្រក់។ ហើយទ្រង់មានបន្ទូល

នៅក្នុងជំពូកទី៥៩ឃ្លាទី៧ថា ហើយអ្វីដែលអ្នកនាំសារបាននាំមកឲ្យពួកអ្នក ចូរពួកអ្នកទទួលយកចុះ ហើយអ្វីដែលគាត់បានហាមឃាត់ពួកអ្នកពីវា ចូរពួកអ្នកបោះបង់ចោលចុះ។ ហេតុនេះរាល់អ្វីដែលអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់បានហាមឃាត់គឺយើងអ្នកមុស្លីមត្រូវចៀសឱ្យឆ្ងាយ។ ហើយមានហាទីសជាច្រើននៅក្នុងសៀវភៅពូខរីនិងមុស្លីម អ៊ិបនូម៉ាជះដែលបានបកស្រាយពីការហាមប្រាមការហូបសាច់សត្វកាចសាហាវទាំងនេះ។ បានលើកឡើងនៅក្នុងសៀវភៅមុស្លីម ជំពូកសត្វគេបរបាញ់និងសំឡេះ។ ហាទីសទី៤៧៥២ ហើយនៅក្នុងមុសណាត់អ៊ិបនូម៉ាជះជំពូកទី១៣លេខទី៣២៣២/៣២៣៤ ប្រភេទអាហារផ្សេងៗដែលណាពីមូហាំម៉ាត់បានហាម ក្នុងនោះមាន រាល់សត្វសាហាវណាដែលមានចង្កោម។ ដូចជា តោ ខ្លា ឆ្មា ឆ្កែ ចចក ឆ្កែព្រៃ ទាំងនេះត្រូវបានគេហាមឃាត់។ និងពួកសត្វកកេរមួយចំនួនទៀតដូចជាកណ្តុរ និងទន្សាយដែលមានក្រញាំ។ និងសត្វល្មូនមួយចំនួនដូចជា ពស់ ក្រពើ ទាំងនេះត្រូវបានហាមឃាត់។ ហើយណាពីមូហាំម៉ាត់បានហាមរាល់សត្វស្លាបណាដែលមានក្រញាំ។ ដូចជា ឥន្ទ្រី ខ្លែង ក្អែក សត្វទីទុយ ។ល។ ទាំងនេះគឺត្រូវបានហាមឃាត់។

# សំនួរទី១១

# មូស្លីមគោរពកាក់ហ្ពះ?

ឥឡូវយើងនឹងពិភាក្សាសំនួរទីដប់មួយ ដែលឮសុសសាយចេញពីអ្នកមិនមែនមូស្លីម ការភាន់ច្រឡំទី១១ក្នុងគំនិតអ្នកមិនមែនមូស្លីម នោះគឺ ប្រសិនបើឥស្លាមប្រឆាំងនឹងកាគោរពរូបបដិមា ចុះហេតុអ្វីបានជាមូស្លីមគោរពកាក់ហ្ពះ? ហើយឆ្លើយតបនឹងការចោទប្រកាន់នេះគឺ គ្មានអ្នកមូស្លីមណាម្នាក់គោរពកាក់ហ្ពះទេ កាក់ហ្ពះគ្រាន់តែជាទិសដៅ កន្លែងតម្រង់ទិស ដូចបានបញ្ជាក់ក្នុងគម្ពីរគួរអាន ជំពូកទី២ឃ្លាទី១៤៤ ដូច្នេះចូរអ្នកបែរមុខរបស់អ្នកទៅទិសម៉ាស្ជិទិលហារ៉មចុះ។ ហើយទោះបីពួកអ្នកនៅទីណាក៏ដោយ ចូរពួកអ្នកបែរមុខពួកអ្នកទៅរកទិសនោះ ដូច្នេះកាក់ហ្ពះគឺជាទិសដៅ ឧទាហរណ៍ថា បើអ្នកមូស្លីមចង់សឡាតនៅកន្លែងនេះ ហើយពួកគេមួយចំនួនបាននិយាយថាយើងត្រូវសំដៅទៅទិសខាងជើងហើយអ្នកខ្លះទៀតថាទៅខាងត្បូង ហើយអ្នកខ្លះទៀតថាទៅខាងកើតហើយអ្នកខ្លះទៀតថាទៅខាងលិច ដូច្នេះដើម្បីការប្រមូលផ្តុំនិងបង្រួបការបង្រួមតែមួយគឺអ្នកមូស្លីមទាំងអស់ត្រូវតែសំដៅទៅទិសតែមួយគត់គឺកាក់ហ្ពះ ហេតុដូច្នេះកាក់ហ្ពះគឺជាកន្លែងតម្រង់ទិសរបស់ពួកយើង ហើយអ្នកដែលគូរផែនទីពិភពលោកមុនគេគឺអ្នកមុស្លីម នៅក្នុងឆ្នាំ១១៥៤លោកអ៊ីតរីស៊ីគឺជាអ្នកគូរផែនទីពិភពលោកមុនគេ នៅពេល

ដែលអ្នកមូស្លីមគួរផែនទីនោះគឺពួកគេបានយកប៉ូលខាងត្បូងដាក់ខាង លើ ប៉ូលខាងជើងដាក់ខាងក្រោម ហើយកាក់ហ្គះនៅចំណុចកណ្ដាល ក្រោយមក ពួកភូមិវិទូលោកខាងលិចបានយកផែនទីដាក់បញ្ច្រាសវិញ ប៉ូលខាងជើងដាក់ខាងលើហើយខាងត្បូងដាក់ខាងក្រោមវិញទោះបីយ៉ាង ណាក៏ដោយក៏កាក់ហ្គះនៅចំកណ្ដាលដដែលសូមអរគុណចំពោះអល់ឡោះ ដូច្នេះទោះជាអ្នកនៅទីណាក៏ដោយក្នុងពិភពលោកយើងនេះ បើអ្នកនៅខាងជើងគឺអ្នកត្រូវតម្រង់ឆ្ពោះខាងត្បូងហើយផ្ទុយមកវិញ ហើយបើអ្នកនៅខាងកើតគឺត្រូវតម្រង់ឆ្ពោះទៅទិសខាងលិចហើយផ្ទុយមកវិញ កាក់ហ្គពះនៅចំកណ្ដាល ហើយបច្ចុប្បន្ននេះយើងជាអ្នកមូស្លីមនៅពេលយើងទៅម៉ាក់កះ ហើយខណៈដែលយើងកំពុងធ្វើអុំរ៉ោះឬហាជីឬតវាហ្វនោះគឺយើងនឹងដើរជុំវិញកាក់ពះ ល្អហើយអ៊ីចឹង!ចុះហេតុអ្វីបានជាអ្នកមូស្លីមដើរជុំវិញកាក់ហ្គះ? ពីព្រោះវាជាបទបញ្ជាពីអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហេតុនេះទើបយើងនាំគ្នាអនុវត្ត ក៏ប៉ុន្តែការបកស្រាយសមហេតុផលដែលនៅក្នុងគំនិតរបស់ខ្ញុំគឺរាល់រង្វង់មូលទាំងអស់វាមានចំណុចស្នូលតែមួយប៉ុណ្ណោះ ហេតុនេះរាល់ពេលដែលយើងដើរជុំវិញកាក់ហ្គះនោះគឺយើងទទួលស្គាល់ថាព្រះជាម្ចាស់គឺមានតែមួយគត់

លើសពីនេះទៅទៀតលោកអូម៉ើរពិនខតបដែលជាស្ដេចខលីហ្វតស្លាមទីពីរបានមានប្រសាសន៍ហើយពាក្យសំដីនេះមាននៅក្នុង សហីសពូខរីជំពូកអាលហាជ ភាគទី៥៦ ហាទីសលេខទី៦៧៥ អូម៉ើរបានចង្អុលទៅជុំ

ថ្មនោះហើយនិយាយថានេះជាដុំថ្មខ្មៅ វាមិនអាចផ្ដល់ផលប្រយោជន៍ឬគ្រោះថ្នាក់មកដល់រូបខ្ញុំឡើយក៏ប៉ុន្តែខ្ញុំឃើញរ៉សូលុលឡោះថើបវាដូច្នេះខ្ញុំក៏ថើបវាដែរ នេះបញ្ជាក់ថាដុំថ្មវាមិនអាចផ្ដល់ប្រយោជន៍ឬគ្រោះថ្នាក់ដល់នរណាម្នាក់ឡើយនេះជាភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថាយើងជាអ្នកមុស្លីមមិនមែនគោរពកាក់ហ្ពះឡើយ លើសពីនេះនៅសម័យរ៉សូលុលឡោះមានសហាហ្ពាត់ជាច្រើនដែលបានឡើងលើកាក់ហ្ពះដើម្បីអាហ្សាន-ប្រកាសហៅឱ្យគេមកថ្វាយបង្គំ- គ្មានអ្នកដែលគោរពរូបបដិមាណាម្នាក់ឡើងជាន់ពីលើអ្វីដែលគេគោរពនោះជាដាច់ខាត នេះជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថាយើងជាអ្នកមូស្លីមមិនគោរពកាក់ហ្ពះឡើយវាគ្រាន់តែជាកន្លែងតម្រង់ទិសរបស់យើងប៉ុណ្ណោះ។

# សំនួរទី១២

## ហេតុអ្វីបានជាមិនអនុញ្ញាតឲ្យអ្នកមិនមែនមូស្លីម ចូលទឹកដីម៉ាកកះនិងម៉ាឌីណះ?

ប្រសិនបើឥស្លាមជាសាសនាសកល ចុះហេតុអ្វីបានជាមិនអនុញ្ញាតឲ្យអ្នកមិនមែនមូស្លីម ចូលទឹកដីម៉ាកកះនិងម៉ាឌីណះ? ប្រសិនបើឥស្លាមជាសាសនា សម្រាប់មនុស្សទូទៅមែន?ចុះហេតុអ្វីបានជាមិនអនុញ្ញាតឲ្យអ្នកមិនមែនមូស្លីម ចូលក្នុងទឹកដីម៉ាកកះនិងម៉ាឌីនះ? ឆ្លើយនឹងសំនួរនេះមានដូចខាងក្រោមៈ គ្រប់ប្រទេសទាំងអស់មានតំបន់មួយដែលគេហៅថា តំបន់សុវត្ថិភាព។ ហើយតំបន់សុវត្ថិភាពគឺជាតំបន់មួយដែលគ្មាននរណាម្នាក់ អាចចូលបានក្រៅពីទាហាននិងបុគ្គលមួយចំនួនដែលគេចាត់តាំងឱ្យការពារប្រទេស។ ដ្បិតតែខ្ញុំជាពលរដ្ឋឥណ្ឌា តែគេមិនអនុញ្ញាតឲ្យខ្ញុំចូលតំបន់សុវត្ថិភាពទេ ហើយខ្ញុំក៏មិនជំទាស់ដែរ។ មិនបានជាដាច់ខាត់ គឺសម្រាប់តែអ្នកដែលគេចាត់តាំងឲ្យការពារជាតិនិងសន្តិសុខជាត់ប៉ុណ្ណោះដែលអាចចូលបាន។ ដូច្នោះដែរម៉ាកកះនិងម៉ាឌីណះ ទឹកដីពិសិដ្ឋទាំងពីរនេះជាតំបន់សុវត្ថិភាពសម្រាប់ឥស្លាម។ ដូច្នេះ សម្រាប់តែអ្នកមានជំនឿ និងស្រលាញ់ ឥស្លាម ហានបូជាជីវិតដើម្បីឥស្លាមប៉ុណ្ណោះដែលគេអនុញ្ញាតឲ្យចូលតំបន់នេះ។ ហេតុនេះ

ហើយបានជាទ្រង់មានបន្ទូលថាៈ ដូច្នេះ កុំឲ្យពួកគេទៅក្បែរម៉ាស្ជិទអាល់ហារ៉មបន្ទាប់ពីឆ្នាំនេះទៅ។ គ្រាន់តែអល់ឡោះហាមអ្វីមួយគឺពួកយើងយល់ព្រមតែម្តង។ មូលហេតុផ្សេងទៀតនោះគឺៈ នៅពេលអ្នកចង់ចូលប្រទេសណាមួយ គឺអ្នកត្រូវតែមានទិដ្ឋាការ។ អ្នកមិនអាចចូលប្រទេសនោះដោយគ្មានទិដ្ឋាការនោះឡើយ។ ហើយប្រទេសដែលពិបាកយកទិដ្ឋាការជាងគេគឺសហរដ្ឋអាមេរិក។ គេសួរអ្នកនូវសំនួរជាច្រើន ហើយបច្ចុប្បន្នគេសួរថា តើអ្នកជាភេរវករឬ? ហើយហាក់ដូចជាមានអ្នកឆ្លើយថា បាទអ៊ីចឹង!! ខ្ញុំចង់សួររដ្ឋាភិបាលអាមេរិកថា តើមានអ្នកណាម្នាក់ឆ្លើយថា បាទទេ? តើអ្នកជាសមាជិកអង្គការភេរវកម្មណាមួយ? ពិតជាចំឡែកណាស់!!! ខ្ញុំចង់សួរពួកគេថា តើមានអ្នកណាម្នាក់សរសេរថា បាទទេ!!! បាទ ខ្ញុំជាភេរវករ ខ្ញុំជាសមាជិករបស់អង្គការភេរវកម្ម។ ពួកគេមានសំនួរជាច្រើន ហើយអ្នកត្រូវបំពេញរាល់សំនួរទាំងនោះ ដើម្បីទទួលបានទិដ្ឋាការ។ លើកទីមួយនៅឆ្នាំ១៩៨៧ខ្ញុំបានទៅប្រទេសសិង្ហបុរីហើយគេបានសរសេរក្នុងសំណុំបែបបទអន្តោប្រវេសន៍មួយថា ទោសប្រហារជីវិតសម្រាប់អ្នកជួញដូរគ្រឿងញៀន។ មានន័យថា ប្រសិនបើគេចាប់អ្នក ហើយនៅក្នុងខ្លួនអ្នកមានគ្រឿងញៀននោះ អ្នកត្រូវតែស្លាប់។ អ្នកមិនអាចនិយាយថា ទោសប្រហារជីវិតគឺជាទោសមួយធ្ងន់ធ្ងរបំផុត។ ទោះជាអ៊ីចឹងក៏ដោយ ប្រសិនបើអ្នកចង់ចូលអ្នកត្រូវតែយល់ព្រម បើមិនយល់ព្រមកុំមកអី។ ដូច្នេះប្រសិនបើអ្នកចង់ទទួលបានទិដ្ឋាការនោះ អ្នក

ត្រូវតែយល់ព្រមលើច្បាប់ប្រទេសនោះ។ ឥឡូវ ទិដ្ឋាការចូលម៉ាកកះនិង ម៉ាឌីណះ គឺអ្នកគ្រាន់តែពោលថា៖ គ្មានទេព្រះពិតលើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ។ បុគ្គលណាពោលថា៖ គ្មានទេព្រះពិត លើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ គឺគេទទួលបានទិដ្ឋាការចូលម៉ាកកះនិងម៉ាឌីណះទ។ កន្លែងទាំងពីរនេះជាតំបន់សុវត្ថិភាព ហើយទិដ្ឋាការដើម្បីចូលទៅកាន់ទីនោះគឺ អ្នកធ្វើសាក្សីថា៖គ្មានទេព្រះពិត លើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ។

# សំនួរទី១៣

# ហេតុអ្វីបានជាឥស្លាមហាមមិនឲ្យបរិភោគសាច់ជ្រូក?

ជាសំនួរដែលល្បីសុសសាយ បើតាមយោបល់ខ្ញុំ គឺ តើហេតុអ្វីបានជាឥស្លាមហាមមិនឲ្យបរិភោគសាច់ជ្រូក? ដើម្បីឆ្លើយនឹងសំនួរនេះគឺក្នុងគម្ពីរគួរអានបានលើកឡើងមិនតិចជាងបួនកន្លែងឡើយ។ ក្នុងជំពូកទីពីរឃ្លាទី១៧៣ ក្នុងជំពូកទី៥ឃ្លាទី៣ ក្នុងជំពូកទី៦ឃ្លាទី១៤៥ ក្នុងជំពូកទី១៦ឃ្លាទី១១៥ អល់ឡោះបានហាមពួកអ្នក(បរិភោគ)សត្វស្លាប់ ឈាម សាច់ជ្រូក និងអ្វីដែលគេសំឡេះដើម្បីបូជាម្ចាស់ផ្សេងពីអល់ឡោះ ..។ជំពូកទី៥ឃ្លាទី៣។ ហេតុនេះក្នុងគួរអានមានបួនកន្លែងដែលបញ្ជាក់ថា ការបរិភោគសាច់ជ្រូកគឺត្រូវបានហាម។ គម្ពីគួរអានបានប្រាប់ដូច្នេះ ហើយអ្នកមុស្លីមក៏បានជឿលើវាផងដែរ ការហាមនេះក៏មានលើកឡើងក្នុងគម្ពីរជីហ្វ និងគម្ពីរគ្រីស្តសាសនា។ នៅក្នុងសៀវភៅលេវីវិន័យ ជំពូកទី១១ឃ្លាទី៧និងទី៨ បានលើកឡើងថា ជ្រូកជាសត្វកខ្វក់ព្រោះវាប្រើក្រចកជើងឈ្លូសនិងបំបែកវាដោយក្រចកជើងទាំងពីររបស់វា ប៉ុន្តែវាមិនទំពាររទេ។ កុំបរិភោគសាច់វា ហើយកុំប៉ះពាល់ខ្លួនវា ព្រោះវាជាសត្វកខ្វក់។ នេះបញ្ជាក់ថា គម្ពីរសម័យមុនក៏បានហាមមិនឲ្យបរិភោគសាច់ជ្រូក

ដែរ សូម្បីកាន់វាក៏គេហាមដែរ។ មានឯកសារផ្សេងទៀតនៅក្នុងសៀវភៅ( ទុតិយកថា )ជំពូកទី១៤ឃ្លាទី៨ក៏បានបញ្ជាក់ដូចគ្នាដែរ។ ហើយជ្រូកជាសត្វដែលប្រើក្រចកជើងឈូសដី វាមិនទំពារទេ ហើយវាជាសត្វកខ្វក់ ដូច្នេះកុំបរិភោគសាច់វា ហើយកុំប៉ះខ្លួនវា។ ដូច្នោះដែរលមានលើកឡើងនៅក្នុងគម្ពីរ អេសាយជំពូកទី៦៥ឃ្លាទី២ដល់ទី៥៕ ចាំបាច់មិនត្រូវបរិភោគសាច់ជ្រូកឡើយ។ ដូច្នេះ យោងតាមសៀវភៅគ្រីស្តនិងសៀវភៅជ្វីហ្វគឺ បរិភោគសាច់ជ្រូកត្រូវបានហាម( ហារ៉ាម )។ ប្រសិនបើអ្នកអានគម្ពីរហិណ្ឌូ។ សូម្បីក្នុងគម្ពីរហិណ្ឌូក៏បានបញ្ជាក់ដែរថា ការបរិភោគសាច់ជ្រូកត្រូវបានហាម។ បានលើកឡើងក្នុងគម្ពីរមនូសម៍តីថាៈ ការពិតណាស់បុរសអ៊ីបរ៉ហ៊ីមីនោះ(បុគ្គលដែលល្អ)។ គឺគេមិនត្រូវបរិភោគផ្សិត ឬខ្ទឹមបារាំង ឬសាច់ជ្រូកឡើយ។ លើសពីនេះទៅទៀតក្នុងគម្ពីរវិស្នុសាស្រ្តក៏បានបញ្ជាក់ដែរថា បុគ្គលណាហើយលក់សាច់ជ្រូកគឺត្រូវកាត់ដៃនិងជើងរបស់គេទាំងពីរឆ្លាស់គ្នា។ ទណ្ឌកម្ម!!នេះមិនមែននៅក្នុងគម្ពីរគួរអានឬហាទីសឡើយ តែវានៅក្នុងគម្ពីរបស់ហិណ្ឌូ។ គឺត្រូវកាត់ដៃ ប្រសិនបើអ្នកលក់សាច់ជ្រូក តោះយើងវិភាគមើលតើអ្វីទៅជាមូលហេតុដែលសមហេតុផល យោងតាមគម្ពីរគ្រីស្ត គម្ពីរជីហ្វ គម្ពីរឥស្លាម បានបញ្ជាក់យ៉ាងច្បាស់ក្នុងគម្ពីរទាំងនោះថា ការបរិភោគសាច់ជ្រូកគឺត្រូវបានហាម។ តែយើងត្រូវវិភាគមើលថា តើមូលហេតុអ្វីបានជាគេហាមមិនឲ្យបរិភោគសាច់ជ្រូក? វេជ្ជសាស្រ្តបានឲ្យដឹងថាៈ បុគ្គល

ដែលបរិភោគសាច់ជ្រូកនោះ គឺគេអាចមានជម្ងឺមិនក្រោមជាង៧០ប្រភេទឡើយ។ គឺអាចមានជម្ងឺព្រូន អៀន។ សត្វល្អិតអង់ក្លូសតូម៉ានិងផ្សេងៗទៀត។ ពពួកប៉ារ៉ាស៊ីតជាច្រើនទៀត។ ហើយប៉ារ៉ាស៊ីតដែលគ្រោះថ្នាក់បំផុត គេហៅថា តេនញ៉ា។ តេនញ៉ា ឈ្មោះវាតាមបច្ចេកសព្ទថា តេនញ៉ា។ ហើយវាឋិតនៅក្នុងពោះវៀន។ វាវែងមែនទែន ហើយមានពង ឬស៊ុតជាច្រើន។ វាអាចចូលពេញក្នុងរាងកាយតាមរយៈសរសៃឈាម។ កាលណាវាចូលដល់ខួរក្បាល វានឹងធ្វើឲ្យបាត់បង់ការចងចាំ។ ប្រសិនបើវាចូលដល់ភ្នែកវានឹងអាចធ្វើឲ្យខ្វាក់បាន។ បើវាចូលដល់បេះដូង វានឹងអាចធ្វើឲ្យមានជម្ងឺគាំងបេះដូង។ កាលណាវាចូលដល់ថ្លើមវានឹងធ្វើឲ្យខូចថ្លើម។ វាអាចបង្ករគ្រោះថ្នាក់ដល់ខ្លួនប្រាណទាំងមូល។ ហើយនៅពេលដែលអ្នកដឹងថាខ្លួនមានរោគតេនញ៉ានោះ វាយឺតពេលហើយ។ ជម្ងឺផ្សេងទៀតដែលគ្រោះបំផុតនៅពេលបរិភោគសាច់ជ្រូកនោះគឺTrichura tichurasis ហើយមានអ្នកខ្លះគិតខុសថា នៅពេលដែលអ្នកចម្អិនអាហាររបស់អ្នកបានល្អនោះ តេនញ៉ាវានឹងស្លាប់។ តាមការសិក្សាស្រាវជ្រាវបានបញ្ជាក់ថា មានមនុស្ស២៥%ដែលប្រឈរមុខនិងចម្ងឺសត្វល្អិត។ ក្នុងនោះមាន២២%អ្នកដែលចម្អិនសាច់ជ្រូកបានយ៉ាងល្អបំផុត។ មានន័យថា អាហារដែលអ្នកចម្អិនក្នុងផ្ទះរបស់អ្នកនោះកំម្តៅធម្មតាដុតចម្អិតវា មិនអាចសម្លាប់មេរោគនិងបាក់តេរី និងស៊ុតដែលនៅក្នុងសាច់ជ្រូកនោះឡើយ។ មានមូលហេតុជាច្រើនទៀតដែលធ្វើឲ្យ

យើងមិនបរិភោគសាច់ជ្រូកនោះ ការសិក្សាស្រាវជ្រាវបានឲ្យដឹងថា សាច់ជ្រូកមានផ្ទុកជាតិខ្លាញ់ច្រើនបំផុត ហើយសារធាតុ ជំនួយរាងកាយគឺតិចតួចណាស់។ ព្រោះតែសារជាតិបង្កខ្លាញ់នេះ វាអាចធ្វើ ឲ្យបុគ្គលម្នាក់ទទួលរងគ្រោះថ្នាក់ កម្រិតខ្ពស់ ដោយសារសម្ពាធឈាម ឡើងខ្ពស់ កកសរសៃឈាម និងគាំងបេះដូង។ ដោយសារជាតិខ្លាញ់នេះ មានពលរដ្ឋអាមេរិក៥០%កើតជម្ងឺលើសឈាម ព្រោះពួកគេភាគច្រើនបរិភោគសាច់ជ្រូក។ សត្វជ្រូកត្រូវបានគេស្គាល់ថា ជាសត្វដែលកខ្វក់បំផុតនៅលើផែនដីនេះ។ កន្លែងណាដែលមានលាមក ឬភក់គឺពិតជាមានជ្រូកនៅទីនោះ។ វាជាសត្វដែលកខ្វក់ជាងគេបំផុត។ មានមួយចំនួននិយាយថា ប្រទេសខ្លះដូចជាអូស្រ្តាលីពួកគេចិញ្ចឹមជ្រូកដោយមានការអនាម័យល្អបំផុត។ ខ្ញុំសូមប្រាប់ពួកគេថា ទោះបីនៅប្រទេសអូស្រ្តាលីធ្វើដូច្នោះក៏ដោយ អ្វីដែលគ្រោះថ្នាក់នោះគេដាក់សត្វជ្រូកឱ្យនៅជាមួយគ្នា តើអ្នកដឹងទេថា ជ្រូកនៅពេលដែលវាជុះវានឹងស៊ីលាមករបស់វា? ដូច្នេះតើមានអ្នកយាម២៤ម៉ោងដែរឬទេដើម្បីកើបលាមករបស់វានៅពេលវាជុះនោះ? គឺគ្មានទេ. ដូច្នេះសត្វជ្រូកទោះបីនៅប្រទេសអូស្រ្តាលី ក៏កខ្វក់ដែរ។ វាជាសត្វដែលកខ្វក់ជាងគេបំផុត។ មានមូលហេតុបន្ថែមទៀតដែលខ្ញុំកំពុងតែគិតពិចារណា ជាមួយនឹងមូលហេតុជាច្រើផ្សេងទៀត។ ការសិក្សាស្រាវជ្រាវបច្ចុប្បន្នបានបញ្ជាក់ថា សត្វជ្រូកជាសត្វមួយដែលគ្មានការអៀនខ្មាស់បំផុតក្នុងចំ

នោមសត្វទាំងឡាយដែលនៅលើផែនដីនេះ។ សត្វជ្រូកគឺជាសត្វតែមួយគត់ដែលបបួលគ្នារបស់វា ដើម្បីមើលវាដោយមេរបស់វា។ សត្វជ្រូកនៅពេលវាចាប់ផ្តើមដោយញី វាបបួលគ្នារបស់វាមកមើល។ តើអ្នកដឹងទេថា នៅអាមេរិក ជាប្រទេសដែលជឿនលឿន គឺមានកម្មវិធីរាំច្រៀងមួយ បន្ទាប់ពីកម្មវិធីនេះពួកគេចាប់ផ្តើមប្តូរប្រពន្ធរបស់ពួកគេ ឯងដេកជាមួយប្រពន្ធរបស់ខ្ញុំ ខ្ញុំដេកជាមួយប្រពន្ធរបស់ឯង។ ប្រសិនបើអ្នកបរិភោគសាច់ជ្រូក អ្នកនឹងមានចរិតដូចសត្វជ្រូកអ៊ីចឹង។

# សំនួរទី១៩

# ហេតុអ្វីបានជាឥស្លាមហាមឃាត់គ្រឿងស្រវឹង?

ហេតុអ្វីបានជាឥស្លាមហាមឃាត់គ្រឿងស្រវឹង? ហេតុអ្វីបានជាគេហាមគ្រឿស្រវឹងលើអ្នកមូស្លីម? ហេតុអ្វីបានជាគេហាមផឹកស្រា? អល់ឡោះមានបន្ទូលក្នុងគម្ពីរគួរអានជំពូកទី៥ឃ្លាទី៩០ថា ឱបណ្ដាអ្នកមានជំនឿ! ពិតណាស់សុរា ល្បែងស៊ីសងគោរពរូបបដិមា និងជឿលើការចាក់គម្បីរទាយវាសនា គឺជាអំពើដ៏កខ្វក់នៃទង្វើរបស់ស្ហៃតន។ដូច្នេះចូរពួកអ្នកចៀសវាងឲ្យឆ្ងាយពីវា សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។ នេះជាឃ្លាមួយនៅក្នុងគម្ពីរគួរអាន នៃជំពូកទី៥ឃ្លាទី៩០បានបញ្ជាក់ថា: ពិតណាស់សុរា ល្បែងស៊ីសង ការគោរពរូបបដិមា និងជឿលើការចាក់គម្ពីរទាយវាសនាទាំងនោះ គឺជាអំពើដ៏កខ្វក់នៃទង្វើរបស់ស្ហៃតន។ ដូច្នេះចូរពួកអ្នកចៀសវាងឲ្យឆ្ងាយពីវា សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។ យោងតាមព្រះបន្ទូលខាងលើនេះ អ្នកមូស្លីមចៀសវាងពីការផឹកគ្រឿងស្រវឹង។ សារដដែលនេះគេបានលើកឡើងក្នុងគម្ពីរបាយបល សាហ្សារុលអាំសាលជំពូកទី១/២០ដែលបានប្រាប់ថាស្រាធ្វើឲ្យអត់ខ្មាស់អៀន ហើយស្រវឹងធ្វើឲ្យធ្លាក់ក្នុងអំពើអាក្រក់ ហើយបុគ្គលណាវង្វេងនឹងវាទាំងពីរនេះ គឺគេជាមនុស្សដែលគ្មានប្រាជ្ញា។ ក្នុងសៀវភៅសាហ្សាអ៊ីហ្សសជំពូកទី១៨.៥នៃគម្ពីរបាយបលបានប្រាប់ថា ចូរ

ពួកអ្នកកុំស្រវឹងស្រាដែលណាលឲ្យបាត់បង់កេរ្តិ៍ខ្មាស់ ក៏ប៉ុន្តែអ្នកត្រូវបំពេញខ្លួនអ្នកដោយវិញ្ញាណ។ ដូច្នេះបើអ្នកអានគម្ពីរបាយបល ហើយអ្នកមានជំនឿនឹងវានោះ ផ្អែកតាមការណែនាំរបស់បាយបលនោះ គ្រីស្តសាសនិកចាំបាច់ត្រូវតែចៀសឆ្ងាយពីការផឹកគ្រឿងស្រវឹងដែរ។ សារនេះដដែលបានលើកឡើងក្នុងសៀវភៅហិណ្ឌូ។ មានច្រើនកន្លែងនៅក្នុងគម្ពីហិណ្ឌូបានហាមពីគ្រឿងស្រវឹង។ ក្នុងសៀវភៅមនូសម៌តីភាគទី៩/២២៥។ ជាការពិតណាស់សុរាត្រូវបានហាមជាច្រើនកន្លែងក្នុងគម្ពីរវេទ។ តោះយើងវិភាគមើលពីមូលហេតុដែលសមហេតុផលនៃការហាមរបស់ព្រះអល់ឡោះចំពោះអ្នកមូស្លីមពីការផឹកស្រា។ បច្ចុប្បន្នការស្រាវជ្រាវបានឲ្យដឹងថា មនុស្សគ្រប់គ្នាមានប្រព័ន្ធគ្រប់គ្រងក្នុងខួរក្បាលរបស់គេ។ ប្រព័ន្ធនេះនឹងធ្វើការទប់ស្កាត់មនុស្សរាល់ទង្វើខុសឆ្គង។ ឧទាហរណ៍ដូចជា: មនុស្សគ្រប់គ្នាដឹងថា ការប្រើពាក្យអសុរោះវាជារឿងខុសឆ្គង ជាពិសេសនៅពេលយើងនិយាយជាមួយចាស់ទុំឬឪពុកម្តាយប្រសិនបើយើងត្រូវកាបន្ទោបង់ ជាធម្មតាយើងមិនធ្វើនៅមុខមហាជនឡើយ ផ្ទុយទៅវិញយើងនឹងទៅរកបង្គន់។ ប្រព័ន្ធគ្រប់គ្រងនោះវាហាមយើងមិនឲ្យធ្វើនៅមុខមហាជនទេ ព្រោះយើងដឹងថា នេះជាអំពើខុសឆ្គង។ ក៏ប៉ុន្តែនៅពេលបុគ្គលម្នាក់ស្រវឹងស្រា ប្រព័ន្ធគ្រប់គ្រងរបស់គេត្រូវផ្អាក់! ហេតុនេះហើយបានជាយើងឃើញអ្នកដែលស្រវឹង គេប្រើពាក្យអសុរោះ រហូតមានពេលខ្លះ គេជេរប្រមាថចាស់ទុំ សូម្បីតែឪពុកម្តាយ

គេ។ ពីព្រោះប្រព័ន្ធគ្រប់គ្រងរបស់គេត្រូវផ្អាក់ដំណើរការ។ ហើយជាញឹកញាប់ណាស់យើងបានប្រទះឃើញអ្នកស្រវឹងស្រា ជុះនោមដាក់សំលៀកបំពាក់របស់គេ ហើយនៅមុខមហាជន។ ជាញឹកញាប់ យើងបានប្រទះឃើញអ្នកស្រវឹងទាំងនោះ មិនអាចដើរបានត្រឹមត្រូវឡើយ។ ជួនកាលគេមិនអាចនិយាយស្ដីបានល្អទេ។ គេមិនអាចធ្វើឥរិយាបទបានត្រឹមត្រូវឡើយ។ ព្រោះប្រព័ន្ធគ្រប់គ្រងនោះវាលែងដំណើរការ។ លើសពីនេះទៅទៀត ការស្រាវជ្រាវបានឲ្យដឹងថា គឺ នៅពេលបុគ្គលនោះស្រវឹង គេប្រព្រឹត្តអំពើដែលគេហាមឃាត់ជាច្រើន។ យោងតាមស្ថិតិ របស់ FBI បាន រាយការណ៍ថា នៅក្នុងឆ្នាំ 1990 ក្នុងក្រសួងយុត្តិធម៌ ការិយាល័យស្ថិតិជាតិជនរងគ្រោះនៃឧក្រិដ្ឋកម្មនៅសហរដ្ឋអាមេរិក នៅឆ្នាំ១៩៩០បានរាយកាណ៍ថាៈ ជារៀងរាល់ថ្ងៃមានអាត្រានៃការចាប់រំលោភសេពសន្ថវៈ ១៧៥៦ករណី ជាអាត្រាមធ្យមប្រចាំថ្ងៃ ហើយរបាយកាណ៍បានឲ្យដឹងថា ការរំលោភសេពសន្ថវៈដែលកើតឡើងនោះ មាន៥០%ករណីជាងបញ្ហានេះបានកើតឡើងនៅពេលបុគ្គលនោះស្រវឹងស្រា។ ការស្រាវជ្រាវបានរាយកាណ៍ថា នៅសហរដ្ឋអាមេរិក មានប្រហែលជាប្រាំបីភាគរយនៃជនជាតិអាមេរិកបានធ្វើការរួមភេទជាមួយសាច់ញាតិរបស់ខ្លួន ការរួមភេទជាមួយសាចញាតិរបស់ខ្លួន គឺមានន័យថា! ទំនាក់ទំនងផ្លូវភេទរវាងម្ដាយនិងកូន ឬរវាងឪពុកនិងកូនស្រី ឬរវាងបងប្រុសនិងប្អូនស្រី ទំនាក់ទំនងផ្លូវភេទជាមួយសាចញាតិដែលច្បាប់ហាមឃាត់។ ប្រាំបីភាគរយ គឺ

រាល់១២ឬ១៣នាក់នៃពលរដ្ឋអាមេរិកគឺមានម្នាក់បានធ្វើការរួមភេទជាមួយសាច់ញាតិរបស់ខ្លួន។ ក្នុងរបាយការណ៍បានបញ្ជាក់ថា ភាគច្រើនប្រសិនបើមានម្នាក់ឬទាំងពីរនាក់ ពួកគេឋិតក្នុងស្ថានភាពស្រវឹង ការស្រាវជ្រាវបានឲ្យដឹងថា មូលហេតុមួយនៃមូលហេតុធ្វើឲ្យមានជម្ងឺអេដស៍(ជម្ងឺដែលបណ្ដាលឲ្យស្លាប់ច្រើនច្រើនជាងគេ) នោះគឺជាតិស្រវឹង។ ជាធម្មតានៅពេលយើងជួបមនុស្សជាច្រើន នៃពួកអ្នកផឹកគ្រឿងស្រវឹងនោះ ពួកគេបាននិយាយថាៈ ខ្ញុំគ្រាន់តែផឹកដើម្បីចូលក្នុងសង្គមនឹងគេប៉ុណ្ណោះ។ ឬក៏ឪពុករបស់ខ្ញុំផឹកគ្រាន់តែចូលក្នុងសង្គមនឹងគេប៉ុណ្ណោះ ផឹកដើម្បីចូលក្នុងសង្គមនឹងគេ មានន័យថា គេផឹកមួយពែងឬពីរពែង ហើយគាត់ថា ខ្ញុំមិនស្រវឹងឡើយព្រោះខ្ញុំអាចគ្រប់គ្រងខ្លួនឯងបាន នៅពេលអ្នកជួបមនុស្សស្រវឹងណាម្នាក់។ ហើយអ្នកសួរពីប្រវត្តិរបស់គេ....គឺគ្មានអ្នកស្រវឹងណាម្នាក់ថា ផឹកស្រាដើម្បីឱ្យក្លាយជាមនុស្សប្រមឹកនោះទេ។ គឺគេចាប់ផ្ដើមផឹកដើម្បីចូលក្នុងសង្គមនឹងគេ។ ក្រោយមកគេក្លាយជាមនុស្សប្រមឹក ខ្ញុំហ៊ានភ្នាល់ ចូរប្រាប់ខ្ញុំមកមើល អ្នកណាម្នាក់ដែលផឹកដើម្បីចូលក្នុងសង្គមនឹងគេរាប់ឆ្នាំ ហើយមិនដែលស្រវឹងសោះក្នុងជិវិតរបស់គេសូម្បីតែម្ដង ។ ទោះបីជាអ្នកធ្វើប្រជាមតិសួរអ្នកដែលផឹកស្រាដើម្បីចូលក្នុងសង្គមនឹងគេ ទោះបីជាគេផឹកដើម្បីចូលក្នុងសង្គមនឹងគេក៏ដោយ ជួនពេលខ្លះ ឬមួយរយៈក្រោយមកគឺគេគង់តែស្រវឹងទេ បើទោះបីជាគេស្រវឹងតែម្ដងក៏ដោយក្នុងមួយជីវិតរបស់គេ ហើយគេប្រព្រឹត្ត

បទឧក្រិដ្ឋចាប់រំលោភសេពសន្ថវៈ ឬមានទំនាក់ទំនងផ្លូវភេទជាមួយសាច់ញាតិ ចូរគិតទៅមើល បន្ទាប់ពីគេដឹងខ្លួនវិញនោះ ផលប៉ះពាល់ ឬកំហុសដែលបានកើតឡើងនោះគឺមិនអាចកែខៃវិញបានឡើយ។ អាចដល់ជនរងគ្រោះ ឬជនល្មើសខ្លួនឯង។ វាជាការខាតបង់ដែលមិនអាចកែខៃវិញបានឡើយ។ សូមគិតទៅមើល បើបុគ្គលម្នាក់ស្រវឹង ហើយចាប់រំលោភសេពសន្ថវៈឬមានទំនាក់ទំនងផ្លូវភេទជាមួយសាច់ញាតិរបស់ខ្លួន បុគ្គលនោះមិនអាចលើកលែងទោសឲ្យខ្លួនឯងបានឡើយ ហេតុដូច្នេះហើយ ណាពីរបស់យើងបានមានប្រសាសន៍ នៅក្នុងសូណាន់អ៊ិបនូម៉ាជះភាគទី៤មាតិកាទី៣០ហាទីសលេខ ៣៣៧១។ ណាពីប្រាប់ថា ចូរពួកអ្នកកុំផឹកស្រា ព្រោះវាជាកូនសោនៃរាល់ទង្វើអាក្រក់។ វាជាប្រការអាក្រក់ដែលឃោរឃៅបំផុត។ ណាពីរបស់យើងបានមានប្រសាសន៍ នៅក្នុងសូណាន់អ៊ិបនូម៉ាជះភាគទី៤មាតិកាទី៣០ហាទីសលេខទី ៣៣៩២។ ណាពីយើងប្រាប់ថា (រាល់ជាតិស្រវឹងតិចក្តីច្រើនក្តីគឺហារ៉ាម)។ គ្មានការអនុគ្រោះឡើយទោះជាបរិមាណប៉ុណ្ណាក៏ដោយ។ ណាពីយើមូហាំម៉ាត់បានមានប្រសាសន៍ទៀត នៅក្នុងសូណាន់អ៊ីបនូម៉ាជះភាគទី៤ នៅក្នុងសូណាន់អ៊ិបនូម៉ាជះភាគទី៣០អាទីស្ទលេខ៣៣៨០ គាត់បានមានប្រសាសន៍ថាៈ ពិតណាស់មានមនុស្សដប់ក្រុមដែលពាក់ព័ន្ធនឹងគ្រឿងស្រវឹងត្រូវបានព្រះអល់ឡោះទ្រង់ដាក់បណ្តាសាពួកគេ អ្នកបិតស្រានិងអ្នកប្រើឱ្យគេបិតស្រា បុគ្គលដែលផបិតស្រាឲ្យអ្នកដទៃ។ អ្នក

ផឹក និងអ្នកដឹកវា អ្នកដែលឱ្យគេដឹកស្រាយកទៅឱ្យ អ្នកបញ្ចុកស្រា និង អ្នកលក់ស្រា បុគ្គលដែលទទួលផលកំរៃពីការលក់គ្រឿងស្រវឹង។ អ្នកទិញនិងអ្នកដែលគេទិញឲ្យ អ្នកទាំងនោះណាពីយើងប្រាប់ថា ព្រះអល់ឡោះបានដាក់បណ្ដាសាពួកគេទាំងអស់។ ប៉ុន្តែគ្រូពេទ្យ សព្វថ្ងៃនេះមានទស្សនៈផ្សេងគ្នា ពួកគេនិយាយថា ស្រាមិនមែនធ្វើឱ្យញៀនទេ។ ពួកគេនិយាយថា ការញៀនគ្រឿងស្រវឹងគឺជា ជំងឺមួយ ពួកគេនិយាយថា យើងគួរតែអាណិតដល់មនុស្សប្រមឹកទាំងនោះ បច្ចេកវិទ្យានិងវិធីថ្មី ដូចជាការសួរសុខទុក្ខអ្នកជម្ងឺវាជាតួនាទីរបស់យើង ហើយយើងត្រូវបង្ហាញការអាណិតដល់ពួកគេ គ្រូពេទ្យបច្ចុប្បន្ននិយាយថា ការញៀនស្រាវាជាជម្ងឺមួយ ដូច្នេះយើងគួរអាណិតអាសូដល់ពួកគេ ហើយខ្ញុំតបទៅពួកគេវិញថា ក្នុងសារមួយដែលខ្ញុំបានលើកឡើងក្នុងទូរទស្សន៍( peace tv ហើយខ្ញុំតែងតែនិយាយវាឡើងវិញដដែលៗ ថាបើសិនការញៀនស្រាជាជម្ងឺនោះ វាពិតជាជម្ងឺមួយដែលគ្មានមេរោគបង្កឡើយ។ វាគឺជាជម្ងឺតែមួយគត់ដែលគេដាក់លក់ក្នុងដប វាជាជម្ងឺមួយគត់ដែលគេចុះផ្សាយតាមកាសែតនិងទស្សនាវដ្ដី។ និងតាមទូរទស្សន៍និងវិទ្យុ។ វាជាជម្ងឺតែមួយគត់ដែលមានប័ណ្ណអនុញ្ញាតលក់។ ហើយវាជាជម្ងឺតែមួយគត់ដែលជាចំណូលរបស់រដ្ឋាភិបាលជាច្រើននៅលើសកលលោក។ វាជាជម្ងឺតែមួយគត់ដែលបង្កឲ្យមានករណីស្លាប់ដ៏កាចសាហាវនៅលើដងផ្លូវ។ វាជាជម្ងឺតែមួយគត់ដែលបំផ្លាញគ្រួសារ ព្រះអល់ឡោះជាម្ចាស់ដែលបង្កើតយើង

បានតបវិញក្នុងជំពូកទី៥/៩០ ឱបណ្ដាអ្នកមានជំនឿ! ពិតណាស់សុរា ល្បែងស៊ីសង ការគោរពបូជារូបបដិមា និងការចាក់គម្ពីរទស្សន៍ទាយ វាសនា គឺជាអំពើដ៏កខ្វក់នៃទង្វើរបស់ស្ហៃតន។ ដូច្នេះចូរពួកអ្នកចៀស វាងឲ្យឆ្ងាយពីវា សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។ វាមិនមែន ជាជម្ងឺទេ ក៏ប៉ុន្តែវាជាអំពើដ៏កខ្វក់នៃទង្វើរបស់ស្ហៃតន។ ចូរបញ្ឈប់វា ទើប បានជោកជ័យ នេះជាមូលហេតុ ហើយនៅក្នុងបណ្ដាគម្ពីរទាំងអស់ភាគ ច្រើនគាំទ្រគម្ពីរគួរអាន និងប្រសាសន៍របស់ ព្យាការីមូហាំម៉ាត់។ ពិត ណាស់ស្រាគឺត្រូវបានហាម។

# សំនួរទី១៥

# ហេតុអ្វីបានជាក្នុងឥស្លាម សាក្សីស្ត្រីពីរនាក់ស្មើនឹងសាក្សីបុរសម្នាក់?

នេះបញ្ជាក់ថា ឥស្លាមមិនលើកឋានៈស្ត្រី ទុកឱ្យខ្ញុំបកស្រាយប្រាប់អ្នកទាំងអស់គ្នា ថានៅក្នុងគម្ពីរគួរអានមានមិនតិចជាងប្រាំកន្លែងបាននិយាយពីការធ្វើសាក្សីដោយមិនបានកំណត់ភេទប្រុសឬស្រីឡើយ។ មានតែមួយកន្លែងប៉ុណ្ណោះដែលគម្ពីរគួរអានបានកំណត់ថាៈ សាក្សីស្ត្រីពីរនាក់ស្មើនឹងសាក្សីបុរសម្នាក់ គឺនៅក្នុងជំពូកទីពីរឃ្លាទី២៨២ វាជាឃ្លាដែលវែងជាងគេនៅក្នុងគម្ពីរគួរអាន។ ជំពូកដែលវែងជាងគេនៅក្នុងគម្ពីរគួរអានគឺជំពូកទីពីរហើយឃ្លាទី២៨២ជាឃ្លាដែលវែងជាងគេនៅក្នុងគួរអាន។ អល់ឡោះមានបន្ទូលក្នុងគម្ពីរគួរអានថា ឱបណ្ដាអ្នកដែលមានជំនឿ រាល់កិច្ចព្រមព្រៀងណាដែលពាក់ព័ន្ធនឹងលុយកាក់ដែលមានពេលកំណត់ជាកាតព្វកិច្ច ចូរពួកអ្នកត្រូវកត់ត្រាវា ហើយពួកអ្នកត្រូវមានសាក្សីពីរនាក់( ប្រុស )ក្នុងចំណោមពួកអ្នក ហើយទ្រង់បានបន្តទៀតថា ប្រសិនបើពួកអ្នកមិនអាចរកសាក្សី( ប្រុស )ពីរនាក់ទេនោះគឺត្រូវមានបុរសម្នាក់និងស្ត្រីពីរនាក់ ហើយទ្រង់បានបន្តថាៈ ប្រសិនបើនរណាម្នាក់នៃស្ត្រីទាំងពីរនោះច្រឡំឬខុស ម្នាក់ទៀតកែតម្រូវនាង។ ឃ្លាមួយនេះ

បានរៀបរាប់ប្រាប់ពីការពាក់ព័ន្ធនឹងទ្រព្យសម្បត្តិតែប៉ុណ្ណោះ គ្មានអ្វីផ្សេងទៀតឡើយ។ ទុកឱ្យខ្ញុំលើកឧទាហរណ៍ផ្សេងដើម្បីឲ្យអ្នកយល់កាន់តែច្បាស់ ឧបមាថា មានគេចង់ធ្វើការវះកាត់ជម្ងឺមួយ អាចជាការវះកាត់ដ៏ធំដុំ ជម្រើសដ៏ល្អបំផុតសម្រាប់គាត់គឺគាត់ត្រូវស្ដាប់ការណែនាំរបស់អ្នកមានជំនាញវះកាត់ពីរអ្នកដើម្បីធានាឱ្យបានខ្ពស់ចំពោះសុវត្ថិភាពរបស់គាត់ តែបើគ្មានពីរនាក់ទេយ៉ាងហោចណាស់ត្រូវរកឲ្យបានម្នាក់។ ដែលមានបរិញ្ញាប័ត្រជាន់ខ្ពស់អនុបណ្ឌិត និង គ្រូវពេទ្យពីរនាក់មានបរិញ្ញាប័ត្រវះកាត់(មានបទពិសោធវះកាត់យូរ)។ ព្រោះគ្រូពេទ្យបរិញ្ញាបត្រវះកាត់នោះ គាត់មិនអាចធ្វើការវះកាត់ដ៏ធំដុំបានឡើយ ហើយអ្នកក៏មិនអាចរកពេទ្យជំនាញខាងវះកាត់ថ្នាក់បរិញ្ញាប័ត្រចំនួនបួននាក់ដែរ ល្អវាអ្នកត្រូវមានអ្នកជំនាញពីរនាក់ដែលមានបរិញ្ញាប័ត្រជាន់ខ្ពស់អនុបណ្ឌិតផ្នែកវះកាត់ ប្រសិនបើគ្មានអ្នកឯកទេស វះកាត់ពីរនាក់ទេនោះ យ៉ាងហោចណាស់ឲ្យមានម្នាក់ និងជំនួយការខាងវះកាត់ពីរអ្នក។ វាគឺស្រដៀងគ្នានិងរឿងទ្រព្យសម្បត្តិ ព្រោះក្នុងសាសនាឥស្លាម បុរសជាអ្នកទទួលខុសត្រូវលើទ្រព្យសម្បត្តិ។ ក្នុងឥស្លាមស្ត្រីមិនទទួលខុសត្រូវលើទ្រព្យសម្បត្តិឡើយ។ ក្នុងឥស្លាម មុននឹងស្ត្រីរៀបការ ជាកាតព្វកិច្ចឪពុកនិងបងប្រុស (កាតព្វកិច្ចទទួលបន្ទុកផ្នែកលុយកាក់ចាយវាយរបស់នាង)។ បន្ទាប់ពីនាងរៀបការរួច ជាកាតព្វកិច្ចប្ដីនិងកូនប្រុសរបស់នាងជាអ្នកទទួលបន្ទុកលើរូបនាង។ មូលហេតុដូច្នេះ បុរសនៅក្នុងសង្គមឥស្លាមគឺ ទទួលបន្ទុក

ធ្ងន់ជាងស្ត្រីលើបញ្ហាលុយកាក់។ ហេតុនេះរាល់ការធ្វើសាក្សីពាក់ព័ន្ធនឹងលុយកាក់យើងត្រូវយកបុរសពីរនាក់។ ហើយបើគ្មានបុរសពីរនាក់ទេ គឺត្រូវមានបុរសម្នាក់និងស្ត្រីពីរនាក់។ ព្រោះបើមានម្នាក់ច្រឡំ ឬមានការខុសឆ្គង ឬមានម្នាក់ភ្លេច ម្នាក់ទៀតជួយរំឭកវិញគឺថា ។បើសមានម្នាក់ខុស ម្នាក់ទៀតជួយកែ ក្នុងគម្ពីរគួរអានមានឃ្លាជាច្រើននិយាយពីការធ្វើសាក្សីដោយមិនបានលើកឡើងពីភេទឡើយ។ ដូចជានៅក្នុងជំពូកទី៥ ឃ្លាទី១០៦-១០៨។ ឱបណ្តាអ្នកមានជំនឿ! នៅពេលអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកជិតស្លាប់ពេលនោះគេចង់ធ្វើបណ្តាំ ចូរឲ្យគេរកសាក្សីពីរនាក់ដែលមានភាពយុត្តិធម៌ក្នុងចំណោមពួកអ្នកមូស្លីមឬពីរនាក់ផ្សេងទៀតក្រៅពីពួកអ្នក(មិនមែនមូស្លីម)។ មិនបានកំណត់ភេទឡើយ។ នៅក្នុងជំពូកទី៧៥ឃ្លាទី២បានលើកឡើងថា ហើយនៅពេលដែលពួកនាងជិតផុតពេលកំណត់(លែងលះលើកទី១ឬលើកទីពីរ) ចូរពួកអ្នកវិលទៅរកនាងវិញដោយសមរម្យ ឬលែងលះគ្នាឲ្យដាច់ដោយសមរម្យដែរ។ ហើយចូរពួកអ្នករកសាក្សីដ៏យុត្តិធម៌ចំនួនពីរនាក់នៅក្នុងចំណោមពួកអ្នក។ ចូរពួកអ្នកធ្វើសាក្សីដើម្បីអល់ឡោះ។ កន្លែងនេះគ្មានកំណត់ភេទឡើយ។ គឺត្រូវការអ្នកយុត្តិធម៌និងសច្ចៈធម៌ប៉ុណ្ណោះ។ ក្នុងជំពូកទី២៤ឃ្លាទី៤បានប្រាប់ថា ហើយពួកដែលចោទប្រកាន់ស្ត្រីដែលល្អបរិសុទ្ធ បន្ទាប់មកពួកគេមិនបាននាំមកនូវសាក្សីចំនួនបួននាក់ទេនោះ ចូរពួកអ្នកពិន័យពួកគេចំនួនប៉ែតសិបរំពាត់។ សាក្សីបួននាក់ដោយមិនបានកំណត់ថា

ប្រុសឬស្រីឡើយ។ បន្ទាប់ពីការចោទទៅលើគេ ហើយគ្មានសាក្សីបួននាក់ទេនោះ គឺត្រូវដាក់ទណ្ឌកម្ម។ មានឃ្លាមួយនៅក្នុងគម្ពីរគួរអានដែលបញ្ជាក់ថា ស្ត្រីនិងបុរសគឺមានភាពស្មើគ្នា គឺនៅក្នុងជំពូកទី២៤ឃ្លាទី៦-៧។ បើបុគ្គលណាម្នាក់ប្រឌិតរឿងចោទប្រកាន់ដៃគូជីវិតរបស់ខ្លួន។ ប្តីប្រឌិតរឿងចោទប្រកាន់ភរិយារបស់ខ្លួន ដោយគេគ្មានភស្តុតាងឬសាក្សីអ្វីនោះទេ គឺសាក្សីខ្លួនគេផ្ទាល់គឺគ្រប់គ្រាន់ហើយដោយគេត្រូវស្បថចំនួនបួនដង ហើយលើកទីប្រាំគេត្រូវដាក់បណ្តាសាខ្លួនឯងបើគេនិយាយកុហកនោះ ឃ្លាបន្ទាប់ពីរឃ្លាទី៦ទី៧គឺទី៨នោះ ហើយភរិយាក៏ដូច្នោះដែរបើគ្មានសាក្សីទេនោះ គឺនាងអាចធ្វើសាក្សីដោយខ្លួនឯងបាន។ តាមរយៈការស្បថចំនួនបួនដង។ ហើយស្បថលើកទីប្រាំត្រូវដាក់បណ្តាសាលើខ្លួនឯងប្រសិនបើនាងកុហកនោះ ដូច្នេះកន្លែងនេះគម្ពីរគួរអានបានបញ្ជាក់យ៉ាងច្បាស់ថា សាក្សីរបស់នារីម្នាក់ស្មើនិងសាក្សីបុរសម្នាក់ដែរ។ ផ្អែកលើខ្លឹមសារនេះ អ្នកប្រាជ្ញឥស្លាមភាគច្រើនបានឯកភាពគ្នាថា ពាក់ព័ន្ធនឹងលុយកាក់ ប៉ុណ្ណោះដែលសាក្សីស្ត្រីពីរនាក់ស្មើនឹងសាក្សីបុរសម្នាក់។ ហើយអ្នកប្រាជ្ញឥស្លាមខ្លះទៀតថា ក្នុងករណីឃាតកម្មប៉ុណ្ណោះព្រោះស្ត្រីអាចមានការលំបាកក្នុងការបញ្ជាក់ពីការពិត ហេតុនេះពីរនាក់ទើបស្មើនឹងបុរសម្នាក់។ ចំណែកករណីផ្សេងៗទៀតគឺសាក្សីស្ត្រីម្នាក់ស្មើនឹងសាក្សីបុរសម្នាក់។ ឧទាហរណ៍ដូចជា ពេលចាប់ផ្តើមខែបួស នៅពេលចាំមើលកូនខែគឺយើងត្រូវការសាក្សីម្នាក់។ ហើយនៅពេលចុងខែគឺយើង

ត្រូវការសាក្សីពីរនាក់ ដោយមិនបានកំណត់ថាប្រុសឬស្រីឡើយ។ មានប្រទេសខ្លះថា សាក្សីត្រូវតែជាបុរស មានពុកចង្ការ ....គឺគាត់តែម្នាក់គត់ដែលអាចធ្វើសាក្សីបាន។ ហើយខ្ញុំមានភស្តុតាងច្បាស់ណាស់ គឺភរិយារបសមូហាំម៉ាត់(អ្នកនាំសាររបស់ព្រះអល់ឡោះ) ដែលបានរាយកាណ៍ពីរសូលុលឡោះចំនួន២២១០ហាទីស។ ហើយគាត់ជាសាក្សីតែម្នាក់គត់ ហេតុនេះ២២១០ហាទីសត្រឹមត្រូវដែលជាមូលដ្ឋានគ្រឹះ របស់ឥស្លាម។ គឺសាក្សីស្ត្រីម្នាក់គត់ដែលជាភរិយារបស់មូហាំម៉ាត់លោកស្រីអាអ៊ីស្ហះ។ នេះគឺមានន័យថា សាក្សីស្ត្រីម្នាក់ស្មើនឹងសាក្សីបុរសម្នាក់ ហើយមានករណីខ្លះ ដូចលុយកាក់មួយចំនួន ដែលបុរសមានអាទិភាពជាងស្ត្រី។ ហើយមានពេលខ្លះទៀតគេទទួលស្គាល់សាក្សីរបស់ស្ត្រី ហើយគេមិនទទួលស្គាល់សាក្សីរបស់បុរស។ ឧទាហណ៍ដូចជា នៅពេលលាងសពស្ត្រីមុស្លីម៉ះ គឺត្រូវតែមានសាក្សីជាស្ត្រី បុរសមិនអាចធ្វើសាក្សីបានឡើយ។ ក្រៅពីនោះជាទូទៅនៅពេលលាងសពស្ត្រី គឺត្រូវមានសាក្សីស្ត្រីមិនមែនបុរសទេ។

# សំនួរទី១៦

# ហេតុអ្វីបានជាឥស្លាមបំពានលើស្ត្រីដោយឲ្យនាង ទទួលកេរមរតកតែពាក់កណ្ដាលនៃបុរស?

ហេតុអ្វីបានជាភេទស្រីក្នុងសាសនាឥស្លាម ទទួលកេរមរតកមិនស្មើនឹងភេទប្រុស? នេះអយុត្តិធម៌ណាស់សម្រាប់ស្ត្រី នេះជាសំនួរទី១៦ នៃការយល់ច្រឡំដែលបានសុសសាយអំពីសាសនាឥស្លាម។ ខណៈដែលយើងនិយាយអំពីកេរមរតកក្នុងគម្ពីរគួរអាន។គម្ពីរគួរអានក៏បានបកស្រាយជាច្រើនកន្លែងស្ដីពីការចែកកេរមរតក ក្នុងជំពូកអាល់ហ្គាករ៉ោះ ទី២ ឃ្លាទី១៨០ និងឃ្លាទី១៤០ ជំពូកអាន់នីសាក ទី៤ ឃ្លាទី៧-៩ និងឃ្លាទី១៩។ ជំពូកអាន់នីសាក ទី៤ឃ្លាទី៣៣ និងជំពូកអាល់ម៉ាអ៊ីដះ ទី៥ ឃ្លាទី១០៦-១០៨។ មានកន្លែងជាច្រើនបានបរិយាយអំពីកេរមរតក ហើយកន្លែងដែលច្បាស់ជាងគេនោះគឺនៅក្នុង ជំពូកអាន់នីសាក ទី៤ ឃ្លាទី ១១-១២ ហើយនៅក្នុងជំពូកអាន់នីសាក ទី៤ ដដែលឃ្លាទី១៧៦។ អល់ឡោះទ្រង់មានបន្ទូលក្នុងជំពូកអាន់នីសាក ទី៤ ឃ្លាទី១១ថា: អល់ឡោះបញ្ជាឲ្យយពួកអ្នកធ្វើការបែងចែកទ្រព្យសម្បត្តិទាក់ទងនិងកូនចៅរបស់ពួកអ្នក គឺសម្រាប់កូនប្រុសម្នាក់ស្មើនឹងចំណែកកូនស្រីពីរនាក់។ តែប្រសិនបើសពមានកូនស្រីលើសពីពីរនាក់គឺពួកនាងទទួលបានមួយភាគ

បីនៃមរតកនោះ។ ហើយប្រសិនបើសពមានតែកូនស្រីម្នាក់គឺនាងទទួលបានពាក់កណ្តាល។ តើអ្វីទៅដែលអ្នកបន្សល់ទុកសម្រាប់ឪពុកម្តាយរបស់អ្នក។ ហើយចំពោះឪពុកម្តាយនៃសពវិញម្នាក់ៗត្រូវទទួលបានមួយភាគប្រាំមួយនៃមរតក ប្រសិនបើសពនោះមានកូន។ តែប្រសិនបើសពនោះគ្មានកូនទេគឺឪពុកម្តាយជាអ្នកទទួលមរតកនោះទាំងស្រុង ដោយម្តាយសពទទួលបានមួយភាគបី។ តែប្រសិនបើសពនោះមានបងប្អូនចាប់ពីពីរនាក់ឡើងទៅ គឺម្តាយសពទទួលបានមួយភាគប្រាំមួយ។ ឃ្លាទី១២បានប្រាប់ថាៈ តើចំនួនប៉ុន្មានដែលប្រពន្ធរបស់អ្នកបន្សល់ទុកឲ្យអ្នកបន្ទាប់ពីនាងស្លាប់ទៅហើយនោះ ហើយសម្រាប់ពួកអ្នក(ជាប្តី) ត្រូវទទួលបានពាក់កណ្តាលនៃមរតកដែលភរិយាៗរបស់ពួកអ្នកបន្សល់ទុកប្រសិនបើពួកនាងគ្មានកូន។ តែបើពួកនាងមានកូនវិញ គឺពួកអ្នកទទួលបានមួយភាគបួនពីមរតកដែលពួកនាងបានបន្សល់ទុក។ ចំណែកអ្វីដែលអ្នកបន្សល់ទុកសម្រាប់ភរិយារបស់អ្នកវិញៈ ហើយពួកនាង(ជាភរិយា)វិញត្រូវទទួលបានមួយភាគបួនពីមរតកដែលពួកអ្នក(ប្តី)បានបន្សល់ទុកប្រសិនបើពួកអ្នកគ្មានកូនទេនោះ។ តែបើពួកអ្នកមានកូនវិញគឺពួកនាងទទួលបានមួយភាគប្រាំបីប៉ុណ្ណោះពីមរតកដែលពួកអ្នកបានបន្សល់ទុកនោះ។ កុំច្របូកច្របល់ បើអ្នកមិនដឹងនោះ ចូរអ្នកទៅផ្ទះរបស់អ្នកហើយបើកគម្ពីរគួរអានមើល បើមិនយល់ភាសាអារ៉ាប់ អានគម្ពីរបកប្រែ នៅជំពូកអាន់នីសាក ទី៤ ឃ្លាទី១១-១២ ជាទូទៅខ្ញុំឯកភាពនិងអ្នក

ដែលថា ក្នុងករណីជាច្រើនគឺស្ត្រីទទួលបានពាក់កណ្តាលនៃបុរស ។ ហើយមានករណីផ្សេងទៀត ស្ត្រីនិងបុរសទទួលបានចំនួនស្មើគ្នា ដូចបានលើកឡើងអ៊ីចឹង ប្រសិនបើបុគ្គលម្នាក់ស្លាប់ហើយគាត់មានកូនប្រុស គឺឪពុកនិងម្តាយទទួលបានមួយភាគប្រាំមួយស្មើគ្នា។ ឬក៏ប្រសិនបើអ្នកស្លាប់នោះ ហើយគាត់គ្មានកូន តែគាត់មានបងប្អូនប្រុសស្រី ពួកគេទាំងពីរទទួលបានមួយភាគប្រាំមួយ។ មានករណីខ្លះស្ត្រីទទួលបានលើសពីបុរស។ បើស្ត្រីម្នាក់ស្លាប់ហើយនាងគ្មានកូន តែនាងមានប្តីនិងឪពុកម្តាយ ប្តីទទួលមរតកពាក់កណ្តាល ម្តាយទទួលមរតកមួយភាគបី ឪពុកទទួលបានមួយភាគប្រាំមួយ គឺមានន័យថា ម្តាយទទួលបានច្រើនជាងឪពុកទ្វេដង។ ប៉ុន្តែករណីនេះវាកម្រណាស់។ ខ្ញុំស្របនឹងអ្នកដែលថា ជាទូទៅស្ត្រីទទួលមរតកបានពាក់កណ្តាលនៃបុរសនោះ ប្រសិនបើកូនប្រុសនិងកូនស្រី កូនប្រុសទទួលបានទ្វេដងពីអ្វីដែលកូនស្រីទទួលបាននោះ បើប្តីប្រពន្ធវិញ ប្តីទទួលបានទ្វេដងពីអ្វីដែលភរិយាទទួលបាននោះ។ខ្ញុំយល់ស្របនិងអ្នក តើអ្វីទៅជាមូលហេតុដែលសមហេតុផលនោះ? មូលហេតុវាដូចខ្ញុំបានបញ្ជាក់ពីមុនអ៊ីចឹង គឺក្នុងឥស្លាមបុរសជាអ្នកទទួលបន្ទុកផ្នែកទ្រព្យសម្បត្តិ។ ព្រោះតែរឿងនេះវាពាក់ព័ន្ធនឹងស្ត្រី មុននាងរៀបការ គឺឪពុកនិងបងប្អូនប្រុសរបស់នាងជាអ្នកទទួលបន្ទុកលើនាង។ ហើយបន្ទាប់ពីរៀបការរួចប្តីនិងកូនជាអ្នកទទួលបន្ទុកលើនាង។ ត្រូវផ្តល់ឱ្យនាងនូវកន្លែងស្នាក់នៅ សំលៀកបំពាក់ ការហូប

ចុក និងរាល់កិច្ចការណាដែលពាក់ព័ន្ធនឹងលុយកាក់។ ដូច្នេះស្ត្រីមិនចាំបាច់ធ្វើការងារដើម្បីរកប្រាក់មកផ្គត់ផ្គង់ជីវិតរបស់នាងឡើយ។ យោងតាមខ្លឹមសារនេះ ព្រះអល់ឡោះជាម្ចាស់ដែលដាក់ការបែងចែកមរតកនេះ។ ទុកឱ្យខ្ញុំលើកឧទាហរណ៍មួយប្រាប់អ្នក ឧបមាថា មានបុរសម្នាក់ស្លាប់ ហើយគាត់បន្សល់មរតកចំនួន១៥០០០០ឌីរហាំ។ ហើយគាត់មានកូនប្រុសម្នាក់កូនស្រីម្នាក់។ គឺបន្ទាប់ពីចែកមរតកឱ្យភរិយានិងសាច់ញាតិរួច បើនៅសល់១៥០០០០ឌីរហាំ ដើម្បីចែកឱ្យកូនប្រុសនិងកូនស្រី កូនប្រុសនឹងទទួលបាន១០០០០០ឌីរហាំ ហើយកូនស្រីទទួលបាន៥០០០០ឌីរហាំ ឥឡូវខ្ញុំសួរអ្នកមួយថា តើអ្នកចង់នៅកន្លែងកូនប្រុសដែលទទួលបាន១០០០០០ឌីរហាំនោះទេ? ហើយអ្នកប្រហែលជាចំណាយអស់៨០% ឬ៩០%លើគ្រួសាររបស់អ្នកអំពីមរតកដែលអ្នកទទួលបាន ពីព្រោះអ្នកជាបងប្រុសហេតុនេះអ្នកត្រូវទទួលបន្ទុកក្នុងគ្រួសារ។ ឬក៏អ្នកចង់នៅកន្លែងកូនស្រីដែលទទួលបាន៥០០០០ឌីរហាំ ហើយអ្នករក្សាទុក សម្រាប់ខ្លួនឯងទាំងអស់ដោយមិនចំណាយទៅលើនរណាម្នាក់ឡើយ? ជាធម្មតាអ្នកពិតជាចង់យក៥០០០០ឌីរហាំ ហើយអ្នកមិនត្រូវចំណាយលើនរណាម្នាក់ឡើយ។ ដើម្បីចៀសពីយក១០០០០០ឌីរហាំ តែចំណាយវិញអស់៨០%ឬ៩០%ឬ១០០%ដើម្បីផ្គត់ផ្គង់លើគ្រួសាររបស់អ្នកនោះ។ នេះជាមូលហេតុ.....ហើយអល់ឡោះទ្រង់ពិតជាមានភាពយុត្តិធម៌បំផុត។ ប្រសិនបើចែកមរតកឲ្យគេទាំងពីរ

នាក់ស្មើគ្នា គឺចាំបាច់បំផុតមកលើរូបខ្ញុំត្រូវតែនិយាយពីសិទ្ធិបុរសក្នុងសាសនាឥស្លាម។ បន្ទាប់មកបុរសពិតជាមានការជំទាស់ជាមិនខាន តើនេះជាសាសនាអ្វី! ដាក់បន្ទុកគ្រួសារមកលើយើង ហើយនៅពេលទទួលមរតក! ទទួលបានចំនួនស្មើគ្នា! ព្រះអល់ឡោះទ្រង់ជាម្ចាស់ផ្តល់យុត្តិធម៌ដល់យើងទាំងអស់គ្នា ទ្រង់មានបន្ទូលក្នុងជំពូកអាន់នីសាក ទី៤ ឃ្លាទី៤០ថាៈ ពិតណាស់អល់ឡោះទ្រង់មិនបំពានលើអ្នកណាម្នាក់ឡើយសូម្បីល្អិតប៉ុនលម្អងធូលី។

# សំនួរទី១៧

# ហេតុអ្វីបានជាមូស្លីមមានជំនឿចំពោះថ្ងៃបរលោក?

តើអ្វីជាភស្តុតាងសមហេតុផលដែលបញ្ជាក់ថា មានថ្ងៃបរលោកនោះ? មានអ្នកមិនមែនមូស្លីមជាច្រើនបានសួរមកខ្ញុំនូវសំនួរនេះ។ លោកហ្សាកៀណែក លោកជាគ្រូពេទ្យ ហើយលោកបានធ្វើបទបង្ហាញពីគម្ពីរគួរអាននិងវិទ្យាសាស្ត្រពិត ហើយលោកក៏ជាអ្នកប្រាជ្ញម្នាក់ដែរ ចុះហេតុអ្វីបានជាលោកមានជំនឿចំពោះថ្ងៃបរលោកយ៉ាងងប់ងុលដូច្នេះ? វិទ្យាសាស្ត្រមិនបញ្ជាក់ពីថ្ងៃបរលោកទេ។ បានសេចក្តីថា ពួកគេបានចោទជាសំនួរថាៈ ប្រសិនបើឥស្លាមជាសាសនាដែលសមហេតុផលនោះ តើអ្នកអាចផ្តល់ភស្តុតាងបញ្ជាក់ថាមានថ្ងៃបរលោកបានដែរឬទេ? ខ្ញុំតបទៅពួកគេវិញថាៈ ការរស់ឡើងវិញនៅថ្ងៃបរលោកមិនមែនជាជំនឿងងឹតងងុលទេ។ ផ្ទុយទៅវិញវាជាជំនឿដ៏សមហេតុផលបំផុត ហើយខ្ញុំក៏បានលើកឡើងដែរអំពីគួរអាននិងវិទ្យាសាស្ត្រពិត ហើយខ្ញុំបាននិយាយថាៈ ក្នុងគម្ពីរគួរអានមានជាង៦០០០ឃ្លា ក្នុងនោះមានជាង១០០០ឃ្លានិយាយអំពីចំណេះវិជ្ជា ប៉ុន្តែសព្វថ្ងៃ វិទ្យាសាស្ត្រមិនទាន់វិវឌ្ឍន៍គ្រប់គ្រាន់ឡើយដើម្បីស្វែករកអ្វីដែលគម្ពីរគួរអានបានប្រាប់ នៅពេលយើង

ធ្វើការវិភាគ គឺយើងអាចសន្និដ្ឋានបានថាប្រហែលជា៨០%ក្នុងគម្ពីគួរអានបាននិយាយអំពីវិទ្យាសាស្ត្រ។ ហើយបញ្ជាក់ថាវាត្រឹមត្រូវ១០០% ហើយមាន២០%នៅមិនទាន់ច្បាស់ គឺយើងមិនទាន់ដឹងទេថា តើវាត្រឹមត្រូវឬមិនត្រឹមត្រូវ នៅពេលដែល៨០%ក្នុងគម្ពីរគួរអានបានបញ្ជាក់ថាត្រឹមត្រូវ១០០%តាមការសិក្សាស្រាវជ្រាវរបស់វិទ្យាសាស្ត្រ ហើយ២០% ទៀតមិនទាន់បានបញ្ជាក់ ហើយក្នុង២០%នេះក៏មិនទាន់មានចំណុចណាមួយដែលបញ្ជាក់ថាខុសនោះដែរ។ តក្កភាពបាននិយាយនៅពេលដែល៨០%ត្រឹមត្រូវយ៉ាងពេញលេញ ពិតណាស់តក្កភាពក៏និយាយថា ២០%ទៀត ក៏ត្រឹមត្រូវដែរ អិនស្តាអល់ឡោះ។ ដូច្នេះវាជាជំនឿដ៏សមហេតុផលបំផុតមិនមែនជាជំនឿអវិជ្ជានោះទេ។ នេះជាវិធីមួយបញ្ជាក់ពីថ្ងៃបរលោក។ វិធីផ្សេងទៀតដើម្បីបញ្ជាក់ពីថ្ងៃបរលោកនោះ គឺជាសំនួរទូទៅ គឺថាតើអំពើចោរកម្មជាទង្វើល្អឬអាក្រក់? ហើយខ្ញុំចង់សួរអ្នកទាំងអស់គ្នាដែលមានវត្តមាននៅទីនេះថា តើអំពើចោរកម្មជាទង្វើល្អឬអាក្រក់? ៖ល្អឬអាក្រក់ អាក្រក់ ល្អឬអាក្រក់? អាក្រក់ អាក្រក់... នរណាគិតថា អំពើចោរកម្មជាទង្វើល្អ ចូរលើកដៃ អត់មាននរណាម្នាក់ទេ ម៉ាស្តាអល់ឡោះ អ្នកមានវត្តនៅទីនេះច្រើនណាស់ប្រហែលជាលើសពី៥០០០០នាក់ទៅទៀត ហើយគ្មាននរណាម្នាក់គិតថាអំពើចោរកម្មជាទង្វើល្អ ខ្ញុំនិងព្យាយាមធ្វើជាបុគ្គលផ្សេង ឧបមានថា៖ ខ្ញុំជាមនុស្សមានហេតុផល និងមានការសិក្សាស្រាវជ្រាវ ហើយខ្ញុំធ្វើដូចជាអ្នកមិនមែន

មូស្លីម ធ្វើដូចជាអ្នកគ្មានសាសនា ហើយខ្ញុំអះអាងថាខ្ញុំជាមនុស្សមានហេតុផលម្នាក់ និងជាអ្នកសិក្សាស្រាវជ្រាវ ហើយខ្ញុំប្រាប់ថា អំពើចោរកម្មជាទង្វើល្អ។ ជឿខ្ញុំចុះ ខ្ញុំជាមនុស្សមានហេតុផលម្នាក់ និងជាអ្នកសិក្សាស្រាវជ្រាវ ហើយខ្ញុំថា អំពើចោរកម្មជាទង្វើដ៏ល្អមួយ ហើយខ្ញុំក៏ពេញចិត្តនឹងអំពើចោរកម្មនេះដែរ ហើយខ្ញុំផ្ដល់ឱកាសឱ្យអ្នកទាំងអស់គ្នាដែលមានចំនួនជាង៥០ពាន់នាក់នេះ ខ្ញុំផ្ដល់ឱកាសឱ្យពួកអ្នកទាំងអស់គ្នាដើម្បីបញ្ជាក់ប្រាប់ខ្ញុំថា តើអំពើចោរកម្មវាខុសត្រង់ណា ពេលនោះខ្ញុំនឹងឈប់ភ្លាម។ ខ្ញុំបានប្រាប់អ្នករួចហើយថា ខ្ញុំជាមនុស្សមានហេតុផលម្នាក់ និងជាអ្នកសិក្សាស្រាវជ្រាវ ចូរផ្ដល់មូលហេតុដែលសមហេតុផលតែមួយបានហើយ។ ហេតុអ្វីបានជាអំពើចោរកម្មនាំមកនូវគ្រោះថ្នាក់ដល់រូបខ្ញុំដើម្បីឱ្យបញ្ឈប់វា ខ្ញុំនឹងប្រាប់អ្នកថា អំពើចោរកម្មមានផលប្រយោជន៍អ្វីខ្លះ បើខ្ញុំលួចពួកគាត់ ខ្ញុំអាចទៅហូបអាហារពើរ៉យ៉ានី(អាហារនៅឥណ្ឌា) ហើយខ្ញុំអាចទៅស្នាក់នៅសណ្ឋាគារផ្កាយប្រាំ លុយស្រួលៗខ្ញុំរកបានដោយស្រួល ចូរពួកអ្នកប្រាប់ខ្ញុំមកតើហេតុអ្វីបានជាអំពើចោរកម្មជាទង្វើមិនល្អសម្រាប់ខ្ញុំ? មិនចាំបាច់ឲ្យ១០ឬ២០មូលហេតុទេ ផ្ដល់មូលហេតុដែលសមហេតុផលតែមួយបានហើយ ហេតុអ្វីបានជាអំពើចោរកម្ម មិនល្អសម្រាប់ខ្ញុំ ដើម្បីឱ្យខ្ញុំឈប់ធ្វើចោរ! តើមាននរណាម្នាក់អាចប្រាប់ពីមូលហេតុបានអត់? បាទ! ប្អូនប្រុស បើសិនជាខ្ញុំលួចពីនរណាម្នាក់ សុំនិយាយឲ្យខ្លាំងៗបន្តិចបានទេ? ល្អណាស់ ប្អូននោះគាត់

ថា ប្រសិនបើខ្ញុំយករបស់នរណាម្នាក់ គឺខ្ញុំយករបស់គេ។ បាទខ្ញុំយល់ស្របជាមួយអ្នក តែអ្នកដែលខាតគឺគាត់ មិនមែនខ្ញុំទេ ខ្ញុំទទួលបានផលប្រយោជន៍ ខ្ញុំយល់ស្របជាមួយអ្នក អ្វីដែលខ្ញុំប្រាប់អ្នកនោះ គឺ វាបញ្ជាក់ប្រាប់ខ្ញុំថា ហេតុអ្វីបានជាវាអាក្រក់ចំពោះខ្ញុំ? ជាធម្មតា វាអកុសលហើយសម្រាប់អ្នកដែលគេលួចរបស់គាត់នោះ អ្វីដែលខ្ញុំប្រាប់អ្នកនោះគឺតើអ្នកធ្វើដូចម្តេចដើម្បីបញ្ជាក់ប្រាប់ខ្ញុំថា លួចមិនល្អទេសម្រាប់ខ្ញុំ? ខ្ញុំជាមនុស្សមានហេតុផល និងមានចំណេះដឹងម្នាក់ ខ្ញុំយល់ស្របជាមួយអ្នកដែលថា វាជាអកុសលសម្រាប់អ្នកដែលគេឆក់លួចរបស់គាត់នោះ ប្រាប់ខ្ញុំមក វាមិនល្អសម្រាប់ខ្ញុំត្រង់ណា ដើម្បីខ្ញុំនឹងឈប់ធ្វើចោរ បាទ! សូមឲ្យខ្លាំងបន្តិច ប្រសិនបើគេលួចអ្នកតើអ្នកពេញចិត្តដែរឬទេ? ល្អៗ ប្អូន ខ្ញុំជាក្រុមម៉ាហ្វយ៉ាដ៏ធំមួយ ខ្ញុំមានអង្គរក្សផ្ទាល់ខ្លួន១០០នាក់នៅខាងក្រោយវេទិកានេះ ខ្ញុំជាក្រុមចោរជំនាញមិនមែនជាចោរស្ទើរៗឡើយ សម្រាប់ចោរស្ទើរវាអាចមិនល្អសម្រាប់គេក្នុងការលួចអ្នកដទៃ តែខ្ញុំជាក្រុមម៉ាហ្វយ៉ាដ៏ធំមួយ ខ្ញុំមានអង្គរក្សច្រើនជាង១០០នាក់ប្រដាប់អាវុធអាការ៤៧ដើមគ្រប់ដៃ ខ្ញុំជាមនុស្សមានហេតុផល និងមានចំណេះដឹងម្នាក់ ហើយខ្ញុំជាចោរជំនាញ ចំពោះចោរថ្មីថ្មោងវាអាចមិនល្អ ព្រោះអ្នកផ្សេងនឹងលួចបន្តពីគេវិញ ដូច្នេះ ហេតុអ្វីបានជាអំពើចោរកម្មមិនល្អសម្រាប់ខ្ញុំ បាទ! ប្អូនស្ងួរស្តី ខ្ញុំឈ្មោះណាឌីម ហេតុអ្វីបានជាអំពើចោរកម្មមិនល្អសម្រាប់ខ្ញុំ? ព្រោះអ្នកជាបុគ្គលអាក្រក់សម្រាប់អ្នកដទៃ ខ្ញុំជាមនុស្សអាក្រក់សម្របាំ

អ្នកដទៃ។ ខ្ញុំយល់ស្រប កូនប្រុស! ហេតុអ្វីវាអាក្រក់សម្រាប់ខ្ញុំ? ខ្ញុំឯកភាពតាមយោបល់អ្នក លោកនឹងមានកេរ្តិ៍ឈ្មោះអាក្រក់ កេរ្តិ៍ឈ្មោះខ្ញុំ? កេរ្តិ៍ឈ្មោះខ្ញុំល្អណាស់ ហេតុអ្វីវានឹងក្លាយជាអាក្រក់? ខ្ញុំប្រាប់អ្នក កេរ្តិ៍ឈ្មោះអាក្រក់វាគ្មានបញ្ហាឡើយ ដរាបណាខ្ញុំទទួលផលប្រយោជន៍ពីការលួចប្លន់នោះ។ នៅពេលខ្ញុំលួចប្រាក់នរណាម្នាក់បានដប់ម៉ឺនឡៀរហាំ ខ្ញុំអាចទៅស្នាក់នៅសណ្ឋាគារផ្កាយប្រាំ ខ្ញុំអាចទៅមើលភាពយន្ត ខ្ញុំអាចរកកន្លែងកម្សាន្តសប្បាយ ហើយខ្ញុំអាចហូបបាយពើរ៉យ៉ានី។ ខ្ញុំរកលុយបានដោយស្រួលៗ មនុស្សភាគច្រើនមិនអាចរកបានឡើយ។ សម្រាប់ខ្ញុំប្រាក់រកបានងាយណាស់ គឺការលួចប្លន់ជារឿងងាយស្រួលបំផុត។ នរណាក៏ដោយ? អ្នកខ្លះនិយាយថាៈ ប៉ូលិសនឹងចាប់ខ្ញុំ ប៉ូលិសមិនអាចចាប់ខ្ញុំបានឡើយព្រោះខ្ញុំសូកលុយពួកគាត់។ រដ្ឋមន្ត្រីខ្លះនៅក្រោមឱវាទខ្ញុំ ប៉ូលិសក៏ដូច្នោះដែរ ព្រោះខ្ញុំជាក្រុមចោរជំនាញ។ ខ្ញុំជាក្រុមម៉ាហ្វយ៉ាមានប្រទេសជាច្រើន អាចគ្រប់គ្រងមន្ត្រីនិងប៉ូលិសបានតាមរយៈការសូកប៉ាន់ ឬអំពើពុករលួយ។ ដូច្នេះ ទោះជាអ្នកផ្តល់ចម្លើយយ៉ាងណាក៏ដោយគឺគ្មានផ្លូវឡើយ ហើយខ្ញុំធ្លាប់ធ្វើការសាកល្បងរួចហើយ ជាមួយមហាជនច្រើនជាងនេះទៅទៀត ប្រាំម៉ឺននាក់ឬមួយសែននាក់ គឺគ្មាននរណាម្នាក់អាចផ្តល់ចម្លើយបានសមហេតុផលឡើយ។ ក្នុងនាមខ្ញុំមិនមែនជាមូស្លីមខ្ញុំមិនមែនមូស្លីម តែខ្ញុំជាមនុស្សហេតុផលខ្លាំងណាស់ ខ្ញុំមានជំនឿខ្លាំងណាស់ចំពោះចំណេះដឹង។ គ្មាននរណាម្នាក់អាចប្រាប់ខ្ញុំបានឡើយថា

ហេតុអ្វីបានជាចោរកម្មជាអំពើអាក្រក់ គេនឹងសម្លាប់ខ្ញុំឬ? ខ្ញុំមានអង្គរក្ស អង្គរក្សខ្ញុំនឹងសម្លាប់អ្នកមុននឹងអ្នកសម្លាប់ខ្ញុំ បាទប្អូន ខ្ញុំគិតថាអ្វីដែលអាក្រក់ចំពោះអ្នកនោះគឺ នៅពេលដែលអ្នកចាប់ផ្តើមលួច អ្នកនឹងប្រមូលទ្រព្យជាច្រើន ល្អណាស់ ទ្រព្យទាំងនោះ នឹងធ្វើឲ្យអ្នកបារម្ភក្នុងការថែរក្សាវា វានឹងធ្វើឲ្យអ្នកដេកមិនលក់ វានឹងធ្វើឲ្យគ្រួសាររបស់អ្នកមានគ្រោះថ្នាក់រហូត អ្នកនឹងបាតបង់សុវត្ថិភាព ហើយនៅពេលអ្នកបាត់បង់វាគឺអ្នកបាត់បង់អ្វីៗទាំងអស់។ បងប្រុសគាត់ថាៈ ប្រសិនបើខ្ញុំមានទ្រព្យសម្បត្តិច្រើន គឺខ្ញុំពិបាករក្សាវាណាស់ តែនៅទីនេះមានអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ច្រើនណាស់ តើពិបានរក្សាទុកវាមែនទេ? គឺស្រួលបំផុតព្រោះមានធនាគារច្រើនណាស់ ហេតុអ្វី? ខ្ញុំមិនទុកក្នុងហោប៉ៅរបស់ខ្ញុំ ដូចអ្នកដឹងស្រាប់ហើយឥឡូវមានវីហ្សាកាតទៀតផង។

ហើយគេមានសៀវភៅសែកទៀតផង។ សម្រាប់អ្នក ព្រោះអ្នកគ្មានទ្រព្យសម្បត្តិច្រើន។ នៅពេលអ្នកមានលុយចំនួន១០០០ឡៀរហាំ អ្នកពិតជាបារម្ភព្រោះខ្លាចបាត់វា ឱទាហរណ៍ខ្ញុំជាមហាសេដ្ឋី ធនាគារទាំងនោះមានសុវត្ថិភាពណាស់សម្រាប់ខ្ញុំ ប្រសិនជាខ្ញុំ ផ្ញើទុកវាក្នុងធនាគារ លើសពីនេះ នៅមានចំណេញនិងប្រយោជន៍ជាច្រើន ប្អូនប្រសុចំពោះអ្នកមានចំណូលតិចគឺគេពិបានទុកណាសប្រាក់ចំនួន១០០០ឡៀរហាំនោះ តែចំពោះខ្ញុំវិញ ជាសេដ្ឋី ប៉ុន្តែជាថ្មីម្តងទៀត អ្នកនឹងព្រួយបារម្ភព្រោះធនាគារអាចក្ស័យធន ដោយសារសេដ្ឋកិច្ចអត់ដើរ ឬបញ្ហាដែលស្រដៀង

នេះ ហើយនេះ ជាការធម្មតា ការខាតបង់នេះ វាអាចកើតឡើង។ មិត្តយើងគាត់ថាៈ បើខ្ញុំផ្ញើប្រាក់ក្នុងធនាគារ គឺអាចខាតបង់ព្រោះ សេដ្ឋកិច្ចអត់ដើរ គ្មានបញ្ហាឡើយសម្រាប់ធនាគារទាំងនោះ អ្វីដែលអ្នកមិនដឹងនោះគឺ ទោះបីមានករណីខាតបង់ដោយសាសេដ្ឋកិច្ចអត់ដើរក៏ដោយ ការរក្សាប្រាក់មិនមែនមានតែក្នុងធនាគារនោះទេ តែអ្នកអាចរក្សាប្រាក់ជាទ្រព្យក៏បាន ឬសាច់ប្រាក់ផ្ទាល់តែម្តង វាជាជម្រើសតែមួយគត់ដែលខ្ញុំប្រាប់អ្នក។ អ្នកអាចចូលភាគហ៊ុននិងអ្វីគ្រប់យ៉ាង ហើយទោះបីជាសេដ្ឋកិច្ចអត់ដើរក៏វានិងមានថ្ងៃឡើងវិញដែរ ទ្រព្យសម្បត្តិវាអាចធ្លាក់ចុះតែវាក៏អាចឡើងវិញដែរ វានឹងឡើងវិញសាជាថ្មី វាអាចអត់ដើរដល់ទៅបួនឬប្រាំឆ្នាំឯនោះ ខ្ញុំជាសេដ្ឋី គឺគ្មានបញ្ហាឡើយសម្រាប់ខ្ញុំ ដូច្នេះគឺគ្មានចម្លើយទេសម្រាប់រឿងនេះ បាទ...គឺគ្មានចម្លើយឡើយ ខ្ញុំនឹងប្រាប់ចម្លើយដល់ពួកអ្នកទាំងអស់គ្នា ខ្ញុំស្របជាមួយអ្នក គ្មានចម្លើយសមហេតុផលឡើយ ហេតុអ្វីបានជាគេចាត់ទុកអំពើចោរកម្មជាទង្វើអាក្រក់? ហេតុអ្វីបានជាការចាប់រំលោភជាអំពើមិនល្អ? ការបោកប្រាស់ក៏ដូច្នោះដែរ ឥឡូវយើងត្រឡប់ជញ្ជីងវិញម្តង អ្នកជាអ្នកមិនមែនមុស្លីម ជាចោរលួច និងជាមនុស្សមានហេតុផល និងមានចំណេះដឹង ហើយខ្ញុំជាមូស្លីមវិញម្តង ខ្ញុំជាមុស្លីម ខ្ញុំយល់ស្របជាមួយអ្នក ពិបាកណាស់ក្នុងការបញ្ជាក់ឱ្យសមហេតុផលថា អំពើចោរកម្មជាទង្វើអាក្រក់ លើកលែងតែក្នុងករណីមួយគត់ គឺនៅពេលណាខ្ញុំបញ្ជាក់ប្រាប់បុគ្គលនោះជាមុនសិនថា មាន អល់ឡោះជា

ម្ចាស់។ ខ្ញុំបានធ្វើបទបង្ហាញមួយ មានចំណងជើងថា( តើគម្ពីរគួរអានជាពាក្យសម្ដីរបស់ព្រះអល់ឡោះឬ) មានរយៈពេលពីរម៉ោង ខ្ញុំគ្មានបំណងបកស្រាយវានៅទីនេះឡើយ ដែលក្នុងនោះខ្ញុំបានបញ្ជាក់យ៉ាងសមហេតុផលសម្រាប់អ្នកមិនមែនមូស្លីម ដោយផ្អែកលើគម្ពីរគួរអាន គឺព្រះអល់ឡោះពិតជាមាន បន្ទាប់ពីខ្ញុំបានបញ្ជាក់ប្រាប់គាត់ថា មានព្រះអល់ឡោះ។ នៅក្នុងជំពូកអាន់នីសាកទី៤ឃ្លាទី៤០ទ្រង់មានបន្ទូលថា:( ពិតណាស់អល់ឡោះមិនប្រព្រឹត្តអំពើអយុត្តិធម៌ សូម្បីតូចប៉ុនល្អងធុលី)។ អ្នកមិនមែនមូស្លីមគេនឹងថា អ្នកនិយាយពីព្រះហើយខ្ញុំមានជំនឿចំពោះទ្រង់ដែរ ក៏ប៉ុន្តែអ្នកនិយាយថា ព្រះអល់ឡោះគ្មានប្រព្រឹត្តអំពើអយុត្តិធម៌ឡើយ ខ្ញុំចង់ដឹង ហើយខ្ញុំសួរអ្នកមួយសំនួរ។ ខ្ញុំយល់ស្របជាអ្នកថា បុគ្គលម្នាក់ដែលលួចគេ គឺបុគ្គលនោះនឹងសប្បាយរីករាយជាមួយនឹងទ្រព្យដែលលួចបាននោះ។ តែបើគេធ្វើបែបនេះដាក់សាច់ញាតិចោរនោះវិញ តើគេពេញចិត្តដែរឬទេ? ឧបមាថា បុរសម្នាក់មានគេលួចពីឪពុករបស់គាត់ តើគាត់ពេញចិត្តដែរឬទេ? ចម្លើយគឺៈ ទេ មានគេលួចពីមារបស់គាត់ តើគាត់សប្បាយចិត្តដែរឬទេ? ចម្លើយគឺៈ ទេ ហេតុនេះប្រសិនបើព្រះអល់ឡោះមានយុត្តិធម៌ ចុះហេតុអ្វីបានជាអំពើអយុត្តិធម៌កើតឡើងលើលោកនេះ? មានក្រុមចោរដែលយើងដឹងថា ពួកគេធ្វើសកម្មភាពឆក់លួច តែពួកគេនៅតែរស់បានសុខសប្បាយក្នុងជីវិតរបស់ពួកគេ។ ពួគគេមានភូមិគ្រឹះធំស្កឹមស្កៃ ក្រោយមកពួកគេបានស្លាប់

ហើយអ្វីៗគ្រប់យ៉ាងត្រូវចប់។ ចម្លើយមាននៅក្នុងគម្ពីគួរអាន ជំពូកអាល់មុលក៍ទី៦៧ឃ្លាទី២ ទ្រង់ជាម្ចាស់ដែលបង្កើតការស្លាប់ និងការរស់ដើម្បីសាកល្បងពួកអ្នក តើអ្នកណាមួយក្នុងចំណោមពួកអ្នកដែលបានសាងអំពើល្អជាងគេ? ហើយទ្រង់បានមានបន្ទូលនៅក្នុងជំពូកអាលអ៊ិមរ៉ននទី៣ឃ្លាទី១៨៥ថាៈ រាល់ជីវិតទាំងអស់នឹងភ្លក់រសជាតិស្លាប់។ ហើយពិតណាស់អល់ឡោះនឹងតបស្នងនូវផលបុណ្យទាំងឡាយរបស់ពួកអ្នកនាថ្ងៃបរលោក។ ដូច្នេះអ្នកណាហើយដែលត្រូវអល់ឡោះបញ្ចៀសពីភ្លើងនរក និងបានបញ្ចូលគេទៅក្នុងឋានសួគ៌នោះ គេប្រាកដជាទទួលបានជោគជ័យ។ ទ្រង់មានបន្ទូលថា អល់ឡោះនឹងតបស្នងនូវផលបុណ្យទាំងឡាយរបស់ពួកអ្នកនាថ្ងៃបរលោក។ នេះមានន័យថា គ្រាន់តែមានជំនឿលើព្រះប៉ុណ្ណោះគឺមិនទាន់គ្រប់គ្រាន់ទេ។ គោលជំនឿមួយនៃជំនឿលើព្រះអល់ឡោះ និងពួកទេវតា ព្រះគម្ពីរ និងពួកអ្នកនាំសារ និងជំនឿលើវាសនា គឺត្រូវមានជំនឿលើថ្ងៃបរលោក។ បើគ្មានជំនឿលើថ្ងៃបរលោក ដូច្នេះជំនឿលើព្រះគឺមិនគ្រប់គ្រាន់ឡើយ ដូច្នេះ អំពីគោលជំនឿលើអល់ឡោះគឺត្រូវមានជំនឿលើថ្ងៃបរលោក។ គឺជីវិតក្រោយពេលស្លាប់។ យើងដឹងហើយថា មានក្រុមចោរជាច្រើនដែលមានអំណាច ចោរប្លន់ជាច្រើនដែលមានអំណាច ក្រុមម៉ាហ្វយ៉ាដែលមានអំណាច មានមួយចំនួនត្រូវគេចាប់ហើយមួយចំនួនទៀតត្រូវគេដាក់ទោស ហើយពួកគេភាគច្រើបានរួចខ្លួនពីការដាក់ទោស ដូច្នេះ តើនេះជាការសាកល្បងអ្វីដែរ!? ហេតុនេះខ្ញុំនឹង

តបទៅកាន់ ចោរសេដ្ឋីដែលមានអំណាចនោះថា ខ្ញុំយល់ស្របជាមួយអ្នក ដែលអ្នកបានសប្បាយរីករាយនិងបានរស់ដោយសុវត្ថិភាព វាជាមុខរបរងាយស្រួលបំផុត ក៏ប៉ុន្តែ យ៉ាងណាវិញចំពោះថ្ងៃបរលោក តើដូចម្តេចទៅវិញចំពោះជីវិតក្រោយការស្លាប់? ចាំបាច់ត្រូវតែមានជីវិតចុងក្រោយមិនសមហេតុផលឡើយបើគ្មានថ្ងៃបរលោកនោះ ព្រោះជីវិតលើលោកនេះគ្មានភាពយុត្តិធម៌ជាដាច់ខាត។ នៅពេលដែលអ្នកនិយាយពីភាពយុត្តិធម៌ ដូចជា ហ៊ីត្លែរ អ្នកទាំងអស់គ្នាពិតជាស្គាល់ គាត់បានសម្លាប់ជនជាតិជិហ្វ៦លាននាក់ ឥឡូវ បើអ្នកចាប់គាត់បាន តើទណ្ឌកម្មអ្វីដែលអ្នកនឹងដាក់លើគាត់? ប្រសិនបើប៉ូលិសចាប់លោកហីត្លែរបាន តើគាត់នឹងទទួលទណ្ឌកម្មអ្វីដែរ? តាមច្បាប់ពិភពលោកសព្វថ្ងៃ? ទោសដែលធ្ងន់បំផុតនោះគឺគាត់នឹងស្លាប់តែម្តង ចុះជីវិត៥៩៩៩៩៩៩នាក់ដទៃទៀតដែលហីត្លែរសម្លាប់នោះទៅជាយ៉ាងណាវិញ?តើឯណាទៅយុត្តិធម៌ អ្នកអាចសងជីវិតគេបានតែម្នាក់ប៉ុណ្ណោះ ក៏ប៉ុន្តែនៅថ្ងៃបរលោក ទ្រង់មានបន្ទូលក្នុងជំពូកអាន់នីសាកទី៤ឃ្លាទី៥៦ពិតណាស់ ពួកដែលប្រឆាំងនឹងបន្ទូលរបស់យើង យើងនឹងបញ្ចូលពួកគេទៅក្នុងភ្លើងនរក។ រាល់ពេលដែលស្បែករបស់ពួកគេបានឆេះខ្លោចអស់យើងនឹងប្តូរស្បែកផ្សេងទៀតឲ្យពួកគេ ដើម្បីឲ្យពួកគេទទួលរសជាតិទណ្ឌកម្ម។ ប្រសិនបើទ្រង់ចង់ដុតហេត្លែរ៦លានដងគឺទ្រង់អាចធ្វើបានប្រសិនបើទ្រង់ចង់ដុតគាត់១២លានដង់គឺនៅថ្ងៃបរលោកទ្រង់នឹងធ្វើវា

បាន តែបើប៉ូលិសចាប់បានគាត់នៅលោកីយនេះ គឺប៉ូលិសអាចដាក់ទណ្ឌកម្មខ្លាំងបំផុតនោះ គឺ សម្លាប់បានបុគ្គលនេះតែម្នាក់ប៉ុណ្ណោះ នេះជាមូលហេតុសមហេតុផល ដែលជាភស្តុតាង ថា ការលួចជាអំពើអាក្រក់ និងការចាប់រំលោភ ជាទង្វើអាក្រក់នោះ អំពើពុករលួយជាទង្វើអាក្រក់ ដូច្នេះ ចាំបាច់ត្រូវតែមានការរស់ឡើងវិញ(ថ្ងៃបរលោក) បើគ្មានថ្ងៃបរលោក គឺការជំនឿលើព្រះតែប៉ុណ្ណោះមិនទាន់គ្រប់គ្រាន់ឡើយ គ្រាន់តែមានជំនឿលើព្រះអល់ឡោះគឺមិនទាន់អាចបញ្ជាក់ថា អំពើចោរកម្មជាទង្វើអាក្រក់បានឡើយ! ហេតុអ្វីបានជាការចាប់រំលោភជាអំពើអាក្រក់ ហេតុអ្វីពុករលួយជាអំពើអាក្រក់។ គ្រាន់តែយល់ពីថ្ងៃបរលោក វានឹងបកស្រាយប្រាប់យើងនូវបញ្ហាទាំងអស់នោះ ដូចទ្រង់មានបន្ទូលក្នុងជំពូកអាលអ៊ិមរ៉ននទី៣ឃ្លាទី១៨៥ថា រាល់ជីវិតទាំងអស់នឹងភ្លក់រសជាតិស្លាប់ហើយ ប្រាកដណាស់អល់ឡោះនឹងតបស្នងនូវផលបុណ្យទាំងឡាយរបស់ពួកអ្នកនាថ្ងៃបរលោក។

# សំនួរទី១៨

# ហេតុអ្វីបានជាមូស្លីមបែងចែកជាច្រើនក្រុម?

ប្រសិនបើអ្នកមូស្លីមទាំងអស់មានជំនឿលើព្រះតែមួយគត់ តាមគម្ពីរគួរអានតែមួយ មានជំនឿលើណាពីតែមួយ ចុះហេតុអ្វីបានជាមូស្លីមបែងចែកជាច្រើនក្រុម? ឆ្លើយនឹងសំនួរនេះ ផ្តល់ចម្លើយដល់យើងក្នុងគម្ពីគួរអានជំពូកអាលអ៊ិមរ៉ននទី៣ឃ្លាទី១០៣ ទ្រង់មានបន្ទូលថា: ចូរពួកអ្នកកាន់ខ្ជាប់នឹងមាគ៌ារបស់អល់ឡោះទាំងអស់គ្នា ហើយមិនត្រូវបែកបាក់គ្នាឡើយ.. ក្នុងនោះបានបញ្ជាក់ប្រាប់ពីរចំណុចៈ ត្រូវកាន់ខ្ជាប់នឹងមាគ៌ារបស់ទ្រង់ ការបញ្ជាក់ទីពីរ: ចូរកុំបែកបាក់ មាគ៌ារបស់អល់ឡោះ គឺគម្ពីរគួរអាន ទ្រង់មានបន្ទូលថា ចូរពួកអ្នកកាន់ខ្ជាប់នឹងមាគ៌ារបស់អល់ឡោះ(គម្ពីគួរអាន)ទាំងអស់គ្នា ហើយកុំបែកបាក់គ្នា។ ហើយទ្រង់មានបន្ទូលថា ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះនិងប្រតិបត្តិតាមអ្នកនាំសាររបស់ទ្រង់ ក្នុងជំពូកអាន់នីសាកទី៤ឃ្លាទី៥៩ ចាំបាច់លើយើងទាំងអស់គ្នាប្រតិបត្តិតាមអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ហើយកុំបែកបាក់គ្នា នៅក្នុងជំពូកអាន់អ៉ាមទី៦ឃ្លាទី១៥៩ព្រះអល់ឡោះទ្រង់មានបន្ទូលថា: ប្រាកដណាស់ពួកអ្នកដែលបានបំបែកសាសនារបស់ពួកគេ ដែលធ្វើឲ្យពួកគេក្លាយជាក្រុមៗនោះ អ្នក(ណាពីមូហាំម៉ាត់)គ្មានការពាក់ព័ន្ធនឹងពួកគេបន្តិចសោះឡើយ។ ពិត ណាស់កិច្ចការរបស់ពួកគេត្រូវប្រគល់ជូន

ចំពោះអល់ឡោះជាម្ចាស់។ ព្រះអល់ឡោះបានប្រាប់ណាពីមូហាំម៉ាត់ថា: ប្រសិនបើគេបែកចែកសាសនានេះទៅជាក្រុមៗ គឺគ្មានពាក់ព័ន្ធនឹងអ្នកឡើយ។ ព្រះអល់ឡោះនឹងជំនុំជម្រះគេនៅថ្ងៃបរលោក។ ក៏ប៉ុន្តែ នៅពេលយើងសួរអ្នកមូស្លីមថា អ្នកកាន់នីកាយអ្វីដែរ? អ្នកខ្លះប្រាប់ថា ខ្ញុំជាស៊ុននីត ខ្ញុំជាស៊ីអ៊ីត ខ្ញុំកាន់នីកាយហាណាហ្វី ខ្ញុំកាន់នីកាយសាហ្វីអ៊ី ខ្ញុំកាន់នីកាយហាំបាលី ខ្ញុំកាន់នីកាយម៉ាលីកី ខ្ញុំ ឪវ៉ាបាន់ឪ ខ្ញុំជាសាស្រ្តាចារ្យហាទីស ខ្ញុំជាសាឡាហ្វី ខ្ញុំជាក្រុមតស្លាម ខ្ញុំជាក្រុមតាប់លៀហ្គ ចុះណាពីយើងមូហាំម៉ាត់ជាអ្វី? គាត់ជាក្រុមអ្វីដែរ? តើគាត់ជាហាណាហ្វីឬ? ជាសាហ្វីអ៊ីឬ? ជាហាំបាលីឬ? ជាម៉ាលីកីឬ? ជាក្រុមណាដែរ? គាត់ស្ថិតនៅក្រុមណា? គាត់ជាមូស្លីមម្នាក់ ព្រះអល់ឡោះទ្រង់មានបន្ទូលក្នុងគម្ពីគួរអាន ក្នុងជំពូកអាលអ៊ិមរ៉ានទី៣ឃ្លាទី៥២ កាពិតណាស់អ៊ីសា(យេស៊ូ)ជាមូស្លីម ហើយនៅក្នុងជំពូកអាលអ៊ិមរ៉ានទី៣ឃ្លាទី៦៧ ទ្រង់មានបន្ទូលថា អ៊ីព្រហ៊ីមមិនមែនជាយ៉ាហូទីឡើយ ហើយក៏មិនមែនជាណាសរ៉ានីដែរ តែគាត់ជាអ្នកមូស្លីម ទ្រង់មានបន្ទូកក្នុងជំពូកហ្វូស៊ីឡាត់ទី៤១ឃ្លាទី៣៣ថា: ហើយគ្មានអ្នកណាម្នាក់ដែលមានពាក្យសំដីល្អប្រសើរជាងអ្នកដែលបានអំពាវនាវទៅចំពោះអល់ឡោះ និងបានសាងអំពើល្អត្រឹមត្រូវ ព្រមទាំងបាននិយាយថា ខ្ញុំឋិតក្នុងចំណោមអ្នកមូស្លីមទាំងឡាយ។ គាត់ពោលថា ខ្ញុំស្ថិតក្នុងចំណោមអ្នកមូស្លីម ហើយគន្លឹះសំខាន់សម្រាប់ការផ្សព្វផ្សាយដែលខ្ញុំលើកឡើងនេះ មានក្នុងបទបង្ហាញ

ជាច្រើន។ គន្លឹះសំខាន់ដើម្បីអំពាវនាវទៅកាន់ព្រះអល់ឡោះ ហើយវាជាឃ្លាមួយដ៏សំខាន់បំផុត ចូរអ្នក(ណាពីមូហាំម៉ាត់)ពោលថា ឱពួកម្ចាស់គម្ពីរ! ចូរពួកអ្នកត្រឡប់មករកពាក្យសំដីមួយដែលស្មើភាពគ្នារវាងពួកយើងនិងពួកអ្នក... ចូរមកដើម្បីកំណត់លក្ខខណ្ឌ ដើម្បីឱ្យយើងឯកភាពគ្នា ហើយលក្ខខណ្ឌដំបូងបង្អស់គឺៈ ចូរយើងកុំគោរពសក្ការៈក្រៅពីអល់ឡោះ ហើយកុំគោរពវត្ថុផ្សេងជាមួយនឹងអល់ឡោះ ហើយពួកយើងកុំយកគ្នាឯងធ្វើជាម្ចាស់ផ្សេងក្រៅពីអល់ឡោះ។ តែប្រសិនបើពួកគេងាកចេញ(ពីការអំពាវនាវដ៏ល្អនេះ) ចូរពួកអ្នកនិយាយទៅកាន់ពួកគេថាៈ ចូរជួយដឹងឮផងចុះថា ពួកយើងជាមូស្លីម។ ខ្ញុំជាមូស្លីម ហើយយើងទាំងអស់គ្នាជាមូស្លីម មាន២២កន្លែងជាងក្នុងគម្ពីរគួរអានដែលទ្រង់បានប្រើឲ្យយើងពោលថា យើងជាមូស្លីម នៅក្នុងជំពូកអាល់ហ្គាករ៉ោះទី២ឃ្លាទី១២៨នៅពេលដែលណាពីអ៊ីព្រហ៊ីមសុំពីព្រះអល់ឡោះជាម្ចាស់ គឺគាត់សុំពីអល់ឡោះឲ្យកូនចៅគាត់ក្លាយជាអ្នកមូស្លីម អ្នកប្រាជ្ញនិងអ្នកដឹកនាំឥស្លាមទាំងអស់ មេនិកាយទាំងបួន លោកអាពូហាណីហ្វះ អះម៉ាត់ហាំបាល ម៉ាលីក និងសាហ្វីអ៊ី។ ខ្ញុំស្រលាញ់និងគោរពពួកគាត់ទាំងអស់គ្នា។ ពួកគាត់ជាសាសនវិទូធំៗក្នុងឥស្លាម ប្រសិនបើអ្នកសួរពួកគាត់ បើអ្នកសួរ លោកអាពូហាណីហ្វះ តើលោកជាក្រុមណាដែរ? តើអ្វីទៅជាចម្លើយរបស់គាត់? តើគាត់នឹងពោលថា ម៉េចដែរ? ខ្ញុំជាមូស្លីម យើងស្រលាញ់ពួកគាត់និងគោរពពួកគាត់ ហើយពួកគាត់ទាំងអស់គ្នាបាន

មានប្រសាសន៍ថា ប្រសិនបើអ្នកឃើញគំនឹងទស្សនៈរបស់ខ្ញុំផ្ទុយពីមានគំារបស់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់នោះចូរពួកអ្នកកុំទទួលស្គាល់ទស្សនៈរបស់ខ្ញុំឲ្យសោះ ពួកយើងស្រលាញ់ពួកគាត់និងគោរពពួកគាត់ ពួកគាត់ទាំងអស់មកបញ្ជិតខ្លួនចំពោះឥស្លាមដើម្បីបង្រៀនយើងពីឥស្លាមនិងប្រាប់យើងពីរបៀបអនុវត្តឥស្លាម ពួកគាត់ពុំបានមកដើម្បីបែងចែកសាសនាឥស្លាមឡើយ។ អល់ឡោះទ្រង់មានបន្ទូលក្នុងគម្ពីគួរអាននៅជំពូកអាន់នីសាកទី៤ឃ្លាទី៥៩ថា ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងប្រតិបត្តិតាមអ្នកនាំសារ និងមេដឹកនាំរបស់ពួកអ្នក។ គឺអ្នកដែលមានចំណេះដឹងរវាងពួកអ្នក ហេតុនេះបានគេនិយាយថា ចូរមានជំនឿចំពោះព្រះអល់ឡោះនិងអ្នកនាំសារបន្ទាប់មកត្រូវតាមអ្នកមានចំណេះដឹង។ ក៏ប៉ុន្តែពួកគេបានដាក់ចំណុចចុងក្រោយ ដោយមិនបានលើកឡើងខាងលើ ហើយឃ្លាខាងលើក៏មិនទាន់បញ្ចប់ដែរ ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងប្រតិបត្តិតាមអ្នកនាំសារ និងមេដឹកនាំរបស់ពួកអ្នក។ ក្រោយមកប្រសិនបើពួកអ្នកខ្វែងគំនិតគ្នាពីកិច្ចការអ្វីមួយ ចូរពួកអ្នកបង្វិលប្រការនោះត្រលប់ទៅរកអល់ឡោះនិងអ្នកនាំសាររបស់អល់ឡោះ។ នៅពេលដែលអ្នកបានឃើញអ្នកប្រាជ្ញឥស្លាមទាំងអស់ឯកភាពគ្នាលើអ្វីមួយនោះ អ្នកមិនចាំបាច់ស្រាវជ្រាវទៀតឡើយ។ ពួកគាត់ទាំងអស់គ្នាបាននិយាយថា ចូរអ្នកសឡាត គឺគ្មានបញ្ហាឡើយ.....ពួកគាត់ថា ចូរអ្នកបួស

គឺគ្មានបញ្ហាឡើយ។ តែប្រសិនបើពួកគាត់ខ្វែងគំនិតគ្នា ចូរពួកអ្នកបង្វិលរឿងនោះត្រលប់ទៅរកអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់។ ដូច្នេះប្រាប់ខ្ញុំមក កន្លែងណាដែលថាឥស្លាមបែងចែកជាក្រុមនោះ? នេះជាពាក្យសំដីណាពីមូហាំម៉ាត់នៅក្នុងសូណាន់អាពីដាវូត លេខទី៤៥៧៩គាត់បានមានប្រសាសន៍ថាៈ ប្រជាជាតិរបស់ខ្ញុំនឹងបែកជា៧៣ក្រុម ហេតុនេះមានមនុស្សនិយាយថា ណាពីដឹងមុន ក៏ប៉ុន្តែគាត់មានប្រសាសន៍ថា នឹងកើតឡើង គាត់មិនបានថា ចូរពួកអ្នកបង្កើតឡើយ អ្នកនាំសារបានប្រាប់ថា នឹងមាន៧៣ក្រុម ក៏ប៉ុន្តែគាត់មិនបានប្រើឲ្យយើងបង្កើតជាក្រុមៗក្នុងឥស្លាមឡើយ អល់ឡោះបានបញ្ជាក់យ៉ាងច្បាស់ក្នុងជំពូកអាន់អ៊ាមទី៦ឃ្លាទី១៥៩ថា ប្រាកដណាស់ពួកអ្នកដែលបានបំបែកសាសនារបស់ពួកគេ ដែលធ្វើឲ្យពួកគេក្លាយជាក្រុមៗនោះ អ្នក(ណាពីមូហាំម៉ាត)គ្មានពាក់ព័ន្ធនឹងពួកគេបន្តិចសោះឡើយ។ អ្នកនាំសារបានឱ្យដឹងថា នឹងកើតមាន៧៣ក្រុម ក៏ប៉ុន្តែគាត់មិនបានថា ចូរអ្នកត្រូវតែបង្កើតវាឡើយ។ ហើយមានហាទីសណាពីផ្សេងទៀតនៅក្នុងសូណាន់តៀរមីស៊ុ បានបញ្ជាក់ថា ជាការពិតណាស់នឹងមាន៧៣ក្រុមក្នុងឥស្លាមទាំងនោះនឹងចុះនរកលើកលែងតែមួយគត់ ហើយសហាការីរបស់គាត់បានសួរថា តើមួយក្រុមណា? គាត់បានប្រាប់ថា អ្នកដែលតាមខ្ញុំនិងតាមសហាការីរបស់ខ្ញុំបន្ទាប់ពីខ្ញុំ គឺអ្នកដែលតាមគម្ពីរគួរអាននិងពាក្យសំដីដែលត្រឹមត្រូវរបស់ណាពី។ ប្រសិនបើអ្នកតាមគម្ពីរគួរអាននិងពាក្យសំដីរបស់ណា

ពី គឺអ្នកនឹងឋិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ ដូច្នេះគ្មានក្រុមក្នុងឥស្លាម ឥស្លាមជាសាសនាតែមួយ ហើយគម្ពីរគួរអានតែមួយ ហើយអ្នកនាំសារក៏តែមួយដែរ។ ដូច្នេះយើងត្រូវតែតាមគម្ពីរគួរអាននិងការបង្រៀន និងពាក្យទូន្មានរបស់អ្នកនាំសារ។

# សំនួរទី១៩

# ហេតុអ្វីបានជាយើងត្រូវធ្វើតាមសាសនាអ៊ីស្លាមតែមួយគត់នោះ?

ប្រសិនបើអ្នកសិក្សាអ្នកនឹងរកឃើញថាសាសនាភាគច្រើនបង្រៀនយើងនូវអ្វីដែលល្អ មិនឱ្យយើងលួច, មិនឱ្យយើងក្បត់, មិនឱ្យយើងចាប់រំលោភ ប្រសិនបើសាសនាភាគច្រើនបង្រៀនយើងនូវអ្វីដែលល្អ, ហេតុអ្វីបានជាយើងត្រូវធ្វើតាមសាសនាអ៊ីស្លាមតែមួយគត់នោះ? វាជាសំណួរល្អ .... ប្រសិនបើសិនជាអ្នកសិក្សាស្រាវជ្រាវអ្នកនឹងរកឃើញថាសាសនាភាគច្រើន ជាគោលការណ៍ ពិតជាបានជំរុញឱ្យ ប្រព្រឹត្តអ្វីដែលល្អមែន ដូច្នេះហេតុអ្វីបានជាយើងត្រូវធ្វីតាមសាសនាអ៊ីស្លាម? ចម្លើយនឹងសំណួរនេះគឺ: ខ្ញុំយល់ស្របថាសាសនាភាគច្រើនជាគោលការណ៍បានជំរុញឱ្យប្រព្រឹត្តអំពើល្អ។ ប៉ុន្តែភាពខុសគ្នាក្នុងសាសនាអ៊ីស្លាមគឺវាបានបង្ហាញពីវិធីសាស្រ្តដែលនាំអ្នកឈានទៅដល់ សុចរិតភាព យើងនឹងលើកឧទាហរណ៍មួយ សាសនាទាំងអស់បានបញ្ជាមិនឱ្យលួចដូចជាសាសនាហិណ្ឌូ, គ្រិស្តសាសនានិងសាសនាអ៊ីស្លាមផងដែរ ដូច្នេះតើកន្លែងណាដែលជាភាពខុសគ្នារវាងសាសនាអ៊ីស្លាមនិងសាសនាផ្សេងទៀត? ភាពខុសគ្នានោះគឺសាសនាអ៊ីស្លាមបង្រៀនអ្នកពីរបៀប

មួយដែលធ្វើឱ្យមនុស្សមិនលួច សាសនាអ៊ីស្លាមមានប្រព័ន្ធ Zakat ដែលធ្វើឱ្យអ្នកដែលមានទ្រព្យលើសពីបរិមាណដែលគេកំណត់ បានសេចក្តីថាលើសពីទម្ងន់មាស 85 ក្រាម ចាំបាច់លើគេត្រូវដក 2,5% នៃទ្រព្យសម្បត្តិរបស់គេដើម្បីអំពើល្អឬបរិច្ចាគវារៀងរាល់ឆ្នាំគិតតាមឆ្នាំចន្ទគតិ។ ប្រសិនបើអ្នកមានទាំងអស់គាត់ផ្តល់ Zakat នោះភាពក្រីក្រនឹងត្រូវបានលុបបំបាត់ពីពិភពលោកហើយនឹងគ្មានមនុស្សណាម្នាក់ស្លាប់ដោយសារភាពអត់ឃ្លានទៀតដែរ។ បន្ទាប់ពីការផ្តល់ទាំងនេះរួចហើយ គម្ពីរគួរអានបានបកស្រាយនៅក្នុងជំពូក អាល់ម៉ាអ៊ីដះទី៥ ឃ្លាទី៣៨ ថា ចោរប្រុសនិងចោរស្រី ចូរពួកអ្នកកាត់ដៃគេទាំងពីរនាក់ជាការតបស្នងនូវអ្វីដែលពួកគេទាំងពីរបានប្រព្រឹត្តជាទណ្ឌកម្មពីអល់ឡោះ។ហើយអល់ឡោះមហាខ្លាំងពូកែ មហាគតិបណ្ឌិត។ កាត់ដៃនៅក្នុងសម័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅសតវត្សរ៍ទី 21 នេះ? សាសនាអ៊ីស្លាមចាំបាច់ត្រូវតែជាសាសនាព្រៃផ្សៃ ហើយជាវិថីជីវិតគ្មានមេត្តា ហើយខ្ញុំនឹងសួរពួកគេមួយសំនួរ សព្វថ្ងៃនេះអាមេរិកបានក្លាយទៅជាប្រទេសអភិវឌ្ឍន៍ខ្លាំងបំផុតនៅលើលោក ប៉ុន្តែតើអ្នកដឹងទេ? វាជាប្រទេសដែលមានអត្រាការលួចនិងប្លន់ធំជាងគេ ខ្ញុំសួរសំនួរមួយ ប្រសិនបើអនុវត្តច្បាប់អ៊ីស្លាមនៅអាមេរិក នៅក្នុងសហរដ្ឋអាមេរិក គ្រប់អ្នកមានទាំងអស់ និងអ្នកដែលមានទ្រព្យសម្បត្តិច្រើនជាងទម្ងន់មាស ៨៥ ក្រាម ចាំបាច់ត្រូវតែដក 2,5% នៃប្រាក់សន្សំរបស់ខ្លួនរៀងរាល់ឆ្នាំចន្ទគតិសម្រាប់បរិច្ចាគនិងធ្វើវិភាគទាន

បន្ទាប់ពីនោះប្រសិនបើមានបុគ្គលណាម្នាក់លួចគេមិនថាជាបុរសឬស្ត្រី ត្រូវកាត់ដៃរបស់គាត់ជាការដាក់ទណ្ឌកម្ម ខ្ញុំសួរមួយសំនួរ តើអត្រានៃការលួចនឹងកើនឡើងទៀតទេនៅក្នុងសហរដ្ឋអាមេរិក? តើវានៅដូចដើមឬវាថយចុះ? កើនឡើង?ថយចុះ?ឬក៏នៅដូចដើម? ថយចុះ នេះច្បាប់ដែលអនុវត្តជាក់ស្តែង ប្រសិនបើអនុវត្តតាមច្បាប់ស្ហារីអាត់នឹងទទួលបានលទ្ធផល ប្រសិនបើអនុវត្តតាមច្បាប់អ៊ីស្លាម, ទោះបីជាមិនមែននៅក្នុងប្រទេសអ៊ីស្លាមក៏ដោយ ប្រសិនបើអនុវត្តវានៅក្នុងសហរដ្ឋអាមេរិចវានិងទទួលបានលទ្ធផល។ នេះគឺជាមូលហេតុ ខ្ញុំថាសាសនាអ៊ីស្លាមបើនិយាយពីផ្លូវល្អវិញគឺបង្ហាញអ្នកពីវិធីដែលនាំឱ្យដល់ផ្លូវល្អតែម្តង មានជាច្រើនគិតថា ប្រសិនបើខ្ញុំបានទៅអារ៉ាប៊ីសេអូឌីត ជាប្រទេសដែលអនុវត្តច្បាប់នេះ ពួកគេនិងគិតថាអ្នកនឹងមើលឃើញមនុស្សដាច់ដៃគ្រប់នាទីដោយសារតែការអនុវត្តច្បាប់នេះ ពិតណាស់ ខ្ញុំបានទៅអារ៉ាប៊ីសេអូឌីតច្រើនជាង៥០ដងរួចមកហើយ តែខ្ញុំមិនដែលបានជួបប្រទះនរណាម្នាក់ដៃដែសូម្បីតែម្តង ប្រហែលជានៅទីនោះមានមនុស្សដែលត្រូវបានកាត់ដៃរបស់ពួកគេ ប៉ុន្តែពួកគេមិនច្រើនដូចជាពួកអ្នកគិតនោះទេ ច្បាប់នេះគឺតឹងរ៉ឹងណាស់ មនុស្សនិងគិតមួយម៉ឺនដងមុននឹងលួច ប្រសិនបើច្បាប់នេះធូររលុង ប្រសិនបើអារ៉ាប៊ីសេអូឌីតផ្អាក់ការអនុវត្តច្បាប់នេះភ្លាមៗនោះអ្នកនឹងឃើញមានចោរកម្មកើនឡើងតែម្តង។ មិនមែនដោយសារប៉ូលីសឆ្លាតខ្លាំងនោះទេ ប៉ុន្តែដោយសារច្បាប់នេះតឹងរ៉ឹងង វាជាច្បាប់របស់

អល់ឡោះជាម្ចាស់។ ប្រសិនបើច្បាប់នេះធូររលុង សូម្បីតែនៅក្នុងប្រទេសនោះក៏ដោយអ្នកនឹងឃើញចោរកម្មកើនឡើងជាថ្មីម្តងទៀត វាជាច្បាប់អនុវត្តជាក់ស្តែង អនុវត្តច្បាប់នេះទទួលបានលទ្ធផល ទុកឱ្យខ្ញុំលើកឧទាហរណ៍ផ្សេងទៀត សាសនាភាគច្រើនបាននិយាយថាការបៀតបៀនក្មេងស្រីខុស ការចាប់រំលោភក្មេងស្រីខុស សាសនាហិណ្ឌូបាននិយាយដូច្នោះ សាសនាជីហ្វក៏និយាយដូច្នោះ សាសនាគ្រិស្តក៏និយាយដូច្នោះដែរ សាសនាអ៊ីស្លាមក៏និយាយដូចគ្នានេះដែរ តើអ្វីជាភាពខុសគ្នារវាងសាសនាអ៊ីស្លាមនិងសាសនាផ្សេងទៀត? ភាពខុសគ្នាគឺសាសនាអ៊ីស្លាមចង្អុលបង្ហាញអ្នកទៅកាន់ផ្លូវដើម្បីឱ្យស្ថានភាពនោះសម្រេចបានជោគជ័យ ដោយធ្វើឱ្យមនុស្សដែលបៀតបៀននិងលែងចាប់រំលោភស្រ្តី។ សាសនាអ៊ីស្លាមនិយាយពីប្រព័ន្ធច្បាប់នៃការបិទបាំងរាងកាយ(ហ៊ីជើព) តាមធម្មតានៅពេលដែលអ្នកបានអានសៀវភៅ អ្នកនឹងបានឃើញអ្នកនិពន្ធនិងអ្នកប្រាជ្ញនិយាយពីការបិទបាំងរាងកាយរបស់ស្រ្តី ក៏ប៉ុន្តែអល់ឡោះបានមានបន្ទូលនៅក្នុងគម្ពីរគួរអាន ជាដំបូងទ្រង់និយាយពីការបិទបាំងរាងកាយបុរស បន្ទាប់មកនិយាយការបិទបាំងរាងកាយរបស់ស្រ្តី។ អល់ឡោះបានមានបន្ទូលនៅក្នុង ជំពូកអាន់នួរទី ២៤ ឃ្លាទី៣០ ចូរអ្នក(ណាពីម៉ូហាំមាត់)ពោលទៅកាន់បណ្តាបុរសដែលមានជំនឿឱ្យពួកគេដាក់ក្រសែភ្នែករបស់ពូកគេចុះពីការសម្លឹងមើលហើយឱ្យពួកគេថែរក្សាប្រដាប់ភេទរបស់ពួកគេ នៅពេលបុរសម្នាក់

សម្លឹងមើលស្រ្តី នៅពេលដែលមានអារម្មណ៍ស្រើបស្រាលកើតដល់ខួរក្បាលរបស់គេ គេចាំភ្នែកចុះកុំសម្លឹងមើល។ មានពេលមួយនោះមានមូស្លីមម្នាក់បានសម្លឹងមើលទៅស្រ្តីយ៉ាងយូរ ខ្ញុំបាននិយាយទៅកាន់គាត់ថា ប្អូនប្រុស តើអ្នកកុំពុងធ្វើអ្វី? វាត្រូវបានហាមនៅក្នុងសាសនាអ៊ីស្លាមពិតណាស់ ព្យាការីជាទីស្រឡាញ់របស់ពួកយើងបានមានប្រសាសប្រាប់ខ្ញុំថា មើលលើកដំបូងគេអត់ឱន លើកទីពីរបានគេហាមឃាត់ ខ្ញុំមិនទាន់បានមើលលើកទី១បានពាក់កណ្ដាលផង នេះមិនមែនមានន័យថាអ្នកសម្លឹងមើស្រ្តីដប់នាទីដោយមិនព្រិចភ្នែកនោះទេ ហើយអ្នកក៏និយាយថាខ្ញុំមិនទាន់បានបញ្ចប់ការមើលរបស់ខ្ញុំផង អ្វីជាបំណងរបស់ព្យាការីប្រសិនបើអ្នកមើលស្រ្តីដោយគ្មានបំណង ចូកុំមើលនាងម្ដងទៀតព្រោះអ្នកនឹងឃើញភាពស្រស់ស្អាតរបស់នាង។ ឃ្លាបន្ទាបពីឃ្លាដែលនិយាយពីការបិទបាំងរាងកាយរបស់បុរសគឺនិយាយពីការបិទបាំងរាងកាយកន្សែងរបស់ស្រ្តី។ អល់ឡោះបានមានបន្ទូលនៅក្នុងជំពូកអាន់នួរទី២៤ ឃ្លាទី៣១ ចូរអ្នក(ណាពីមូហាំម៉ាត់)ពោលទៅកាន់បណ្ដាស្រ្តីដែលមានជំនឿឱ្យពួកនាងដាក់ក្រសៃភ្នែករបស់ពួកនាងចុះកុំសម្លឹងមើល ហើយឱ្យពួកនាងថែរក្សាប្រដាប់ភេទរបស់ពួកនាង។ ហើយកុំឱ្យពួកនាងបង្ហាញសម្រស់របស់នាងលើកលែងតែអ្វីដែលបានស្ដែងចេញជាធម្មតា ហើយឱ្យពួកនាងគ្របក្បាលឱ្យជិត បរិវេណដើមទ្រូងនិងកររបស់នាង ហើយពុំត្រូវបង្ហាញសម្រស់នៅមុខបុរសណាក្រៅពីស្វាមីរបស់ពួកនាង ឪពុក

របស់ពួកនាង ឪពុកក្មេករបស់ពួកនាង និងមានមួយចំនួនផ្សេងទៀត ដែលនាងមិនអាចរៀបការជាមួយពួកគេបាន ស្គង់ដារក្រណាត់គ្រប ក្បាលនិងខ្លួន( ហ៊ីហ្សាប )ដែលយើងតែងតែនិយាយពីទំហំរបស់វា។ ស្ត្រី ត្រូវគ្របរាងកាយទាំងមូល ផ្នែកតែមួយគត់ដែលអាចឱ្យឃើញបាននោះ គឺមុខនិងប្រអប់ដៃ ហើយវាក៏បានលើកឡើងនៅក្នុងគួរអានជំពូកអាល់ អះហ្សាបទី៣៣ ឃ្លាទី៥៩ អល់ឡោះបានមានបន្ទូលថា ឱណាពី!ចូរអ្នក ប្រាប់បណ្តាភរិយារបស់អ្នកនិងកូនស្រីទាំងឡាយរបស់អ្នក និងស្ត្រីរបស់ បណ្តាអ្នកមានជំនឿពាក់អាវឱ្យហៀរលុងគ្រប់រាងកាយរបស់ពួកនាង ធ្វើដូច្នេះគេមើលស្គាល់ពួកនាង ហើយពួកនាងក៏មិនអាចត្រូវគេ មើលងាយដែរ។ គួរអានបាននិយាយថា ចូរអ្នក( ណាពីមូហាំម៉ាត់ ) ពោលទៅកាន់បណ្តាស្ត្រីមានជំនឿ នៅពេលពួកគេចេញទៅក្រៅត្រូវ ពាក់អាវវែងបិទបាំងខ្លួនប្រាណ អាវវែងនេះធ្វើឱ្យគេស្គាល់ពួកនាង ហើយការពារពួកនាងពីការមើលងាយ ឧទាហរណ៍ ប្រសិនបើមាននារីពីរ នាក់ជាបងប្អូនភ្លោះនឹងគ្នាហើយគេទាំងពីរមានរូបស្រស់ស្អាតដូចគ្នា។ ហើយគេទាំងពីរដើរតាមដងផ្លូវនៅទីក្រុងឌូបៃ ឬប្រហែលជាដើរនៅ តំបន់ជូម៉ៃរ៉ា ហើយម្នាក់ពាក់សម្លៀកបំពាក់ឥស្លាមដែលគ្របខ្លួនគេ ទាំងមូលលើកលែងតែមុខនិងប្រអប់ដៃប៉ុណ្ណោះ ហើយម្នាក់ទៀតពាក់ស ម្លៀកបំពាក់បែបអឺរ៉ុប សំពត់ខ្លីនិងខោខ្លី ឬស្លៀកលេចក្បាលជង្គង់ ប្រសិនបើពួកគេទាំងពីរដើរនៅតាមដងផ្លូវ នៅតំបន់ជូម៉ៃរ៉ោះ ហើយមាន

ស្ពាវមួយក្រុមចាំញ៉ែស្រី ខ្ញុំចង់សួរអ្នកមួយសំនួរថាតើក្មេងស្រីមួយណាពួកគេនឹងញ៉ែ? តើគេនឹងទៅញ៉ែនារីស្លៀកពាក់សំលៀកឥស្លាមឬ? ឬក៏ទៅញ៉ែនារីដែលស្លៀកខ្លីនោះ? នារីមួយណាដែលពួកគេនឹងញ៉ែ? នារីមួយណា? នារីដែលស្លៀកខ្លី គួរអានបានប្រាប់យ៉ាងច្បាស់ថា ការដែលបង្គាប់ឲ្យស្ត្រីគ្របខ្លួនប្រាណគឺដើម្បីការពារពួកនាង។ កុំឲ្យមានការបៀតបៀនលើរាងកាយរបស់នាង បន្ទាប់ពីនេះច្បាប់អ៊ីស្លាមក៏បាននិយាយថា បើសិនមានករណីបុរសចាប់រំលោភស្ត្រី ច្បាប់ឥស្លាមដាក់ទោសប្រហាជីវិត អ្នកមិនមែនមូស្លីមនឹងនិយាយថា: ទោសប្រហារជីវិតនៅក្នុងសម័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ឥស្លាមពិតជាសាសនាព្រៃផ្សៃណាស់ ការរស់នៅពិតជាគ្មានធម៌មេត្តាមែន ខ្ញុំនឹងឆ្លើយតបទៅគេវិញដោយខ្ញុំនិយាយថាប្រសិនបើមាននរណាម្នាក់បានរំលោភម្តាយឬបងស្រីរបស់អ្នក ហើយអ្នករំលោភនោះបានដើរកាត់មុខអ្នក តើអ្នកនឹងដាក់ទោសគេយ៉ាងដូចម្តេច? ជឿខ្ញុំទៅ មួយរយភាគរយពួកគេនឹងដាក់ទោសប្រហារជីវិត ប្រសិនបើនរណាម្នាក់មករំលោភម្តាយរបស់គាត់ គាត់និងទាមទារឱ្យគេដាក់ទោសប្រហារជីវិត តែប្រសិនបើជាម្តាយអ្នកដទៃវិញពួកគេនឹងនិយាយថាទោសប្រហារជីវិតគឺជាទោសព្រៃផ្សៃបំផុត។

ហេតុអ្វីបានមុខពីរបែបនេះ?? សព្វថ្ងៃនេះយើងមើលទៅប្រទេសអាមេរិចដូចជាប្រទេសរីកចំរើនខ្ពស់បំផុតនៅលើសកលលោក តើអ្នកដឹងទេថាដោយផ្អែកលើស្ថិតិអាមេរិកជាប្រទេសដែលមានការចាប់រំលោភសេពស

នូវៈច្រើនជាងគេបំផុតនៅក្នុងពិភពលោក ដូចដែលខ្ញុំបានរៀបរាប់ពីដើមអ៊ីចឹង នៅឆ្នាំ១៩៩០ ចំនួននៃករណីចាប់រំលោភសេពសន្ថវៈក្នុងមួយថ្ងៃ ១៧៥៦ករណី ប្រសិនបើយើងក្រឡេកមើលទៅស្ថិតិក្នុងឆ្នាំ១៩៩៦ បន្ទាប់ពីនោះប្រាំមួយឆ្នាំ យោងតាមក្រសួងយុត្តិធម៌រាល់ថ្ងៃមាន ២៧១៣ករណីនៃការចាប់រំលោភសេពសន្ថវៈកើតឡើង ជួនកាលជនជាតិអាមេរិកអាចក្លាយជាជនជាតិមួយហ៊ានខ្លាំងជាងគេ ដោយរៀងរាល់ ៣២វិនាទីកើតឡើងនូវករណីចាប់រំលោភសេពសន្ថវៈនៅក្នុងអាមេរិក រៀងរាល់ ៣២វិនាទី រយៈមួយម៉ោងតាំងពីចាប់ផ្តើមធ្វើបទបង្ហាញនេះមានច្រើនជាង៥០ករណីនៃការចាប់រំលោភសេពសន្ថវៈនៅអាមេរិកក្នុងអំឡុងពេលនៃការធ្វើបទបង្ហាញនេះ។ តើអ្នកដឹងទេថាស្ថិតិនឹងនិយាយដូចម្តេច ស្ថិតិបានឱ្យដឹងថានៅឆ្នាំ១៩៩០ទាំងមូលបានកើតឡើងនូវករណីចាប់រំលោភសេពសន្ថវៈ១០២៥៥៥ករណី មានតែ១៦%ប៉ុណ្ណោះត្រូវបានគេរាយការណ៍ ដូច្នេះពួកគេជឿជាក់ថាតួលេខពិតត្រូវបានគុណនឹង១៦.២៥ គឺ ៦៤០.៩៦៨ ករណី ដោយចែកជាមួយនឹង៣៦៥ថ្ងៃវាស្មើនឹង ១៧៥៦ករណីក្នុងមួយថ្ងៃ ហើយរបាយការណ៍បន្តថា.. តែដប់ភាគរយនៃចំនួនសរុបដែលកើតឡើងប៉ុណ្ណោះ ត្រូវបានចាប់ខ្លួន នេះមានន័យថា ១.៦%នៃជនល្មើសត្រូវបានចាប់ខ្លួន ក្នុងចំនោមអ្នកដែលត្រូវបានចាប់ខ្លួននោះហាសិបភាគរយបានដោះលែង នេះមានន័យថាមានតែ ០.៨%ប៉ុណ្ណោះដែលធ្វើការត្រូវបញ្ជូនទៅតុលាការ ៥០%ទៀតត្រូវ

បានចេញផ្សាយមុនពេលកាត់ទោស មានន័យថាជារៀងរាល់ ១២៥ ករណីរំលោភកើតឡើងនៅពេលដែលជំនុំជម្រះក្តីគិតតែម្តងប៉ុន្នោះ ភាគរយនៃគ្រោះថ្នាក់ខ្លាំងបំផុត រាល់ក្មេងស្រី ១២៥នាក់ដែលអ្នកបានចាប់រំលោភ គឺអ្នកប្រឈមនឹងការដាក់ទោសតែម្តងប៉ុណ្ណោះ តើអ្នកណាមិនចង់ធ្វើវា ស្ថិតិបានប្រាប់ថាចៅក្រមបាននិយាយថានេះ បើសិនជាអ្នកជាជនល្មើសចាប់រំលោភសេពសន្ថវៈលើកដំបូងអ៊ីចឹងអ្នកត្រូវជាប់ពន្ធនាគារតែមួយឆ្នាំប៉ុណ្ណោះ ច្រើនជាង៥០%នៃជនល្មើសចាប់រំលោភត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារមួយឆ្នាំខណៈពេលដែលច្បាប់បានចែងថាប្រាំពីរឆ្នាំ ក៏ប៉ុន្តែចៅក្រមចិត្តល្អ គាត់និយាយថា នេះជាលើកដំបូង ១២៥ករណីនៃការរំលោភសេពសន្ថវៈដែលអ្នកបានប្រព្រឹត្តដល់ពេលគេចាប់បានម្តងចៅក្រមនិយាយថានេះជាលើកដំបូង អ៊ីចឹងត្រូវជាប់ពន្ធនាគារមួយឆ្នាំ ខ្ញុំសួរអ្នកមួយសំនួរៈ ប្រសិនបើច្បាប់ឥស្លាមត្រូវបានអនុវត្តនៅក្នុងប្រទេសអាមេរិក បុរសណាក៏ដោយឱ្យមើលឃើញស្រីៗត្រូវដាក់ភ្នែកចុះ ហើយស្ត្រីត្រូវតែបិទបាំងជិតរាងកាយរបស់នាងលើកលែងតែមុខនិងប្រអប់ដៃរបស់នាង។ បន្ទាប់មកប្រសិនបើបុរសណាចាប់រំលោភស្ត្រីណាម្នាក់គឺត្រូវមានទោសប្រហារជីវិត ខ្ញុំសុំសួរសំនួរថាតើអត្រានៃការចាប់រំលោភសេពសន្ថវៈក្នុងប្រទេសអាមេរិកកើនឡើងឬនៅដដែលឬថយចុះ? វានឹងថយចុះ ដោយសារវាជាច្បាប់អនុវត្តជាក់ស្តែង អនុវត្តច្បាប់ឥស្លាមនឹងទទួលបានលទ្ធផល។ នេះជាហេតុផលដែលមាន

អត្រាឧក្រិដ្ឋកម្មពិភពលោកទាបបំផុតនៅក្នុងប្រទេសអារ៉ាប៊ីសេអូឌីត។ ហេតុអ្វី?បានជាអនុវត្តច្បាប់នេះត្រូវទទួលបានលទ្ធផល។ ហេតុនេះហើយបានជាយើងឃើញថាសាសនាឥស្លាមមិនត្រឹមតែប្រើឱ្យធ្វើល្អបុណ្ណោះទេ តែថែមទាំងប្រាប់អ្នកពីរបៀបដើម្បីឈានទៅដល់ប្រការល្អនោះទៀត។ ហេតុនេះហើយបានជាសាសនាដទៃទៀតភាគច្រើនមានតែទ្រឹស្តីខណៈពេលដែលសាសនាឥស្លាម ជាសាសនាអនុវត្តជាក់ស្តែង អនុវត្តជាក់ស្តែងប្រសិនបើអ្នកយកចិត្តទុក្ខដាក់ពីមនុស្សជាតិ អនុវត្តជាក់ស្តែងប្រសិនបើអ្នកគឺជាមនុស្សតែម្នាក់គត់នៅលើពិភពលោក ដែលអាចទទួលរងនូវផុតពូជសាសន៍។ ដូច្នេះអ្នកត្រូវតែទទួលយក សាសនាឥស្លាម។

# សំនួរទី២០

# ហេតុអ្វីបានជាមានភេរវករភាគច្រើនជាជនមូស្លីម?

សំនួរទីម្ភៃនិងជាសំនួរចុងក្រោយនៅក្នុងមាតិកា ជាសំនួរដែលល្បីសុសសាយពីសំណាក់អ្នកមិនមែនមូស្លីមនោះគឺៈ បើសិនជាសាសនាឥស្លាមជាសាសនាល្អប្រសើរជាងសាសនាផ្សេងៗនោះ ហេតុអ្វីបានជាមានភេរវករភាគច្រើនជាជនមូស្លីម ចោរភាគច្រើនជាជនមូស្លីម មនុស្សបោកប្រាស់ភាគច្រើនជាជនមូស្លីម តើហេតុអ្វី? បើសិនជាសាសនាឥស្លាមជាសាសនាល្អប្រសើរជាងសាសនាផ្សេងៗនោះ ហេតុអ្វីបានជាជនមូស្លីមភាគច្រើនជាមនុស្សអាក្រក់បំផុត ឆ្លើយតបនឹងសំនួរនេះ កត្តាមួយនៃកត្តាធំជាងគេដែលបានធ្វើឱ្យបាក់ផ្ទត់ ដែលនិយាយថារាល់ៗភេរវករជាជនមូស្លីមទាំងអស់ហើយពួកគេភាគច្រើនជាមនុស្សបោកប្រាស់ និងជាមនុស្សពុករលួយ នោះគឺ ប្រព័ន្ធផ្សព្វផ្សាយ ជាងប្រាំឆ្នាំកន្លងមកហើយនៅពេលគេអញ្ជើញខ្ញុំឱ្យទៅទទួល ពានរង្វាន់គម្ពីរគួរអានអន្តរជាតិនាទីក្រុងឌូបៃជាលើកទីពីរ ក្រោមការឧបត្ថម្ភរបស់លោក Sheikh Mohammed bin Rashid Al Maktoum ខ្ញុំបានធ្វើបទបង្ហាញមួយនៅថ្ងៃបន្ទាប់ ប្រព័ន្ធផ្សព្វផ្សាយនិងសាសនាឥស្លាម, សង្គ្រាមឬសន្តិភាព ខ្ញុំ

បានរៀបរាប់ពន្យល់យ៉ាងលម្អិត តើអ្វីទៅជាយុទ្ធសាស្ត្ររបស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីប្រយុទ្ធប្រឆាំងនឹងសាសនាឥស្លាម ហើយខ្ញុំបាននិយាយដែរថាសាសនាឥស្លាមគឺជាដំណោះស្រាយពេញលេញសម្រាប់បញ្ហាទាំងអស់របស់មនុស្សជាតិ ប្រព័ន្ធផ្សព្វផ្សាយបាននិយាយថាសាសនាឥស្លាមគឺជាបញ្ហារបស់មនុស្សជាតិ តែការពិត សាសនាឥស្លាមគឺជាដំណោះស្រាយសម្រាប់រាល់បញ្ហាទាំងអស់របស់មនុស្សជាតិ ហេតុនេះហើយបានជាចំណងជើងឆានែល ដែលនៅក្រោមឆានែលសាឡាមគឺ មានចំណងជើងថា " ដំណោះស្រាយសម្រាប់រាល់បញ្ហាមនុស្សជាតិ" នេះមានន័យថាសាសនាឥស្លាម គឺជាដំណោះស្រាយពិតប្រាកដសម្រាប់បញ្ហាមនុស្សជាតិ តើប្រព័ន្ធផ្សព្វផ្សាយកំពុងធ្វើអ្វី ដោយសារតែពេលវេលាមិនអនុញ្ញាតឱ្យនិយាយពីប្រធានបទនេះឱ្យលម្អិត ខ្ញុំនិងនិយាយពីវាតែប៉ុន្មាននាទីប៉ុណ្ណោះ តើប្រព័ន្ធផ្សព្វផ្សាយកំពុងធ្វើអ្វី? ប្រព័ន្ធផ្សព្វផ្សាយ "ចាប់យកចៀមខ្មៅនៅក្នុងចំណោមហ្វូងចៀមស ហើយនិយាយថាវាតំណាងឱ្យសាសនាឥស្លាម ដូចដែលពួកអ្នកបានឃើញស្រាប់ ក្នុងចំណោមពួកយើងមានអ្នកដែលបានធ្វើបង្ខូច ឥស្លាមយើងមានជនមូស្លីមជាច្រើនដែលបានហៅខ្លួនឯងថាជាអ្នកមូស្លីម តែពួកគេមិនអនុវត្តតាមសាសនាឥស្លាម ហើយប្រព័ន្ធផ្សព្វផ្សាយបានថតយកពួកគេដោយថាពួកគេគឺតំណាងឱ្យសាសនាឥស្លាម ជាច្រើនដង ហើយដែលប្រព័ន្ធផ្សព្វផ្សាយបានដកស្រង់អ្វីមួយ ពីគម្ពីរគួអាន និងបាន

បកស្រាយខុសពីខ្លឹមសាររបស់វា នៅពេលដែលគេ ទទួលបានដំណឹងអ្វីមួយ គេយកវាលាបពណ៌ឱ្យអ្នកឥស្លាមរាប់លាននាក់ ឧទាហរណ៍ដូចជាយើងទាំងអស់គ្នាដឹងថាអ្វីបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រនៃការទម្លាក់គ្រាប់បែកឆ្នាំ១៩៩៦នៅរដ្ឋអូក្លាហូម៉ា ខ្ញុំគិតថាកាលនោះ ជាការផ្ទុះធំជាងគេបំផុតដែលបានកើតឡើងទៅលើប្រេងកាតអាមេរិក មនុស្សជាង១០០នាក់ត្រូវបានសម្លាប់នៅក្នុងការផ្ទុះនេះឬមនុស្សជាង១៦៦នាក់ត្រូវបានសម្លាប់ កាលនោះមានចេញចំណងជើងសំខាន់ៗគឺថា (ផែនការក្បត់របស់ពួក**មូស្លីមបូព៌ា**) ជនមូស្លីមទាំងអស់ត្រូវតែផ្តន្ទាទោស ជនមូស្លីមទាំងអស់ត្រូវតែផ្តន្ទាទោស ចំណងជើងធំប្រចាំថ្ងៃនិងប្រចាំសប្តាហ៍ដូចគ្នា បន្ទាប់មកនៅពេលដែលពួកគេបានដឹងថាអ្នកដែលធ្វើវានោះជាទាហាន២នាក់របស់អាមេរិក ដំណឹងនេះបានបង្ហាញខ្លួននៅក្នុងប្រព័ន្ធផ្សព្វផ្សាយតែម្តងគត់ហើយបន្ទាប់មកក៏បានបាត់ទៅវិញ ពេលដែលពួកគេមិនទាន់បានដឹងពីអ្នកប្រព្រឹត្តពិតប្រាកដទេនោះចំណងជើងធំនៅតែមានប្រចាំសប្តាហ៍ ហើយនៅពេលដែលពួកគេដឹងពីអ្នកប្រព្រឹត្តពិតប្រាកដដំណឹងគឺមានតែមួយថ្ងៃឬពីរថ្ងៃប៉ុណ្ណោះ ហើយបន្ទាប់មកបានបាត់ទៅវិញ ហេតុអ្វី? នៅក្នុងប្រទេសឥណ្ឌា បុរសមូស្លីមជនជាតិអារ៉ាប់អាយុ៥០ ឆ្នាំរៀបការជាមួយក្មេងស្រីអាយុ១៨ ឆ្នាំ វាបានក្លាយជាចំណងជើងធំ ប៉ុន្តែនៅពេលដែលបុរសម្នាក់មិនមែនជាមូស្លីមមានអាយុ៥០ឆ្នាំបានចាប់រំលោភក្មេងស្រីអាយុ៦ឆ្នាំ បែរជាឃើញវានៅក្នុងព័ត៌មានខ្លីៗ

ទៅវិញ បុរសមូស្លីមជនជាតិអារ៉ាប់អាយុ៥០ ឆ្នាំនៅពេលដែលគាត់រៀបការ គាត់បានសុំការអនុញ្ញាត គាត់បានរៀបការជាមួយក្មេងស្រីនោះដោយការយល់ព្រមពីនាងផ្ទាល់និងការពេញចិត្តពីឪពុកម្ដាយនាង ប៉ុន្តែការពិតទាំងនេះ ប្រព័ន្ធផ្សព្វផ្សាយមិនចាប់អារម្មណ៍នោះទេ។ ប៉ុន្តែនៅពេលដែលបុរសម្នាក់ដែលមិនមែនជាមូស្លីមមានអាយុ៥០ឆ្នាំមករំលោភក្មេងស្រីដែលមានអាយុ៦ឆ្នាំ បែរជាឃើញវា នៅក្នុងព័ត៌មានខ្លី ទៅវិញហេតុអ្វី? ឧទាហរណ៍មួយទៀត ប៉ុន្មានសប្ដាហ៍ថ្មីនេះ មានការបន្ទុះគ្រាប់បែកដ៏ធំមួយនៅ ប៉ូណា ក្នុងហាងនុំប៉ុងនៅអាឡឺម៉ង់ មនុស្ស៩នាក់ត្រូវគេសម្លាប់ ជនជាប់ចោទគឺជាមូស្លីម(អ្នកមូស្លីម) វាគ្រាន់តែជាការចោទប្រកាន់តែមិនមានភស្តុតាងជាក់លាក់មួយរយភាគរយទេ នៅក្នុងថ្ងៃដដែលនោះ ពួកកុម្មុយនិស្តម៉ៅនិយមបានសម្លាប់ប៉ូលិស ១៦នាក់ពួកគេបានសម្លាប់ប៉ូលីស មិនមែនមនុស្សធម្មតាទេ តែជាប៉ូលិស ដំណឹងនេះត្រូវបានផ្សាយនៅក្នុង ព័ត៌មានខ្លីៗ ជនមូស្លីមដែលគេចោទប្រកាន់ពីបទសម្លាប់ជនស៊ីវិលចំនួន៩នាក់ ហើយពួកកុម្មុយនិស្តម៉ៅនិយមបានសម្លាប់ប៉ូលីស ១៦នាក់ បែរជាចុះផ្សាយនៅក្នុង ព័ត៌មានខ្លីៗទៅវិញ វាពិតជាចម្លែកខ្លាំងណាស់ ពួកគេបានស្គាល់ឃាតករដែលសម្លាប់ប៉ូលីសពួកគេមិនមែនជាជនស៊ីវិលនោះទេប៉ុន្តែពួកគេមានគ្រាប់មីស៊ីលនិងគ្រាប់រ៉ូកែត ពួកគេបានកម្ទេចស្ថានីយ៍ប៉ូលីសទាំងមូលតែម្ដង់ ដំណឹងនេះចុះផ្សាយនៅក្នុង ព័ត៌មានខ្លីៗទៅវិញ ផ្ទុយទៅវិញខណៈដែលពួកគេមិន

បានដឹងអ្នកនៅពីក្រោយការបំផ្ទុះគ្រាប់បែកនៅហាងនំប៉ុងរបស់អាឡឺម៉ង់ នៅទីក្រុងហ្គូណា ពួកគេបាននិយាយថាជនមូស្លីមគឺជាប់ចោទពីបទនេះ ការចោទប្រកាន់នៅបន្តលើជនមូស្លីមរហូត រយៈពេលជាច្រើនថ្ងៃ ដ្បិត ពួកគេមិនទាន់បានដឹងពីអ្នកប្រព្រឹត្តពិតប្រាកដនៅឡើយទេ ប៉ុន្តែ ដ្បិត ពួកគេបានដឹងថាអ្វីដែលពួកម៉ៅនិយមបានធ្វើទៅលើក្រុមប៉ូលីស ហើយ ដំណឹងនោះក៏បានចុះផ្សាយនៅក្នុងព័ត៌មានខ្លីៗទៅវិញ ឬប្រហែលជា នៅទំព័រដំបូងឬក្រដាសមួយចំនួនប៉ុន្តែនៅខាងក្រោមគេ ហើយដំណឹងក៏ បានបាត់ទៅវិញយ៉ាងឆាប់រហ័សពីប្រព័ន្ធផ្សព្វផ្សាយទាំងឡាយ ដូច្នេះ កត្តាដែលសំខាន់គឺប្រព័ន្ធផ្សព្វផ្សាយ ប្រព័ន្ធផ្សព្វផ្សាយនិងសាសនា ឥស្លាម សង្គ្រាមឬសន្តិភាព ជាអកុសលយើងមូស្លីមទន់ខ្សោយខ្លាំង ណាស់វិស័យប្រព័ន្ធផ្សព្វផ្សាយ ពិតជាទន់ខ្សោយខ្លាំងណាស់ ប្រហែល ជាយើងមានប្រព័ន្ធផ្សព្វផ្សាយល្អក្នុងវិស័យចំរៀង និងរាំដែលយើងមាន ជាច្រើនប៉ុសតិ៍ ប៉ុន្តែសម្រាប់ប៉ុសតិ៍ឥស្លាមជាអកុសល ទន់ខ្សោយណាស់ បាទ, ខ្ញុំដឹងថាមានមនុស្សអាក្រក់នៅក្នុងសង្គមរបស់យើង ប៉ុន្តែរហូតមក ដល់ពេលនេះ ដ្បិតមានមនុស្សអាក្រក់ទាំងនោះជាទូទៅរហូតមកមក ដល់បច្ចុប្បន្ន មូស្លីមគឺជាមនុស្សដែលច្រើនជាងគេបំផុតនៅលើពិភព លោកដែលមិនពិសារស្រា ខ្ញុំដឹងថាជនមូស្លីមមួយចំនួនអាចផឹកច្រើន ជាងអ្នកមិនមែនមូស្លីម ប៉ុន្តែជាទូទៅ, សង្គមដែលធំហើយដែលមិនផឹក គ្រឿងស្រវឹងនោះគឺជាសង្គមឥស្លាម ជាទូទៅ, សង្គមធំដែលបរិច្ចាគទាន

គឺជាសង្គមមូស្លីមគ្មានអ្នកណាឡើយក្រៅពីអ្នកមូស្លីម, គ្មានមនុស្សណាឡើយនៅលើពិភពលោកនេះ ប្រៀបនឹងអ្នកមូស្លីមដែលកាន់ខ្ជាប់នឹងសាសនា ទាក់ទងនឹងសុជីវធម៌និងយុត្តិធម៌ ឱ្យតម្លៃមនុស្សនិងសីលធម៌ មិនអាចយកមនុស្សណាម្នាក់មកប្រៀបនឹងអ្នកមូស្លីមដែលកាន់ខ្ជាប់នឹងសាសនាទាក់ទងនឹងសុជីវធម៌និងយុត្តិធម៌ ឱ្យតម្លៃមនុស្សនិងសីលធម៌ ខ្ញុំតែងតែលើកឧទាហរណ៍នេះ ឧបមាថាអ្នកចង់ត្រួតពិនិត្យគុណភាពរថយន្ត សូមយករថយន្ត Mercedes S-600 ធ្វើជាគំរូក្នុងឆ្នាំ 2010 ហើយអ្នកចង់សាកល្បងរថយន្ត ហើយអ្នកយកមនុស្សបើកបរមិនស្ទាត់ជំនាញ មកបើករថយន្តនេះ ហើយអ្នកបើកបរនោះក៏បើករថយន្តទៅបុកគេហើយបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ តើអ្នកស្តីបន្ទោសនរណា? តើអ្នកនឹងស្តីបន្ទោសរថយន្តឬអ្នកបើកបរ? ជាការពិតណាស់អ្នកនឹងស្តីបន្ទោសអ្នកបើកបរ ប្រសិនបើអ្នកចង់ដឹងពីគុណភាពរថយន្តនេះ អ្នកចាំបាច់ត្រូវដឹងពីលក្ខណៈពិសេសរបស់វាសិន ភាពធន់របស់មានប៉ុន្មាន? តើវិធានការសុវត្ថិភាពរបស់វាយ៉ាងម៉េចដែរ? វាមានសមត្ថភាពអ្វីខ្លះ? មធ្យមភាគដែលគេកំណត់មកប៉ុន្មានដែរ? ប្រព័ន្ធហ្វ្រាំងនិងសោ សូមមើលលក្ខណៈពិសេសរបស់វា វិធីតែមួយគត់ក្នុងការសាកល្បងរថយន្តនេះអ្នកត្រូវដាក់អ្នកបើកបរដែលមានជំនាញវិជ្ជាជីវៈច្បាស់ក្នុងការសាកល្បងរថយន្តនេះ ប្រសិនបើអ្នកចង់ដឹងការពិត ចូរអ្នកស្វែងយល់ពីសាសនាឥស្លាម មិនត្រូវមើលជនមូស្លីមទេ ប៉ុន្តែចូរមើលអត្ថបទដែលមានក្នុងគម្ពីរគួរអាន

និង ហាទីសរបស់ណាពី ចូរអ្នកកុំមើលខ្ញុំ, ហើយកុំមើលជនមូស្លីម ប្រសិនបើអ្នកចង់សាកល្បងរថយន្តអ្នកត្រូវដាក់អ្នកបើកបរដែលមាន ជំនាញវិជ្ជាជីវៈច្បាស់លាស់មកកាន់ចង្កូតរថយន្តនោះ គំរូដ៏ល្អបំផុតដែល អ្នកអាចយកមកធ្វើគំរូជនមូស្លីមបាននោះគឺព្យាការីមហាំម៉ាត់ សូមអានជី វប្រវត្តិរបស់ព្យាការីមហាំម៉ាត់ហើយអ្នកនឹងឃើញថាគាត់គឺជាគំរូល្អបំផុត សម្រាប់ជនមូស្លីម ប៉ុន្តែជាដ៏គំរូល្អបំផុតសម្រាប់មនុស្សលោកទាំងមូល នេះហើយជាមូលហេតុ, ដូចដែលខ្ញុំបាននិយាយថា ការយល់ដឹងពី សាសនានេះត្រូវតែត្រឡប់ទៅមើលអត្ថបទគម្ពីរ នៅពេលដែលអ្នកបាន អានអត្ថបទចេញពីប្រភពដើមរបស់វាដែលត្រឹមត្រូវៈ គម្ពីរគួរអាន និង ហាទីសណាពី នៅពេលនោះ អ្នកនិងអាចវាយតម្លៃពិតរបស់ ឥស្លាម។